ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

# គោលការណ៍ណែនាំ
# ស្តីពី
# ការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រី នៅកម្ពុជា

រៀបចំដោយ៖ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

ឧបត្ថម្ភដោយ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

កក្កដា ២០១៥

**គោលការណ៍ណែនាំស្តីពីការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិកសហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា**

បោះពុម្ពផ្សាយ៖ ខែកក្កដា ឆ្នាំ២០១៥
បោះពុម្ពផ្សាយដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)
អាសយដ្ឋាន៖ លេខ:៥៤ បេអេហ្វ៤៩/ ផ្លូវ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក
រាជធានីភ្នំពេញ ទូរស័ព្ទលេខ (០២៣) ៨៨៣ ៤២៧ ទូរសារលេខ (០២៣) ៨៨៣ ៤២៧
© គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា


គោលការណ៍ណែនាំអំពីការសិក្សាស្រាវជ្រាវ... ............ ១
០១ កំណត់ចំណាំដែលមានប្រយោជន៍សម្រាប់គ្រូបង្គោល............ ២
០២ ការសាយភាយអំពីចលនាសហគមន៍កសិកម្ម ............ ១០
០៣ ប្រវត្តិរបស់ចលនាសហគមន៍កសិកម្ម ............ ១១
០៤ សម្ព័ន្ធសហគមន៍អន្តរជាតិ [ICA] និងគោលការណ៍គ្រឹះសហគមន៍ ............ ១៧
០៥ ទម្រង់សហគមន៍កសិកម្ម ............ ២៨
០៦ រចនាសម្ព័ន្ធចាត់តាំងនៃសហគមន៍កសិកម្ម............ ៣១
០៧ ការរៀបចំសហគមន៍កសិកម្ម ............ ៣៣
០៨ ច្បាប់ វិធាន បទបញ្ជាផ្ទៃក្នុង/និងលក្ខន្តិកៈសហគមន៍កសិកម្ម............ ៣៥
០៩ ហេតុអ្វីត្រូវចូលជាសមាជិកសហគមន៍កសិកម្ម? ............ ៤០
១០ សិទ្ធិ និងកាតព្វកិច្ចរបស់សហគមន៍កសិកម្ម............ ៤១
១១ សិទ្ធិ និងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម ............ ៤៣
១២ មហាសន្និបាតសហគមន៍កសិកម្ម ............ ៤៤
១៣ សិទ្ធិ និងភារកិច្ចសមាជិកក្រុមប្រឹក្សាភិបាល ............ ៤៦
១៤ គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម ............ ៤៩
១៥ សិទ្ធិ និងភារកិច្ចរបស់អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងទៀត ............ ៥០
១៦ សៀវភៅស្តីពីសហគមន៍កសិកម្ម............ ៥២
១៧ ការបង្កើតដើមទុននៅក្នុងសហគមន៍កសិកម្ម ............ ៥៤
១៨ សេវាកម្មផ្តល់ដោយសហគមន៍កសិកម្ម ............ ៥៥
១៩ សេវាកម្មឥណទានផ្តល់ដោយសហគមន៍កសិកម្ម............ ៥៧

២០ ការធ្វើសវនកម្មលើសហាគមន៍កសិកម្ម ........................................................ ៦០

២១ ការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់សហាគមន៍កសិកម្ម............................................ ៦១

២២ ការលើកកម្ពស់ការគ្រប់គ្រងមុខរបររបស់សហាគមន៍កសិកម្ម...................................... ៦២

២៣ ចំណុចពិសេសសម្រាប់ការពិចារណា ..........................................................៦៣

២៤ សេចក្តីសង្ខេបនៃការពិភាក្សា ............................................................... ៦៦

ឧបសម្ព័ន្ធ ១ ចលនាសហាគមន៍កសិកម្មនៅកម្ពុជា ............................................. ៦៩

អំពីអ្នកនិពន្ធ.......................................................................................៧៤

## គោលការណ៍ណែនាំអំពីការសិក្សាស្រាវជ្រាវ

០១ **"គោលការណ៍ណែនាំអំពី ការសិក្សាស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលសមាជិក សហគមន៍កសិកម្ម និងមន្ត្រីនៅកម្ពុជា"** នេះ ត្រូវបានរៀបរៀងឡើងក្នុងគោលបំណងផ្តល់កម្មវិធីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លីដល់សមាជិក និងមន្ត្រីសហគមន៍កសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

០២ សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលនេះ គឺផ្អែកលើបទបញ្ញត្តិនៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងបទពិសោធន៍របស់មន្ត្រីផ្សព្វផ្សាយសហគមន៍កសិកម្មនៅក្នុងវិស័យនេះ ព្រមទាំងមកពីបណ្តាប្រទេសដែលសហគមន៍កសិកម្មទទួលបានជោគជ័យខ្លាំងផងដែរ។ ច្បាប់បច្ចុប្បន្នទំនងជាមានការតាក់តែងបានល្អ និងគ្រប់ជ្រុងជ្រោយ ប៉ុន្តែការអនុវត្តរបស់វាក្នុងវិស័យនេះ ពិតជាចាំបាច់ត្រូវការការកែលម្អបន្ថែមទៀត។ ទោះបីជាបទបញ្ញត្តិ និងការគាំពារទាំងអស់ ត្រូវបានបង្កើតឡើងនៅក្នុងអត្ថបទផ្សេងៗនៃច្បាប់នេះក្តីក៏ការអនុវត្តរបស់វាឈានទៅរកលទ្ធផលជោគជ័យ និងពិតប្រាកដ ត្រូវពឹងផ្អែកលើការប៉ិនប្រសប់របស់មហាសន្និបាត និងក្រុមប្រឹក្សាភិបាល។ មិនមែនអ្វីគ្រប់យ៉ាងសុទ្ធតែអាចសរសេរចូលទៅក្នុងច្បាប់នេះបានទេ ដោយបញ្ហាជាច្រើននៅតែត្រូវការការបកស្រាយផ្អែកទៅលើកាលៈទេសៈបច្ចុប្បន្ន។នោះជាមូលហេតុដែលច្បាប់ទាំងអស់នៅក្នុងពិភពលោក ផ្តល់ឱកាសសម្រាប់ការធ្វើវិសោធនកម្មនិងការកែលម្អ។

០៣ តាមការរំពឹងទុកថា គ្រូបង្គោលនិងមន្ត្រីផ្សព្វផ្សាយសហគមន៍កសិកម្មក្នុងប្រទេសកម្ពុជានឹងធ្វើការកត់សម្គាល់ផ្នែកផ្សេងៗនៃសៀវភៅណែនាំនេះ ដើម្បីដោះស្រាយប្រធានបទនេះឱ្យបានសមស្រប។ ជំពូកពិសេសមួយស្តីពី 'កំណត់សម្គាល់មានប្រយោជន៍សម្រាប់គ្រូបង្គោល' នេះ ត្រូវបានបន្ថែមដើម្បីផ្តល់ព័ត៌មានសារតារដល់គ្រូបង្គោល។ ជំពូកនេះកត់សម្គាល់ការអភិវឌ្ឍក្នុងវិស័យនេះនៅក្នុងប្រទេសផ្សេងទៀតៗផងដែរ។

០៤ ដោយមានការរំពឹងទុកថា គ្រូបង្គោលនឹងផ្តល់កម្មវិធីបណ្តុះបណ្តាលដោយទាញយកអត្ថប្រយោជន៍ពីពត៌មានផ្តល់ឱ្យនៅក្នុងសៀវភៅណែនាំនេះ ព្រមទាំងបទពិសោធន៍របស់សហគមន៍កសិកម្មដែលមានស្រាប់ផងដែរ។ នៅចុងបញ្ចប់នៃជំពូកនេះមាន "ចំណុចសម្រាប់ការពិភាក្សា"ផងដែរ។ គ្រូបង្គោលអាចប្រើប្រាស់ចំណុចទាំងនេះបានដើម្បីសង្ខេបជំពូក ព្រមទាំងដើម្បីពិនិត្យមើលការយល់ដឹងរបស់សិក្ខាកាមលើបញ្ហានេះផងដែរ។

កំណត់សម្គាល់មួយស្តីពីចលនាសហគមន៍កសិកម្មនៅកម្ពុជា ត្រូវបានដាក់ជា **ឧបសម្ព័ន្ធ ១**។

---

# ជំពូកទី ០១
# កំណាត់ចំណាំដែលមានប្រយោជន៍សម្រាប់គ្រូបង្គោល

តាមការរំពឹងទុកថា គ្រូបង្គោលដែលតម្រូវឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាល នឹងដឹងពីទិដ្ឋភាពសំខាន់ៗផ្សេងៗនៃការអភិវឌ្ឍរបស់សហគមន៍កសិកម្ម។ កំណត់សម្គាល់ទាំងនេះក៏នឹងនាំយកនូវបទពិសោធន៍របស់សហគមន៍កសិកម្មនៅក្នុងប្រទេសផ្សេងទៀតផងដែរ។ មានកំណត់សម្គាល់មានប្រយោជន៍មួយចំនួនសម្រាប់គោលការណ៍ណែនាំរបស់គ្រូបង្គោលត្រូវបានផ្តល់ឱ្យដូចខាងក្រោម៖

រចនាសម្ព័ន្ធរបស់សហគមន៍កសិកម្មឈរលើសរសរស្តម្ភយ៉ាងរឹងមាំចំនួនបួន។ សរសរស្តម្ភទាំងនេះមានដូចជា៖ [i] ការចូលរួម [ii] អភិបាលកិច្ច [iii] តម្លាភាព និង [iv] សេវាកម្ម។ គោលការណ៍ទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងដែរនៅក្នុងគោលការណ៍ទាំងប្រាំពីរនៃសម្ព័ន្ធសហគមន៍អន្តរជាតិ ដែលមានការទទួលស្គាល់ជាសាកល។ ខណៈគោលការណ៍នៃសម្ព័ន្ធសហគមន៍អន្តរជាតិនេះសម្រាប់ណែនាំអំពីចលនារួមរបស់សហគមន៍កសិកម្ម គោលការណ៍ចំនួនបួនដូចបានរៀបរាប់ពីខាងលើ ជំរុញសហគមន៍កសិកម្មឆ្ពោះទៅការក្លាយខ្លួនជាស្ថាប័នមានប្រសិទ្ធភាពក្នុងការបម្រើសេវាកម្មដល់សមាជិករបស់ខ្លួន។ សម្រាប់គោលបំណងបញ្ជាក់ឱ្យកាន់តែច្បាស់ និងការយល់ដឹងកាន់តែប្រសើរ ចូរយើងពិភាក្សាគ្នាលើគោលការណ៍ទាំងបួននេះ៖

***[i] ការចូលរួម៖*** លក្ខខណ្ឌជាមូលដ្ឋានសម្រាប់សហគមន៍កសិកម្មទទួលបានភាពជោគជ័យ គឺការចូលរួមពីសមាជិកកសិករនៅក្នុងគ្រប់ប្រតិបត្តិការស្ថាប័ន និងមុខរបរ។ គ្មានសហគមន៍កសិកម្មណាអាចផ្តល់សេវាកម្មបានល្អបំផុតដោយគ្មានការចូលរួមពីសមាជិកឡើយ។ ការចូលរួមនៅទីនេះមានន័យថា ការចូលរួមរាល់កិច្ចប្រជុំ ការផ្តល់មុខតំណែងផ្សេងៗដោយស្ម័គ្រចិត្តតាមរយៈការបោះឆ្នោតជ្រើសតាំង ការធ្វើការរួមគ្នាដើម្បីភាពរីកចម្រើនរបស់សហគមន៍កសិកម្មពួកគេ ការសួរសំណួរ [អំពីរបាយការណ៍សវនកម្មប្រចាំឆ្នាំ និងកម្មវិធីការងារ ។ល។ អំឡុងពេលកិច្ចប្រជុំ ការលើកជាសំណូមពរអំឡុងពេលកិច្ចប្រជុំ និងក្រៅកិច្ចប្រជុំ ការទិញយក ការលក់ចេញផលិតផលទាំងអស់តាមរយៈសហគមន៍កសិកម្ម ហើយប្រសិនបើអ្នកទទួលយកប្រាក់កម្ចីពីសហគមន៍កសិកម្ម វាក្លាយជាការទទួលខុសត្រូវរបស់អ្នកក្នុងសងរម្លស់រហូតគ្រប់ចំនួន និងទាន់ពេលវេលាដើម្បីឱ្យសមាជិកទាំងអស់ផ្សេងទៀតអាចទាញយកអត្ថប្រយោជន៍ពីប្រាក់កម្ចីនេះ ការដាក់ប្រាក់បញ្ញើដោយស្ម័គ្រចិត្តក្នុងសហគមន៍កសិកម្ម ការទិញយករាល់ទិន្នផលកសិដ្ឋាន និងការអនុវត្តរបស់សហគមន៍កសិកម្ម ។ល។ ស្ថាប័នសហគមន៍កសិកម្មទាំងអស់នៅទូទាំងពិភពលោករីកចម្រើន និងទទួលបានជោគជ័យដោយឈរលើគោលការណ៍នៃការចូលរួម ហើយការចូលរួមត្រូវតែជាការស្ម័គ្រចិត្ត ឥតគិតថ្លៃ និងដោយគ្មានការគ្រោងទុក។ ការ

ចូលរួមកម្រិតខ្ពស់ពង្រឹងប្រពៃណីប្រជាធិបតេយ្យ និងជំហរផ្នែកសេដ្ឋកិច្ចរបស់សហគមន៍កសិកម្ម។ ការចូលរួមគឺជាការបង្ហាញពីភាពរស់រវើកនៅក្នុងស្ថាប័ននេះ។

*(ii) អភិបាលកិច្ច៖* សហគមន៍កសិកម្ម គឺជាសហគ្រាសពាណិជ្ជកម្មស្វយ័តដែលមានលក្ខណៈប្រជាធិបតេយ្យ។ សកម្មភាព និងប្រតិបត្តិការមុខរបរទាំងអស់ត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋានរួសរាយរាក់ទាក់ កិច្ចសហការណ៍ និងការយោគយល់គ្នាទៅវិញទៅមក និងដោយមានការយល់ព្រមទាំងស្រុងពីសមាជិក។ រចនាសម្ព័ន្ធអភិបាលកិច្ចរបស់សហគមន៍កសិកម្ម មានកិច្ចប្រជុំមហាសន្និបាត ដែលសំខាន់បំផុតក្នុងការធ្វើការសម្រេចចិត្ត និងដើម្បីកែលម្អកម្មវិធី និងរបាយការណ៍ហិរញ្ញវត្ថុ។ កិច្ចប្រជុំមហាសន្និបាត បោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាភិបាល ជាសកម្មភាពដែលដាក់ការទទួលខុសត្រូវជាក់លាក់លើក្រុមប្រឹក្សាភិបាល ឱ្យអនុវត្តសេចក្តីសម្រេចរបស់កិច្ចប្រជុំមហាសន្និបាត ខណៈគោលនយោបាយដាក់ចេញដោយកិច្ចប្រជុំមហាសន្និបាត ហើយក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវចំពោះកិច្ចប្រជុំមហាសន្និបាត។ ក្រុមប្រឹក្សាភិបាលតូចជាងកិច្ចប្រជុំមហាសន្និបាត។ ក្រុមប្រឹក្សាភិបាលលើកជាសំណូមពរ (មិនមែនចេញបញ្ជាឡើយ) ក្នុងកិច្ចប្រជុំមហាសន្និបាតនេះ។ ក្រុមប្រឹក្សាភិបាលទទួលយកសិទ្ធិអំណាចរបស់ខ្លួនក្នុងការតែងតាំងបុគ្គលិក ពីកិច្ចប្រជុំមហាសន្និបាត។ ស្រដៀងគ្នានេះដែរ កិច្ចប្រជុំមហាសន្និបាតបោះឆ្នោតជ្រើសតាំង ឬជ្រើសរើសសមាជិកពីររូបឱ្យធ្វើជាសវនករ និងអ្នកត្រួតពិនិត្យ។ អភិបាលកិច្ចមានប្រសិទ្ធភាព នៅពេលស្ថាប័នដែលត្រូវបានបោះឆ្នោតជ្រើសតាំងទាំងអស់នេះ ធ្វើកិច្ចការរបស់ខ្លួនដោយអនុលោមទៅតាមគោលនយោបាយដាក់ចេញដោយកិច្ចប្រជុំមហាសន្និបាតនិងបទបញ្ញត្តិស្តីពីសហគមន៍កសិកម្មដែលមានចែងនៅក្នុងច្បាប់ និងនៅក្នុងក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន។

អភិបាលកិច្ចនៅទីនេះ ក៏ស្នើឱ្យរៀបចំកិច្ចប្រជុំទាន់ពេលវេលា និងពិចារណាអំពីរបៀបវារៈដែលមានការតាក់តែងបានល្អដោយមានហេតុការណ៍ និងតួលេខពាក់ព័ន្ធផងដែរ។ អភិបាលកិច្ចស្នើឱ្យមានកិច្ចពិភាក្សា និងការសម្រេចចិត្តដោយត្រឹមត្រូវ។ បទបញ្ញត្តិជាក់លាក់ស្តីពីសហគមន៍កសិកម្មដែលមានចែងនៅក្នុងច្បាប់ ត្រូវបានធ្វើឡើងស្តីពីការគ្រប់គ្រងកិច្ចប្រជុំ អាណត្តិកាន់តំណែងរបស់មន្ត្រីការិយាល័យ) សិទ្ធិអំណាចរបស់ស្ថាប័នដែលត្រូវបានបោះឆ្នោតជ្រើសតាំង និងមុខងារដែលស្ថាប័នទាំងនោះត្រូវអនុវត្ត។ អភិបាលកិច្ចមានន័យថា ចាំបាច់ត្រូវអនុវត្តតាមបទបញ្ញត្តិទាំងអស់នេះ និងធ្វើការអង្កេតតាមដានឱ្យបានតឹងរឹង បម្រើឱ្យផលប្រយោជន៍របស់សហគមន៍កសិកម្ម និងសមាជិករបស់ខ្លួន។ ប្រតិបត្តិការប្រកបដោយប្រជាធិបតេយ្យ គឺជាគោលនៃការទទួលបានជោគជ័យសម្រាប់សហគមន៍កសិកម្ម ដែលទទួលបានទំនុកចិត្ត និងការគោរពពីសមាជិករបស់ខ្លួន។

អភិបាលកិច្ចក៏ស្នើឱ្យមានការអភិវឌ្ឍ និងការរក្សាទំនាក់ទំនងស្និទ្ធស្នាលជាមួយស្ថាប័នពាក់ព័ន្ធ និងសហគមន៍កសិកម្មជាសាខាផងដែរ ដើម្បីឱ្យប្រតិបត្តិការមុខរបរដំណើរការដោយរលូន និងត្រឹមត្រូវ។

អភិបាលកិច្ចល្អស្នើឱ្យមានការអនុវត្តយ៉ាងតឹងរឹងតាមបទបញ្ញត្តិស្តីពីសហគមន៍កសិកម្មដូចមានចែង នៅក្នុងច្បាប់ ហើយស្របនឹងគោលនយោបាយដែលបានដាក់ចេញដោយកិច្ចប្រជុំមហាសន្និបាត។

*តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាភិបាល៖* ដោយអនុលោមតាមទស្សនវិស័យរបស់សហគមន៍កសិកម្ម និងវិធីសាស្ត្រជាយុទ្ធសាស្ត្ររបស់ខ្លួន មុខងាររបស់ក្រុមប្រឹក្សាភិបាល ទាក់ទងនឹងការពិនិត្យតាមដាន និងគ្រប់គ្រងផែនការប្រតិបត្តិការ និងដើម្បីធានាថាផលប្រយោជន៍របស់សមាជិកត្រូវបានឃ្លាំមើលគ្រប់ពេលវេលា។ ដើម្បីបំពេញការងារនេះប្រកបដោយប្រសិទ្ធភាព គួរចាត់វិធានការដាក់លាក់ជាប្រចាំ។ ផែនការប្រចាំឆ្នាំ ឬប្រចាំឆមាស ជួយក្រុមប្រឹក្សាភិបាលធានាថាមានពេលវេលា និងធនធានសម្រាប់សកម្មភាពទាំងនេះ។ ផែនការបែបនេះមិនមែនមានន័យថាជាការដាក់កម្រិតលើការគិតប្រកបដោយភាពច្នៃប្រឌិតរបស់ក្រុមប្រឹក្សាភិបាលនោះទេ ប៉ុន្តែផ្ទុយទៅវិញវាជាឧបករណ៍មួយសម្រាប់ជួយនាយក គ្រប់គ្រងការគិតរបស់ពួកគេ និងចៀសវាងការផ្តោតលើទិដ្ឋភាពមួយចំនួន។

ផែនការប្រភេទនេះ និងសកម្មភាពអ្វីខ្លះដែលចាត់តាំងទៅក្រុមប្រឹក្សាភិបាល នឹងពឹងផ្អែកលើលក្ខណៈនៃមុខរបររបស់សហគមន៍កសិកម្ម។ ផែនការនឹងរាប់បញ្ចូលចំណុចដែលត្រូវលើកឡើងក្នុងរបៀបវារៈអំឡុងកិច្ចប្រជុំនីមួយៗរបស់ក្រុមប្រឹក្សាភិបាល លើកលែងតែចំណុចណាដែលត្រូវបានលើកយកមកសម្រាប់ពិភាក្សាអំពីបញ្ហាតែមួយ (កិច្ចប្រជុំវិសាមញ្ញ ឬកិច្ចប្រជុំគោលបំណងតែមួយ)។

*ភាពញឹកញាប់នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល៖* ទោះបីជាភាពញឹកញាប់នៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលនឹងពឹងផ្អែកលើលក្ខណៈរបស់សហគមន៍កសិកម្ម និងសកម្មភាពដែលពាក់ព័ន្ធក្តី ក៏ជាទូទៅគេយល់ស្របថា ដើម្បីឱ្យក្រុមប្រឹក្សាភិបាលអាចផ្តល់ការតម្រង់ទិសដល់អង្គការ វាគួរតែជួបប្រជុំប្រចាំខែ។ ប្រសិនបើមិនមានការកោះប្រជុំញឹកញាប់ទេនោះ គណៈគ្រប់គ្រងនឹងត្រូវធ្វើការសម្រេចចិត្តដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូរគោលនយោបាយ ដែលមិនឆ្លុះបញ្ចាំងពីអ្វីដែលសមាជិកចង់បាន។ ប្រសិនបើជួបប្រជុំញឹកញាប់ជាងនេះ អាចនឹងមានគ្រោះថ្នាក់ដោយសារការជ្រៀតជ្រែកលើការងារប្រតិបត្តិការដែលគួរតែទុកឱ្យអ្នកគ្រប់គ្រង។

***[iii] តម្លាភាព៖*** ដើម្បីបន្តរក្សាភាពស្មោះត្រង់ និងធានាការចូលរួមរបស់សមាជិក សហគមន៍កសិកម្មគួរតែមានស្មារតីតម្លាភាពនៅក្នុងប្រតិបត្តិការទាំងអស់របស់ខ្លួន ឧទាហរណ៍ដូចជា ប្រតិបត្តិការអាជីវកម្ម ការគ្រប់គ្រងប្រកបដោយប្រជាធិបតេយ្យ ការចូលរួមរបស់សមាជិក ទំនាក់ទំនងស្និទ្ធស្នាលជាមួយស្ថាប័នហិរញ្ញវត្ថុ ការចុះបញ្ជីគណនេយ្យ ការទូទាត់សាច់ប្រាក់ និងទីភ្នាក់ងារត្រួតពិនិត្យរបស់រដ្ឋាភិបាល។ តាមការរំពឹងថា ក្រុមប្រឹក្សាភិបាលរបស់សហគមន៍កសិកម្មនឹងរៀបចំរបាយការណ៍ប្រចាំឆ្នាំ របាយការណ៍គណនេយ្យ របាយការណ៍សវនកម្ម របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំដែលត្រឹមត្រូវពិតប្រាកដ និងយុត្តិធម៌សម្រាប់ដាក់ជូនកិច្ចប្រជុំរបស់មហាសន្និបាតដើម្បីធ្វើសេចក្តីសម្រេចឱ្យបានត្រឹមត្រូវ។

សមាជិកគួរតែមានទំនុកចិត្តលើប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ ដែលធ្វើឡើងដោយសហគមន៍កសិកម្មទាក់ទងទៅនឹងការទិញទាំងអស់ និងឥណទានដែលសមាជិកទទួលបាន និងប្រាក់សងទៅសហគមន៍កសិកម្មវិញ។ សមាជិកគួរតែមានសេរីភាពក្នុងការទទួលបានព័ត៌មានស្ដីពីការដោះដូរទំនិញជាប្រាក់ជាមួយសហគមន៍កសិកម្មគ្រប់ពេល។ ពួកគេគួរតែអាចពិនិត្យមើលគណនីរបស់ខ្លួនបានដោយគ្មានការរារាំង ព្រមទាំងជាមួយសមាជិកក្រុមប្រឹក្សាភិបាល អ្នកគ្រប់គ្រង និងមន្ត្រីផ្សេងៗទៀតផងដែរ។

ឧបករណ៍ហិរញ្ញវត្ថុដូចជាសៀវភៅប្រាក់បញ្ញើ សៀវភៅមូលប្បទានបត្រ និងប័ណ្ណឥណទានជាដើម គួរតែរៀបចំឱ្យបានទាន់ពេលវេលា និងប្រគល់ទៅឱ្យសមាជិកដើម្បីរក្សាទុកឱ្យមានសុវត្ថិភាព។ អ្នកគ្រប់គ្រង ឬលេខាគួរតែរក្សាទុកគណនីឱ្យបានត្រឹមត្រូវនៅក្នុងសហគមន៍កសិកម្ម ក៏ដូចជានៅជាមួយស្ថាប័នហិរញ្ញវត្ថុ។ សវនកម្មគួរតែធ្វើឡើងឱ្យបានទាន់ពេលវេលា ហើយរបាយការណ៍សវនកម្មត្រឹមត្រូវ ចាំបាច់ត្រូវដាក់ជូនទៅកិច្ចប្រជុំមហាសន្និបាត បន្ទាប់ពីក្រុមប្រឹក្សាភិបាល និងគណៈកម្មការត្រួតពិនិត្យ ពិនិត្យមើលរួច។

ចំណុចលក់ ឃ្លាំងនិងមធ្យោបាយដឹកជញ្ជូនទាំងអស់ គួរតែមានរបៀបរៀបរយល្អ និងដំណើរការពេញលេញគ្រប់ពេល។ យានយន្តទាំងអស់គួរតែមានសៀវភៅសកម្មភាពយានយន្តរបស់វា។ វាគួរតែមានការធានាថា ប្រាក់ទាំងអស់ដែលសមាជិកបានផ្ដល់ឱ្យទៅសហគមន៍កសិកម្មធៀបនឹងការទិញ និង/ ឬ ការសងឥណទានវិញ ត្រូវតែដំណើរការតាមរយៈធនាគារ ហើយត្រូវចេញវិក្កយបត្រត្រឹមត្រូវទៅឱ្យសមាជិកដោយមានការកត់ត្រាទៅក្នុងសៀវភៅប្រាក់បញ្ញើរបស់ពួកគេ។ អ្នកគ្រប់គ្រង ឬបេឡាកររបស់សហគមន៍កសិកម្ម មិនត្រូវលាយឡំមូលនិធិផ្លូវការជាមួយនឹងមូលនិធិផ្ទាល់ខ្លួនរបស់ពួកគេដែលអាចនាំឱ្យមានអំពើពុករលួយ និងការគ្រប់គ្រងមិនបានល្អឡើយ។

ប្រសិនបើមានប្រព័ន្ធហិរញ្ញវត្ថុច្បាស់លាស់ និងស្មោះត្រង់ សមាជិកនឹងមានទំនុកចិត្តខ្លាំងលើសហគមន៍កសិកម្មរបស់ខ្លួន ហើយពួកគេនឹងនៅតែមានភាពស្មោះត្រង់។ ភាពស្មោះត្រង់ និងទំនុកចិត្តរបស់សមាជិក គឺជាកត្តាសំខាន់ឈានទៅប្រតិបត្តិការជោគជ័យ មានប្រសិទ្ធភាព និងត្រឹមត្រូវ។

*ហេតុអ្វីបានជាត្រូវរក្សាទុកគណនីឱ្យបានត្រឹមត្រូវ?៖* សមាជិកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលនៃក្រុមកសិករ ឬសហគមន៍កសិកម្ម ហើយជាធម្មតា អ្នកទាំងនោះគឺជាតំណាងរបស់ពួកគេដែលជាកសិករដូចគ្នានិងមិនមែនជាអ្នកគ្រប់គ្រងពាណិជ្ជកម្មអាជីព។ ក្រុមប្រឹក្សាភិបាលប្រហែលជាមិនដឹងពីការទទួលខុសត្រូវរបស់ខ្លួន ឬរបៀបអាន និងប្រើប្រាស់របាយការណ៍គណនេយ្យឡើយនៅក្នុងការធ្វើសេចក្ដីសម្រេច។ ក្រុមប្រឹក្សាភិបាលប្រហែលជាមិនយល់ច្បាស់ពីមុខងារទាំងមូលនោះទេ ប៉ុន្តែប្រហែលជាយល់ថាវាជាការតម្រូវរបស់រដ្ឋាភិបាល ហេតុដូច្នេះហើយប្រហែលជាមិនចង់ចំណាយប្រាក់ដើម្បីបង្កើតមុខងារនេះឡើយ។ ហេតុអ្វីបានជាសហគមន៍កសិកម្មមានការចុះបញ្ជីគណនេយ្យ និងការចុះបញ្ជីស្ដុកត្រឹមត្រូវ? តើវាជាការចាំបាច់? តើមានហេតុផលអ្វីខ្លះ?

*ហេតុផលទី ១៖* ការទូទាត់ប្រាក់របស់អ្នកផ្សេងៗទៀតត្រូវការការជឿទុកចិត្ត។ សមាជិកទាំងអស់ជាម្ចាស់កម្មសិទ្ធិរួមគ្នាលើទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្ម (អគារ គ្រឿងចក្រ យានយន្ត គ្រឿងសង្ហារិម ស្តុក ប្រាក់នៅក្នុងគណនីធនាគារ ។ល។)។ គ្មានសមាជិកណាអាចអះអាងថាខ្លួនជាម្ចាស់ទ្រព្យសម្បត្តិរបស់សហគមន៍កសិកម្មតែម្នាក់ឯងបានឡើយ។ ដូច្នេះ មុខរបររបស់សហគមន៍កសិកម្មត្រូវមានការគ្រប់គ្រងទៅតាមវិធានជាក់លាក់ និងការសម្រេចដែលសមាជិកបានយល់ស្របរួមគ្នា។

*ហេតុផលទី ២៖* សមាជិកវិនិយោគប្រាក់របស់ពួកគេទៅលើសហគមន៍កសិកម្ម។ ពួកគេមិនចង់ខាតបង់ប្រាក់របស់ខ្លួនឡើយ ប៉ុន្តែមានការព្រួយបារម្ភថា ប្រាក់របស់ពួកគេនឹងបាត់បង់។ ទោះជាយ៉ាងណា សមាជិកទាំងអស់មិនអាចចូលរួមពាក់ព័ន្ធនៅក្នុងការត្រួតពិនិត្យ និងការគ្រប់គ្រងប្រចាំថ្ងៃលើការប្រើប្រាស់ប្រាក់របស់ពួកគេនៅក្នុងមុខរបររបស់សហគមន៍កសិកម្មឡើយ។ ហេតុដូច្នេះហើយ ត្រូវបោះឆ្នោតជ្រើសរើសសមាជិកមួយចំនួនដែលអាចជឿទុកចិត្តបានឱ្យធ្វើជាតំណាងរបស់ពួកគេ ដើម្បីគ្រប់គ្រងប្រាក់របស់ពួកគេឱ្យបានត្រឹមត្រូវ។

***[iv] សេវាកម្ម៖*** ច្បាប់ស្តីពីសហគមន៍កសិកម្ម ចែងយ៉ាងច្បាស់អំពីប្រតិបត្តិការមុខរបរប្រភេទណាខ្លះដែលត្រូវអនុវត្ត។ ជាទូទៅ សហគមន៍កសិកម្មមួយ គឺជាសហគមន៍កសិកម្មពហុគោលបំណងដែលធ្វើមុខងារផ្សេងៗដើម្បីបម្រើសមាជិក។

មុខងារជាមូលដ្ឋានរបស់សហគមន៍កសិកម្មទាក់ទិននឹងសមាជិករបស់ខ្លួន មានបួនដូចជា៖ [i] ឥណទាន [ii] ផ្គត់ផ្គង់ធាតុចូលកសិកម្ម [iii] ទីផ្សារផលិតផលរបស់សមាជិក និង[iv] សេវាកម្មណែនាំ និងប្រឹក្សាយោបល់ដល់សមាជិក។ សេវាទាំងនេះប្រសិនបើបម្រើបានល្អ នឹងធ្វើឱ្យសហគមន៍កសិកម្មទទួលបានជោគជ័យ។ ឥណទានគឺជាកត្តាសំខាន់បំផុតសម្រាប់សមាជិក ពីព្រោះពួកគេត្រូវការប្រាក់ដើម្បីអនុវត្ត មុខងារកសិកម្មខុសៗគ្នា។

ជាទូទៅ ឥណទានត្រូវបានផ្តល់ដោយសហគមន៍កសិកម្មដោយគិតអត្រាការប្រាក់ទាបសម្រាប់ប្រតិបត្តិការកសិកម្ម និងការប្រើប្រាស់ក្នុងរយៈពេលខ្លី ឬមធ្យម។ សហគមន៍កសិកម្មមួយ ប្រហែលជាមិនមានមូលនិធិផ្ទាល់ខ្លួនសម្រាប់បើកឱ្យសមាជិកទាំងអស់នៅពេលវេលាកំណត់ណាមួយឡើយ។ សហគមន៍កសិកម្មត្រូវខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុ (ឧទាហរណ៍ ធនាគារសហគមន៍) ដោយផ្អែកលើកម្លាំងនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល និងជាមួយដែនកំណត់ឥណទានដែលត្រូវបានបង្កើតឡើងសម្រាប់សមាជិក។ ជាទូទៅ អត្រាការប្រាក់ទាប និងសមរម្យ បើប្រៀបធៀបនឹងអត្រាការប្រាក់ក្នុងទីផ្សារបើកទូលាយ។

សហគមន៍កសិកម្មឱ្យប្រាក់ទៅសមាជិករបស់ខ្លួនខ្ចីជាថ្មីម្តងទៀត ដោយគិតអត្រាការប្រាក់សមរម្យ ដែលជាទូទៅជាមួយនឹងអប្បហារតិចតួច។ ជាទូទៅ ឥណទានសម្រាប់គោលបំណងកសិកម្មគឺទាបជាងអត្រាការប្រាក់នៅលើទីផ្សារបើកទូលាយនាពេលបច្ចុប្បន្ន។ សហគមន៍កសិកម្មមិនមែនធ្វើ

ប្រតិបត្តិការក្នុងនាមជាអ្នកចងការប្រាក់ ឬឈ្មួញកណ្ដាល ហើយគិតអត្រាការប្រាក់តាមទីផ្សារឡើយ។ ប្រសិនបើសហគមន៍កសិកម្មជាអ្នកចងការប្រាក់ គឺមិនចាំបាច់មានសហគមន៍កសិកម្មនោះទេ ពីព្រោះកសិករជាសមាជិក ក៏អាចខ្ចីប្រាក់ពីអ្នកចងការប្រាក់នៅខាងក្រៅបានដែរ។ សហគមន៍កសិកម្មមិនកេងចំណេញពីសមាជិកនោះទេ ពោល គឺសហគមន៍កសិកម្មត្រូវបានរៀបចំដើម្បីជួយដល់សមាជិករបស់ខ្លួន មិនមែនដើម្បីកេងចំណេញពីសមាជិកឡើយ។

នៅក្នុងករណីជាច្រើន រដ្ឋាភិបាលមានកម្មវិធីផ្តល់ប្រាក់កម្ចីសម្រាប់សហគមន៍កសិកម្មដោយមានគោលបំណងតែមួយគត់ គឺធ្វើឱ្យប្រសើរឡើងនូវផលិតកម្មកសិកម្ម និងដើម្បីផលប្រយោជន៍របស់សហគមន៍កសិកម្ម។ រដ្ឋាភិបាលមិនគិតអត្រាការប្រាក់តាមតម្លៃទីផ្សារទេ។

គួរតែមានការលើកឡើងថា នៅក្នុងប្រទេសជាច្រើន រដ្ឋាភិបាលផ្តល់ឥណទានដល់កសិករសម្រាប់អនុវត្តសកម្មភាពកសិកម្ម និងសម្រាប់ការចំណាយផ្សេងៗទៀតរបស់ពួកគេដែលមិនពាក់ព័ន្ធនឹងការធ្វើកសិកម្ម។ ឥណទានសម្រាប់សហគមន៍កសិកម្មនេះ ត្រូវបានផ្តល់ឱ្យក្នុងលក្ខខណ្ឌអនុគ្រោះ។ តាមការរំពឹងទុកថាសហគមន៍កសិកម្មនឹងផ្តល់ឥណទានដល់សមាជិកក្នុងលក្ខខណ្ឌអនុគ្រោះ។ នៅគ្រប់ទីកន្លែងក្នុងពិភពលោក និងនៅក្នុងប្រទេសមួយចំនួនធំ អត្រាការប្រាក់គឺទាបខ្លាំងណាស់។ ជាឧទាហរណ៍ ឥណទានកសិកម្មដែលផ្តល់ទៅឱ្យកសិករនៅក្នុងប្រទេសឥណ្ឌា គឺត្រឹមតែ ៦% ប៉ុណ្ណោះ (២% ក្នុងចំណោមនោះ រដ្ឋាភិបាលជាអ្នកចេញ ហើយការប្រាក់ដែលកសិករត្រូវបង់មានតែ ៤% ប៉ុណ្ណោះ)។

នៅរដ្ឋមួយចំនួនក្នុងប្រទេសឥណ្ឌា អត្រាការប្រាក់សម្រាប់ឥណទានកសិកម្មគឺ ០%។ គោលបំណងនេះ គឺដើម្បីផ្តល់សន្តិសុខដល់កសិករ និងដើម្បីបង្កើនផលិតកម្មកសិកម្ម។ នៅក្នុងពិភពលោកគ្មានកសិករណាអាចធ្វើប្រតិបត្តិការកសិកម្ម ដោយមិនទទួលបានអត្ថប្រយោជន៍ពីស្ថាប័នឥណទានឡើយ។ ហើយវាក៏មិនធ្លាប់មានដែរ ដែលសហគមន៍កសិកម្មគិតអត្រាការប្រាក់ដូចគ្នានឹងអត្រាអត្រាការប្រាក់នៅក្នុងទីផ្សារបើកទូលាយ។ គោលបំណងទាំងមូលនៃការផ្តល់ឥណទានដល់កសិករត្រូវបានបាត់បង់។ ឥណទានដែលផ្តល់ឱ្យសម្រាប់ការប្រើប្រាស់ ការសាងសង់ផ្ទះ ការទិញរបស់របរប្រើប្រាស់ក្នុងផ្ទះជាទូទៅមានអត្រាការប្រាក់ខ្ពស់ជាងនេះតិចតួច។ ក្នុងករណីខ្លះ សម្រាប់គោលបំណងទាំងនេះគេគិតអត្រាការប្រាក់ខ្ពស់ជាងឥណទានកសិកម្មប្រហែល ៥%។

សេវាកម្មផ្សេងៗទៀតដែលសហគមន៍កសិកម្មផ្តល់ឱ្យ គឺការផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្មដូចជាពូជ ជី គីមីកសិកម្ម ។ល។ ទាំងនេះគួរតែធ្វើឱ្យទាន់ពេលវេលាសម្រាប់សមាជិក។ ការធ្វើទីផ្សារសម្រាប់លក់ផលិតផលរបស់សមាជិក គឺជាសេវាកម្មដ៏សំខាន់មួយទៀត។ នៅក្នុងករណីជាច្រើន សហគមន៍កសិកម្មទិញផលិតផលរបស់សមាជិក និងលក់វាចេញទៅកាន់ទីផ្សារនៅដំណាក់កាលក្រោយ នៅពេលតម្លៃទីផ្សារឡើងខ្ពស់។ នៅក្នុងករណីខ្លះ សហគមន៍កសិកម្មផ្តល់ព័ត៌មានស្តីពីតម្លៃបច្ចុប្បន្នដែល

សមាជិកអាចលក់ផលិតផលរបស់ខ្លួនបាន និងត្រៀមរៀបចំទីភ្នាក់ងារកម្រៃជើងសាសម្រាប់សមាជិក។ សហគមន៍កសិកម្មក៏អាចអនុវត្តតម្លៃបន្ថែមដោយខ្លួនឯង ឬជួសមុខឱ្យសមាជិកបានផងដែរដើម្បីបង្កើនប្រាក់ចំណូល។

សេវាកម្មមួយទៀត គឺសេវាកម្មផ្តល់ការណែនាំ ឬផ្សព្វផ្សាយទៅសមាជិកដើម្បីគាំទ្រប្រតិបត្តិការកសិកម្មរបស់ពួកគេ។ សេវាកម្មទាំងនេះមានលក្ខណៈបច្ចេកទេស ដូច្នេះហើយសហគមន៍កសិកម្មត្រូវការការគាំទ្រពីស្ថាប័នជំនាញ ឧទាហរណ៍ដូចជានាយកដ្ឋានកសិកម្ម ឬសាកលវិទ្យាល័យកសិកម្មជាដើម ។ល។

ដើម្បីធ្វើឱ្យសមាជិកសប្បាយចិត្តចំពោះសហគមន៍កសិកម្ម និងដើម្បីជូនដំណឹងពួកគេអំពីសេវាកម្ម និងការពាក់ព័ន្ធរបស់សហគមន៍កសិកម្ម ចាំបាច់ត្រូវមានកម្មវិធីអប់រំសមាជិកដែលមានការរៀបចំបានល្អ និងអនុវត្តជាប្រចាំ។ ដើម្បីធ្វើឱ្យមានវិជ្ជាជីវៈ និងប្រសិទ្ធភាព បុគ្គលនៅក្នុងសហគមន៍កសិកម្មចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាល។ ដើម្បីពង្រីកការផ្តល់សេវា និងដើម្បីបញ្ចុះបញ្ចូលកសិករឱ្យចូលជាសមាជិកបន្ថែមទៀត សេវាកម្មផ្សព្វផ្សាយសម្រាប់ស្ត្រី និងយុវជន ក៏មានសារៈសំខាន់ដែលនឹងត្រូវអនុវត្តដែរ។

ការរួមបញ្ចូលគ្នានូវកត្តាទាំងនេះ នាំឱ្យសហគមន៍កសិកម្មទទួលបានជោគជ័យ។ ប្រសិនបើអនុវត្តមុខងារទាំងនេះបានល្អ និងត្រឹមត្រូវ សមាជិកនឹងបន្តរក្សាភាពស្មោះត្រង់របស់ពួកគេ ហើយធ្វើឱ្យទំនាក់ទំនងរបស់ពួកគេជាមួយសហគមន៍កសិកម្មប្រព្រឹត្តទៅយ៉ាងរលូន។

## លក្ខខណ្ឌសំខាន់ៗសម្រាប់បន្តភាពជោគជ័យរបស់សហគមន៍កសិកម្ម

មានលក្ខខណ្ឌមួយចំនួនដែលមានសារៈសំខាន់ ប្រសិនបើសហគម៍កសិកម្មមានគោលបំណងបន្តភាពជោគជ័យបន្ទាប់ពីការចាប់ផ្តើម។

- សហគមន៍កសិកម្មចាំបាច់ត្រូវបង្កើតឱ្យមានអត្ថប្រយោជន៍ជាក់ស្តែងនឹងភ្នែក (ផ្នែកសេដ្ឋកិច្ច និងសង្គម) សម្រាប់សមាជិកច្រើនជាងការចំណាយពាក់ព័ន្ធនៅក្នុងសហគមន៍កសិកម្ម។ សហគមន៍កសិកម្មអាចអភិវឌ្ឍខ្លួនទៅជាអង្គការស្វយ័តជួយខ្លួនឯងបាន នៅពេលពួកគេមានលទ្ធភាព និងទទួលបានការអនុញ្ញាតឱ្យដំណើរការស្ថាប័នអាជីវកម្ម ដែលត្រូវបានរៀបចំឡើងដើម្បីឱ្យទទួលបានជោគជ័យនៅក្នុងការប្រកួតប្រជែងក្នុងទីផ្សារ។
- សហគមន៍កសិកម្មបានជំរុញលើកទឹកចិត្តអ្នកគ្រប់គ្រងដែលមានបទពិសោធន៍ និងស្វាហាប់ដែលមានសមត្ថភាពអាចធ្វើផែនការ និងអនុវត្តគោលនយោបាយអាជីវកម្ម។ ពួកគេត្រូវមានសមត្ថភាព

អាចផ្តល់សេវាកម្ម និងទំនិញដែលសមាជិកត្រូវការ ដោយគិតគូរទាំងចំណាប់អារម្មណ៍ និងសេចក្តីត្រូវការរបស់សមាជិក ព្រមទាំងគោលបំណងសហគ្រិនភាពរបស់សហគ្រាសសហគមន៍កសិកម្មផងដែរ។

- រចនាសម្ព័ន្ធ និងការគ្រប់គ្រងអង្គភាពពាក់ព័ន្ធត្រូវទាក់ទងនឹងសមត្ថភាពរបស់សមាជិករបស់ខ្លួន។ ប្រសិនបើសមាជិកខ្វះសមត្ថភាព និងការលើកទឹកចិត្ត ការលើកកម្ពស់ដើម្បីបង្កើតសហគមន៍កសិកម្មដែលស្មុគស្មាញ និងសាំញ៉ាំ មិនអាចទៅរួចឡើយ។
- សមាជិកចូលរួមក្នុងនាមជាអ្នកប្រើប្រាស់ផង និងជាម្ចាស់ផង

សហគមន៍កសិកម្ម គឺជាអង្គភាពចូលរួមដែលជួយខ្លួនឯង ដែលក្នុងនោះសមាជិកក៏ជាសហកម្មសិទ្ធិដែរ និងមានទាំងសិទ្ធិ ទាំងកាតព្វកិច្ចចូលរួមនៅក្នុងការកំណត់គោលដៅ ការធ្វើសេចក្តីសម្រេចចិត្ត និងការគ្រប់គ្រង ឬការវាយតម្លៃដំណើរការរបស់សហគមន៍កសិកម្មពួកគេ។ សមាជិកធ្វើសេចក្តីសម្រេចលើសេវាកម្មដែលត្រូវផ្តល់ជូន និងអត្ថប្រយោជន៍ដែលសហគមន៍កសិកម្មបានបង្កើតឡើង ឬទទួលបាន។ វាគួរតែមានគ្រឿងលើកទឹកចិត្តសម្រាប់ពួកគេដែលរួមចំណែកផ្តល់ធនធានផ្ទាល់ខ្លួនរបស់ពួកគេ (ដើមទុន កម្លាំងពលកម្ម ផលិតផល) សម្រាប់ការអភិវឌ្ឍសហគមន៍កសិកម្ម។ មូលហេតុចម្បងសម្រាប់ការបរាជ័យរបស់សហគមន៍កសិកម្ម គឺកង្វះការចូលរួមពីសមាជិក។

មានការស្នើឡើងយ៉ាងមុតមាំឱ្យគ្រូបង្គោលមានគោលការណ៍សហការណ៍ ឈរលើមូលដ្ឋានតែមួយដូចចលនាសហគមន៍កសិកម្មពិភពលោក។ សមាជិកសហគមន៍កសិកម្ម មន្ត្រី និងគ្រូបង្គោលទាំងអស់ចាំបាច់ត្រូវដឹងពីគោលការណ៍ទាំងនេះ។

**សេចក្តីសន្និដ្ឋាន**

គ្រូបង្គោល មានសេរីភាពក្នុងការប្រើប្រាស់បទពិសោធន៍របស់សហគមន៍កសិកម្មដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ហើយពង្រឹងអំនះអំនាងរបស់ខ្លួនធ្វើយ៉ាងណាដើម្បីធ្វើឱ្យសមាជិក និងមន្ត្រីសហគមន៍កសិកម្មយល់ពីចំណុចលើកឡើងរបស់ពួកគេ។ មានសហគមន៍កសិកម្ម និងសហភាពកសិករដែលទទួលបានជោគជ័យមួយចំនួនក្នុងប្រទេស ហើយពួកគេមានហេតុផលរបស់ខ្លួនសម្រាប់ការទទួលបានជោគជ័យ។

---

# ជំពូកទី ២

# ការសោយតាយអំពីចលនាសហគមន៍កសិកម្ម

នៅទូទាំងសាកលលោក ពោលគឺនៅគ្រប់ប្រទេស និងខេត្ត និងសូម្បីនៅក្នុងស្ថាប័នសហគមន៍កសិកម្មភូមិ ត្រូវបានរកឃើញថាកំពុងតែដំណើរការ។ សហគមន៍កសិកម្មដំណើរការក្រោមប្រព័ន្ធនយោបាយ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចគ្រប់ប្រភេទដោយឈរលើគោលការណ៍ប្រជាធិបតេយ្យ និងអនុលោមតាមគោលការណ៍សម្ព័ន្ធសហគមន៍អន្តរជាតិដែលគេទទួលស្គាល់ជាសាកល។

រចនាសម្ព័ន្ធសហគមន៍កសិកម្មទូទាំងសាកលលោក អនុវត្តតាមគំរូមួយដែលស្ទើរតែស្រដៀងគ្នា។ កសិករជាសមាជិកនៅក្នុងសហគមន៍កសិកម្មធ្វើមហាសន្និបាតដែលបង្កើតឡើងនូវស្ថាប័នស្របច្បាប់មួយឱ្យឈ្មោះថាសហគមន៍កសិកម្មបឋម។ សហគមន៍កសិកម្មបឋមចូលរួមនៅក្នុងសហភាព ឬសហព័ន្ធសហគមន៍កសិកម្មថ្នាក់ស្រុក។ សហភាពថ្នាក់ស្រុកទាំងនេះដែលមានមុខងារផ្សព្វផ្សាយ និងមុខងារប្រកបមុខរបររួមគ្នាបង្កើតទៅជាមុខរបរថ្នាក់ខេត្ត ឬសហព័ន្ធ ឬសហភាពផ្សព្វផ្សាយថ្នាក់ខេត្ត។ សហព័ន្ធថ្នាក់ខេត្តបង្កើតសហព័ន្ធសហគមន៍កសិកម្មថ្នាក់ជាតិមួយ ដែលធ្វើទាំងមុខងារផ្សព្វផ្សាយ និងមុខរបរជូនសមុខសង្គមសមាជិករបស់ខ្លួន។

សហព័ន្ធ / សហភាពសហគមន៍កសិកម្មថ្នាក់ជាតិ ចូលរួមនៅក្នុងអង្គការសហគមន៍អន្តរជាតិមួយដែលឱ្យឈ្មោះថា សម្ព័ន្ធសហគមន៍អន្តរជាតិ (ICA)។ ICA ដែលជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយ ការពារគោលការណ៍សហគមន៍ និងធ្វើការផ្សព្វផ្សាយអំពីសកម្មភាពសហគមន៍កសិកម្មតាមរយៈការទំនាក់ទំនងជាមួយអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងៗទៀត រួមទាំងរដ្ឋាភិបាលនៃប្រទេសទាំងនោះផង។

នៅពេលបច្ចុប្បន្ន មានប្រទេសជាង ១០០ ក្នុងពិភពលោកដែលជាសមាជិករបស់ ICA ។ សហគមន៍ថ្នាក់ជាតិជិត ២០០ ដែលមានសមាជិកជាង ១,៣ ពាន់លាននាក់ ត្រូវបានតំណាងដោយ ICA។ ICA មានទីស្នាក់ការកណ្តាលនៅក្នុងទីក្រុងព្រុចសែល (បែលហ្ស៊ិក) និងមានការិយាល័យថ្នាក់តំបន់ចំនួនប្រាំនៅទូទាំងពិភពលោក។ ការិយាល័យថ្នាក់តំបន់សម្រាប់អាស៊ីប៉ាស៊ីហ្វិក ស្ថិតនៅក្នុងប្រទេសឥណ្ឌា។

រដ្ឋាភិបាលមិនមែនជាសមាជិករបស់ ICA ទេ។ មានតែសហគមន៍ថ្នាក់ជាតិ និងថ្នាក់ខេត្តប៉ុណ្ណោះដែលអាចធ្វើជាសមាជិករបស់ ICA បាន។

ចលនាសហគមន៍កសិកម្មនៃកម្ពុជា គឺជាផ្នែកមួយរបស់ចលនាសហគមន៍កសិកម្មអន្តរជាតិតែទោះជាយ៉ាងណា វាមិនទាន់ក្លាយជាសមាជិករបស់ ICA នៅឡើយទេ។

---

# ជំពូកទី ៣
# ប្រវត្តិរបស់ចលនាសហគមន៍កសិកម្ម

កិច្ចសហការណ៍ គឺជាសកម្មភាពរបស់មនុស្ស។ វាជាសកម្មភាពដែលត្រូវបានបង្កើតឡើងដោយខ្លួនឯង ដោយស្ម័គ្រចិត្ត និងឯករាជ្យ។ កិច្ចសហការណ៍ គឺជាលក្ខណៈពិសេសរបស់មនុស្សជាតិ។ ជាសំខាន់ កិច្ចសហការណ៍ គឺជាសកម្មភាពរបស់មនុស្សសម្រាប់ការជួយគ្នាទៅវិញទៅមក និងការរីកចម្រើនជាសម្ភហភាព។ សហគមន៍កសិកម្មបង្កើតស្ថាប័នអាជីវកម្មដែលមានប្រភពដើមកំណើតនៅក្នុងប្រទេសអង់គ្លេស ក្នុងចំណោមកម្មករឧស្សាហកម្មនៅពាក់កណ្តាលសតវត្សរ៍ទី ១៩។ ដំបូងឡើយសហគមន៍កសិកម្មបានចាប់ផ្តើមជាហាងលក់ទំនិញប្រើប្រាស់នៅតាមទីប្រជុំជន ប៉ុន្តែមិនយូរប៉ុន្មានរីករាលដាលទៅដល់តំបន់ជនបទក្នុងចំណោមកសិករ។

ការលេចចេញជារូបរាងនូវចលនាសហគមន៍កសិកម្មពិតប្រាកដ អាចកើតឡើងដោយសារតែក្រុមអ្នកត្រួសត្រាយផ្លូវរ៉ចដេល (Rochdale Pioneer) ដែលបានបង្កើតហាងសហគមន៍អ្នកប្រើប្រាស់ក្នុងប្រទេសអង់គ្លេសភាគខាងជើង ដែលអាចទុកបានជាហាងទី១ នៅក្នុងចលនាសហគមន៍អ្នកប្រើប្រាស់។ នៅក្នុងចក្រភពអង់គ្លេស លោក រ៉ូបឺត អូវិន (Robert Owen) (ឆ្នាំ១៧៧១-១៨៥៨) បានបង្កើតឡើងនូវសហគមន៍ឯករាជ្យ ពាក់កណ្តាលកសិឧស្សាហកម្ម និងពាក់កណ្តាលឧស្សាហកម្ម។ លោកប្រាកដក្នុងចិត្តថា អ្នកធ្វើការដែលទទួលបានសិទ្ធិ ប្រហែលជានឹងបង្កើតសហគមន៍កសិកម្ម។ លោកបានបញ្ចូលវាទៅក្នុងការអនុវត្តនៅភូមិញូវ ឡាណាក (New Lanark) ប្រទេសស្កុតឡែន ជាកន្លែងដំណើរការអាជីវកម្មផ្ទាល់ខ្លួនរបស់លោក។

## ចក្រភពអង់គ្លេស

ចលនាសហគមន៍កសិកម្មបានចាប់ផ្តើមនៅអឺរ៉ុប ក្នុងសតវត្សរ៍ទី១៩ ជាពិសេសនៅក្នុងប្រទេសអង់គ្លេស និងប្រទេសបារាំង។ ត្រឹមឆ្នាំ១៨៣០ មានសហគមន៍រាប់រយ។ សហគមន៍ខ្លះបានទទួលជោគជ័យកាលពីដំបូង ប៉ុន្តែសហគមន៍ភាគច្រើនដែលបង្កើតនៅដើមសតវត្សរ៍ទី១៩ បានបរាជ័យត្រឹមឆ្នាំ១៨៤០។ វាមិនទទួលបានជោគជ័យរហូតដល់ឆ្នាំ១៨៤៤ ជាពេលដែល *ក្រុមអ្នកត្រួសត្រាយផ្លូវប្រកបដោយសមធម៌ក្នុងសង្គមរ៉ចដេល (Rodale Society of Equitable Pionneers)* បានបង្កើត 'គោលការណ៍រ៉ចដេល' ស្តីពីការគ្រប់គ្រងសហគមន៍របស់ពួកគេ ដែលមូលដ្ឋានសម្រាប់ការអភិវឌ្ឍ និង កំណើននៃចលនាសហគមន៍សម័យទំនើបត្រូវបានបង្កើតឡើង។

លោក រ៉ូបឺត អូវិន (ឆ្នាំ១៧៧១-១៨៥៨) ត្រូវបានគេចាត់ទុកជាបិតាចលនាសហគមន៍។ លោកជឿជាក់ ការដាក់កម្មកររបស់លោកនៅក្នុងបរិយាកាសល្អដែលអាចទទួលបានការអប់រំសម្រាប់ពួកគេ និងកូនៗរបស់ពួកគេ គឺជារឿងល្អ។ គំនិតទាំងនេះត្រូវបានដាក់ឱ្យអនុវត្តដោយជោគជ័យក្នុងរោងចក្រកែច្នៃកប្បាសនៅភូមិញូវ ឡាណាក ប្រទេសស្កុតលែន។ នៅទីនេះឯងដែលហាងសហគមន៍ទី១ បានបើកដំណើរការ។

***វីលៀម យីង៖*** ទោះបីជាលោក រ៉ូបឺត អូវិន បានជំរុញចលនាសហគមន៍ក្តី ក៏អ្នកផ្សេងទៀតៗដូចជាបណ្ឌិត វីលៀម យីង (William King) (១៧៨៦-១៨៦៥) ជាដើម បានទទួលយកគំនិតរបស់លោក និងអភិវឌ្ឍគំនិតទាំងនោះឱ្យកាន់តែជាក់ស្តែង។ លោកវីលៀម យីង ជឿលើការចាប់ផ្តើមពីតូច ហើយការធ្វើឱ្យវាសម្រេចជោគជ័យ ចាំបាច់ត្រូវបង្កើតសហគមន៍សម្រាប់ខ្លួនពួកគេ ដូច្នេះហើយលោកក៏បានសម្លឹងឃើញតួនាទីរបស់លោកជាគ្រូឧទ្ទេស។ លោក វីលៀម យីង បានផ្តល់ដំបូន្មានដល់មនុស្សកុំឱ្យផ្តាច់ខ្លួនចេញពីសង្គម ពោលគឺឱ្យពួកគេបង្កើតសង្គមមួយនៅក្នុងសង្គមមួយ ហើយចាប់ផ្តើមជាមួយនឹងការបើកហាង ពីព្រោះ "យើងត្រូវចូលហាងរាល់ថ្ងៃដើម្បីទិញម្ហូបអាហារ និងរបស់របរដែលចាំបាច់ អ៊ីចឹងសួរថា ហេតុអ្វីបានជាយើងមិនគួរទៅហាងផ្ទាល់ខ្លួនរបស់យើង?" លោកបានស្នើឱ្យមានវិធានសមរម្យដូចជាការធ្វើសវនកម្មគណនីប្រចាំសប្តាហ៍ ឱ្យមានអ្នកគ្រប់គ្រងទ្រព្យសម្បត្តិចំនួនបីនាក់ និងកុំមានកិច្ចប្រជុំតាមហាងស្រា។

***ក្រុមអ្នកត្រួសត្រាយផ្លូវរ៉ចដេល៖*** ក្រុមអ្នកត្រួសត្រាយផ្លូវប្រកបដោយសមធម៌នៃសង្គមរ៉ចដេលគឺជាក្រុមមួយដែលមានជាងតម្បាញចំនួន ១០ នាក់ និង ២០ នាក់ទៀតនៅទីប្រជុំជនផ្សាររ៉ចដេល (Rochdale) ដ៏ធំនៅក្នុងប្រទេសអង់គ្លេស ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៨៤៤។ នៅពេលការធ្វើយន្តកម្មបដិវត្តន៍ឧស្សាហកម្ម មានការបង្ខិតបង្ខំកាន់តែខ្លាំង និងធ្វើឱ្យកម្មករជំនាញកាន់តែច្រើនធ្លាក់ចូលក្នុងភាពក្រីក្រ ពាណិជ្ជករទាំងនេះបានសម្រេចចិត្តរួមសហការគ្នាបើកហាងផ្ទាល់ខ្លួនលក់គ្រឿងឧបភោគបរិភោគ ដែលពួកគេគ្មានលទ្ធភាពទិញ។ ដោយមានមេរៀនទទួលបានពីការព្យាយាមលើកមុនតែបរាជ័យ ពួកគេក៏បានរៀបចំតាក់តែងគោលការណ៍ណែនាំរ៉ចដេល ដែលមានឈ្មោះល្បីល្បាញដល់សព្វថ្ងៃ ហើយក្នុងរយៈពេលបួនខែ ពួកគេបានខិតខំប្រមូលប្រាក់មូលនិធិមួយផោនក្នុងមនុស្សម្នាក់ឱ្យក្លាយទៅជាទុនសរុប ២៨ ផោន ។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៨៤៤ ពួកគេបានបើកហាងរបស់ខ្លួនដែលផ្តល់នូវជម្រើសតិចតួចក្នុងនោះរួមមានទាំងតែ និងថ្នាំជក់ផង ហើយមិនយូរប៉ុន្មាន ពួកគេក៏មានឈ្មោះល្បីល្បាញខាងផ្តល់ទំនិញដែលមានគុណភាពខ្ពស់ មិនត្រឹមតែទិញសម្រាប់សមាជិករបស់ខ្លួននោះទេ ពោលគឺអ្នកផ្សេងក៏ទទួលបានទំនិញល្អដូចគ្នាដែរ។

## អាល្លឺម៉ង់

ប្រទេសអាល្លឺម៉ង់ គឺជាកន្លែងកំណើតនៃចលនាឥណទានសហគមន៍ក្នុងពិភពលោក។ បន្ទាប់ពីជាតិរលំរលាយ និងការបរាជ័យរបស់អាល្លឺម៉ង់ នៅក្នុងឆ្នាំ១៩៤៥ ជាពេលដែលប្រទេសនេះត្រូវបានបែងចែកជាសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (German Democratic Republic) និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (Federal Republic of Germany) សហគមន៍ផលិតកសិកម្មផ្លូវការត្រូវបានបង្កើតឡើងយកគំរូតាមកសិដ្ឋានសមូហភាពក្នុងប្រទេសរុស្ស៊ី។ ក្រោយមក ចលនាសហគមន៍ បានអភិវឌ្ឍខ្លួនទៅជាក្រុមខុសគ្នាចំនួនបួនដូចជា [i] សង្គមជនបទ [ii] សង្គមសហគមន៍ទីប្រជុំជនដែលត្រូវបានបង្កើតឡើងនៅតាមតំបន់ប្រជុំជន ប្រភេទសហគមន៍ Schulze ដែលត្រូវបានអភិវឌ្ឍដោយមានសមាជិកភាពជាអ្នកលក់រាយ ម្ចាស់ភោជនីយដ្ឋាន វេជ្ជបណ្ឌិត ឱសថការី និងអ្នកផ្សេងៗទៀត។ ការរៀបចំម្ចាស់ហាងលក់រាយទៅជាសហគមន៍អ្នកលក់ដុំ គឺជាផ្នែកដ៏សំខាន់មួយរបស់អាល្លឺម៉ង់ ខាងលិច។ ទាំងប្រភេទសង្គម Raiffeisen និងសង្គម Schulze សុទ្ធតែបានផ្តល់គ្រប់សេវាទាំងអស់ដែលបណ្តាធនាគារពាណិជ្ជកម្មផ្តល់ឱ្យ។ ការសន្សំសំចៃ ត្រូវបានជំរុញលើកទឹកចិត្តក្នុងចំណោមសមាជិកតាមរយៈការផ្តល់ប្រាក់បញ្ញើប្រភេទផ្សេងៗដូចជា ការសន្សំរយៈពេលវែង ការសន្សំលើឆ្នោត ការសន្សំ lottery savings, thrift messenger and club savings [iii] សង្គមសហគមន៍ផ្តល់ជម្រក- សង្គមទាំងនេះបានសាងសង់ផ្ទះឱ្យសមាជិកដែលមានហិរញ្ញវត្ថុប្រមូលបានពីសមាជិក ព្រមទាំងបានពីរដ្ឋាភិបាលផងដែរ ហើយ [iv] គឺសង្គមសហគមន៍អ្នកប្រើប្រាស់។

## ជប៉ុន

*ប្រភពដើមនៃសហគមន៍ជប៉ុន៖* ប្រភពដើមនៃសហគមន៍នៅក្នុងប្រទេសជប៉ុន កើតចេញពីសហភាពឥណទានដូចជា "ហូតុគុសា (Hohtoku-sha)" ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៤៣ ដោយសកម្មជនកសិករ ក្នុងនោះរួមមានទាំង សុនតុគុនីណូមីយ៉ា (SontokuNinomiya) ផង។ សហភាពឥណទានទាំងនេះតំណាងឱ្យស្មារតីនៃការជួយគ្នាទៅវិញទៅមក នៅពេលមួយដែលពុំមានអង្គការសហគមន៍ផ្លូវការ។

នៅក្នុងឆ្នាំ១៨៦៨ ប្រទេសជប៉ុន បានធ្វើការកែប្រែយ៉ាងខ្លាំង។ ក្រោយប្រកាន់យកគោលនយោបាយឯកោនិយមអស់រយៈពេល ៣០០ ឆ្នាំ ប្រទេសជប៉ុន បានបើកទ្វាររបស់ខ្លួនដើម្បីចូលរួមជាមួយប្រទេសជាគ្រួសារក្នុងពិភពលោក។ ក្នុងពេលជាមួយគ្នានោះ ជប៉ុន បានចាប់ផ្តើមការធ្វើទំនើបកម្ម និងឧស្សាហូបនីយកម្ម។ កត្តានេះបាននាំទៅដល់ស្ថានភាពមួយដែលអ្នកផលិតទ្រង់ទ្រាយតូចរហូតមកបង្ខំចិត្តប្រកួតប្រជែងជាមួយសហគ្រាសថ្មីៗ និងដែលមានដើមទុនច្រើន ដោយបង្កើតឱ្យមានតម្រូវការជាបន្ទាន់នូវការរៀបចំសហគមន៍ ដែលនឹងនាំសេដ្ឋកិច្ចដល់ដៃប្រតិបត្តិករទ្រង់ទ្រាយតូច។

សហាគមន៍ទំនើបទី១ របស់ប្រទេសជប៉ុន គឺសហាភាពលក់ដែលត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលពាណិជ្ជកម្មសហាគមន៍។ ចន្លោះចុងទសវត្សរ៍ឆ្នាំ១៨៧០ ដល់ចុងទសវត្សរ៍ឆ្នាំ១៨៩០ អ្នកផលិតសូត្រ និងតែ បានបង្កើតសហាគមន៍នៅតំបន់រដ្ឋបាលមូលដ្ឋានហ្គុនម៉ា (Gunma) និងស៊ីហ្សូកា (Shizuoka) ដែលជាតំបន់ផលិតសូត្រ និងតែដ៏សំខាន់។ រដ្ឋាភិបាលយល់ថា វាចាំបាច់ខ្លាំងណាស់ក្នុងលើកកម្ពស់ការបង្កើតសហាគមន៍ដើម្បីការអភិវឌ្ឍឧស្សាហកម្ម និងជួយដល់អ្នកផលិតទ្រង់ទ្រាយតូច។ បន្ទាប់ពីមានស្ថានការណ៍ស្មុគ្រស្មាញជាច្រើនតាមរយៈកិច្ចប្រឹងប្រែងរបស់ យ៉ាជីរ៉ុ ស៊ីណាហ្គាវ៉ា (Yajiro Shinagawa) និង តូស៊ូកេ ហ៊ីរ៉ាតា (Tosuke Hirata) និងអ្នកជាច្រើនទៀត ច្បាប់ស្តីពីសង្គមសហាគមន៍ក៏ត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩០០ ឈានទៅដល់ការបង្កើតសហាគមន៍ [សាងយ៉ូ គូមីអៃ (Sangyo Kumiai] នៅទូទាំងប្រទេស។ ច្បាប់នេះបានអនុញ្ញាតឱ្យមានសហាគមន៍ប្រាំប្រភេទដូចជា ឥណទាន ទីផ្សារ ការទិញ ការប្រើប្រាស់utilization [ការផលិត] និង usage ការប្រើប្រាស់។

មិនយូរប៉ុន្មាន បណ្តាមេដឹកនាំសហាគមន៍ដែលមានគោលបំណងតែមួយទាំងនេះបានដឹងថា សកម្មភាពទិញ និងសកម្មភាពផ្សេងៗទៀត តម្រូវឱ្យមានការគាំទ្រខ្លាំងផ្នែកហិរញ្ញវត្ថុ។ ជាលទ្ធផលរដ្ឋាភិបាលបានធ្វើវិសោធនកម្មច្បាប់នេះ ដើម្បីអនុញ្ញាតឱ្យសហាគមន៍ឥណានទានធ្វើសកម្មភាពពាណិជ្ជកម្មផ្សេងៗទៀត។ សហាគមន៍ដែលមានគោលបំណងច្រើននាពេលបច្ចុប្បន្នរបស់ប្រទេសជប៉ុន បានលូតលាស់ហួសពីការអភិវឌ្ឍនេះ។ ហើយក្រោយពីសហាគមន៍បឋមមានការអភិវឌ្ឍតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីសង្គមសហាគមន៍នៅក្នុងឆ្នាំ១៩០៩ និង១៩១០ រួចមក សហព័ន្ធនៅថ្នាក់តំបន់រដ្ឋបាលមូលដ្ឋាន ត្រូវបានចាប់ផ្តើមឡើង។ បន្ថែមពីលើនេះ សហាភាពកណ្តាលនៃសហាគមន៍ [សាងយ៉ូ គូមីអៃជូកៃ (Sangyo Kumiai Chuokai) ] ត្រូវបានបង្កើតឡើងដើម្បីចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយអំពីចលនាសហាគមន៍នៅទូទាំងប្រទេស។

## ឥណ្ឌា

ចលនាសហាគមន៍ឥណ្ឌាត្រូវបានបង្កើតឡើង ក្នុងគោលបំណងប្រឆាំងទៅនឹងការកេងប្រវ័ញ្ចពីសំណាក់អ្នកផ្តល់ប្រាក់កម្ចីដែលមិនស្មោះត្រង់ ដើម្បីធ្វើឱ្យសហាគមន៍រួចផុតពីភាពក្រីក្រ និងការជំពាក់បំណុល។ រដ្ឋាភិបាលបានចាត់វិធានការជាច្រើនដើម្បីកែលម្អលក្ខខណ្ឌនៃវិស័យកសិកម្ម និងបានលើកកម្ពស់សង្គមឥណទានសហាគមន៍ដែលធ្វើឡើងទៅតាមការយល់ដឹងអំពីគំរូសង្គមឥណទាន Raiffeisen អំពីគោលគំនិតនៃអនុសាសន៍របស់ លោកSir Fredrick Nicholson ឆ្នាំ១៨៨៩។

ចលនាសហាគមន៍សព្វថ្ងៃនៅក្នុងប្រទេសឥណ្ឌា ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលចក្រភពអង់គ្លេសនៅឆ្នាំ ១៩០៤។ ក្រោយទទួលបានឯករាជ្យនៅឆ្នាំ ១៩៤៧ ចលនាសហាគមន៍បានក្លាយជាផ្នែក

មួយនៃផែនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងត្រូវបានលើកកម្ពស់ដើម្បីរៀបចំកសិករ និងកសាងស្បៀងបម្រុងទុក និងគ្រប់គ្រងតម្លៃផលិតផលកសិកម្ម។ សកម្មភាពសំខាន់របស់សហាគមន៍នោះ ដើម្បីផល់ឥណទានកសិកម្ម។ បច្ចុប្បន្នចលនាសហាគមន៍កសិករឥណ្ឌា គឺជាសហាគមន៍កសិករដែលធំបំផុតនៅក្នុងពិភពលោក។

## ការពិនិត្យឡើងវិញចលនាសហាគមន៍កសិកម្មពិភពលោក

នាពេលកន្លងទៅនេះ សម្ព័ន្ធសហាគមន៍អន្តរជាតិ (ICA) បានធ្វើការស្រាវជ្រាវមួយអំពីស្ថានភាពរបស់សហាគមន៍កសិកម្ម និងបានចូលរួមដោយសហាគមន៍កសិកម្មធំៗចំនួន ៣០០ នៅក្នុងពិភពលោក។ លទ្ធផលចុងក្រោយនៃការសិក្សានេះ គឺមានអត្ថប្រយោជន៍ចំពោះចលនាសហាគមន៍កសិកម្មដែលបង្ហាញថាសហាគមន៍កសិកម្ម គឺជាកម្លាំងដ៏សំខាន់សម្រាប់ទំនាក់ទំនងនៅតាមមូលដ្ឋាន និងមុខរបរ។ សង្ខេបទិន្នន័យនៃការសិក្សាមានដូចខាងក្រោម៖

ទិន្នន័យដែលប្រមូល បានផ្ដល់ជាប្រយោជន៍ក្នុងការកំណត់វិស័យមួយចំនួនសម្រាប់លទ្ធភាពកិច្ចប្រតិបត្តិការ និងជំនួយបច្ចេកទេស។ សម្រង់ទិន្នន័យសំខាន់ៗនៃការសិក្សាមានដូចខាងក្រោម៖

មានប្រាក់ចំណូលសរុបលើសពី១ពាន់កោដិដុល្លារអាមេរិក
មានសេដ្ឋកិច្ចធំបំផុតទី ១០ នៅក្នុងពិភពលោក
មានអត្រាកំណើន ១៤%
សហាគមន៍ចំនួន ២០% នៃការសិក្សាគឺនៅក្នុងសហរដ្ឋអាមេរិក
សហាគមន៍ចំនួន ៥០% នៃការសិក្សាមកពីប្រទេសអាមេរិក បារាំង អាល្លឺម៉ង់ និងអ៊ីតាលី
សហាគមន៍ចំនួន ៣០% នៃការសិក្សាស្ថិតនៅក្នុងវិស័យកសិកម្ម និងស្បៀង
សហាគមន៍ចំនួន ២៣% នៅក្នុងវិស័យលក់រាយ ២២% នៅក្នុងវិស័យធានារ៉ាប់រង និង ១៩% នៅក្នុងវិស័យធនាគារ
មានការងារចំនួន ២០% ច្រើនជាង MNCs ទាំងអស់រួមបញ្ចូលគ្នា (ការងារ ១០០ លាន កន្លែង)
ជនជាតិអាមេរិក ៤០% ជាសមាជិកសហាគមន៍
៤៥% នៃអាជីវកម្មសហាគមន៍នៃ GDP ប្រទេសកេនយ៉ា
៦៦% នៃសម្ភារថែទាំមនុស្សចាស់ និងកុមារនៅប្រទេសស្វីសគឺផលិតដោយសហគ្រាសសហាគមន៍
៩០% នៃអាជីវកម្មលក់រាយនៅក្នុងប្រទេសស្វីសគឺជាសហគ្រាសសហាគមន៍
ធនាគារសាជីវកម្មធំបំផុតរបស់ពិភពលោកគឺនៅក្នុងប្រទេសបារាំង។

ការសិក្សាកំណត់បានវិស័យសេដ្ឋកិច្ចធំៗចំនួនបីដែលបង្កើតប្រាក់កាស ការងារធ្វើ និងការធានា

រ៉ាប់រងសង្គម៖ [០១] វិស័យកសិកម្ម [តំណាងឱ្យច្រើនជាងមួយភាគបីនៃអាជីវកម្ម]។ [០២] ស្ថាប័នហិរញ្ញវត្ថុ (ធានារ៉ាប់រង ធនាគារ សហព័ន្ធផ្តល់ឥណទាន និងពិពិធកម្មស្ថាប័នហិរញ្ញវត្ថុ។ ដោយគិតទៅលើទ្រព្យសកម្ម ស្ថាប័នហិរញ្ញវត្ថុមានទ្រព្យសកម្មច្រើនជាងគេបង្អស់។ ជិតមួយភាគបីនៃសហាគមន៍ធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងមានទីតាំងនៅក្នុងប្រទេសបារាំង និងចក្រភពអង់គ្លេស។ និង [០៣] ក្រុមហ៊ុនលក់រាយ និងបោះដុំ [តំណាងឱ្យសហាគមន៍អ្នកប្រើប្រាស់ដែលមានកេរ្តិ៍ឈ្មោះនៅក្នុងប្រទេសផ្សេងៗ ដូចជាចក្រភពអង់គ្លេស ប្រទេសអ៊ីតាលី ប្រទេសក្នុងទ្វីបអឺរ៉ុប ប្រទេសជប៉ុន និងអាមេរិកខាងជើង)។

# ជំពូកទី ០៤
# សម្ព័ន្ធសហគមន៍អន្តរជាតិ [ICA]
# និង គោលការណ៍គ្រឹះសហគមន៍

ពាក្យថា "សហករណ៍" ដែលជាភាសាអង់គ្លេសថា "Cooperative" មានប្រវត្តិល្វីងជូរចត់ចំពោះប្រជាជនក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ដោយសារវា គឺជាសហករណ៍ក្លែងក្លាយ ដូចនេះហើយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានណែនាំឲ្យប្រើពាក្យថា "សហគមន៍" ជំនួសវិញ។ ដូចនេះពាក្យថា "សហគមន៍" ដែលប្រើក្នុងគោលការណ៍ណែនាំនេះ និងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម គឺមានន័យដូច "សហករណ៍" និងភាសាអង់គ្លេស "Cooperative"។

**[ក] សម្ព័ន្ធសហគមន៍អន្តរជាតិ [International Cooperative Alliance (ICA)]**

សម្ព័ន្ធសហគមន៍អន្តរជាតិត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៩ ខែសីហា ឆ្នាំ១៨៩៥ នៅក្នុងទីក្រុងឡុងដ៍។ សម្ព័ន្ធសហគមន៍អន្តរជាតិ [ICA] គឺជាស្ថាប័នឯករាជ្យអន្តរជាតិមិនមែនរដ្ឋាភិបាលដែលរួបរួមគ្នា តំណាងឱ្យសហគមន៍ និងបម្រើសហគមន៍ទាំងអស់នៅជុំវិញពិភពលោក។ សម្ព័ន្ធសហគមន៍អន្តរជាតិ គឺជាស្ថាប័នសហគមន៍មិនមែនរដ្ឋាភិបាលធំជាងគេបំផុតនៅក្នុងពិភពលោក។ សមាជិក ICA គឺជា សហគមន៍ជាតិ និងអន្តរជាតិនៅគ្រប់វិស័យទាំងអស់នៃសកម្មភាព។ នាពេលបច្ចុប្បន្ននេះ ICA មានសហគមន៍ជាសមាជិកចំនួន ២៤០ដែលមកពីប្រទេសចំនួន ១០០ ដែលតំណាងឱ្យសមាជិកសហគមន៍នីមួយៗ ចំនួន ១,៣ ពាន់លាន នាក់នៅជុំវិញពិភពលោក។ ICA គឺជាស្ថាប័នដែលមានមជ្ឈការ និងដឹកនាំដោយសមាជិករបស់ខ្លួនតាមបែបប្រជាធិបតេយ្យ។

**ទស្សនៈចំណងសំខាន់ៗរបស់ ICA៖** ICA បង្កើតឡើងដើម្បីលើកកម្ពស់ និងការពារអត្តសញ្ញាណសហគមន៍ ធានាថាសហគ្រាសសហគមន៍ គឺជាសហគ្រាសមួយដែលមានការទទួលស្គាល់។ លើកកម្ពស់ការយល់ដឹងអំពីសហគមន៍។ ធានាថាមានគោលនយោបាយត្រឹមត្រូវដែលធានាថាសហគមន៍នឹងរីកចម្រើន និងមានវិបុលភាព។ ផ្តល់ឱ្យសមាជិករបស់ខ្លួននូវព័ត៌មានសំខាន់ៗ ការអនុវត្តល្អៗ និងមធ្យោបាយទំនាក់ទំនង តាមរយៈការចុះផ្សាយអត្ថបទ និងសកម្មភាព PR។ សម្របសម្រួលដល់ការទំនាក់ទំនងគ្នារវាងសហគមន៍សម្រាប់ការដោះដូរពាណិជ្ជកម្ម និងព័ត៌មានសម្ងាត់អំពីទីផ្សារ។ ផ្តល់នូវជំនួយបច្ចេកទេសដល់សហគមន៍។ លើកកម្ពស់ការកសាងសមត្ថភាពនិងការគាំទ្រថវិកា។

**ក្រុមប្រឹក្សាភិបាល ICA៖** គឺទាក់ទងនឹងការអនុវត្ត និងនីតិវិធីដែលត្រូវបានប្រើប្រាស់ដោយស្ថាប័នមួយ ដើម្បីធានាថា ICA អាចសម្រេចបានវត្ថុបំណងរបស់ខ្លួន។ ICA អនុវត្តនូវសេចក្តីសម្រេចគោលនយោបាយទាំងអស់ដែលធ្វើឡើងនៅអង្គសមាជ។ ក្រុមប្រឹក្សាភិបាល ICA រួមមានប្រធាន ០១ រូប អនុប្រធាន ០៤ រូប និងសមាជិកចំនួន ១៨ រូប។

**សមាជ ICA៖** គឺជាស្ថាប័នធ្វើគោលនយោបាយកំពូលរបស់ ICA ដែលតំណាងឱ្យស្ថាប័នជាសមាជិក រៀងរាល់ពីរឆ្នាំម្តង។ អង្គសមាជបង្កើត និងអនុវត្តគោលនយោបាយបញ្ហាសំខាន់ៗមួយចំនួន។ ជ្រើសរើសប្រធាន ICA និងសមាជិកក្រុមប្រឹក្សាភិបាល។ ផ្តល់សច្ចាប័ននៃការបោះឆ្នោតអនុប្រធាន និងជ្រើសរើសអ្នកតំណាងស្ថាប័នវិស័យ និងយុវជននៅក្នុងក្រុមប្រឹក្សាភិបាល។

**រចនាសម្ព័ន្ធស្ថាប័ន៖** [i] បច្ចុប្បន្ននេះ ស្ថាប័ន ICA មានមូលដ្ឋាននៅទ្វីបអឺរ៉ុប។ ការិយាល័យតំបន់ទាំងបួនមានតួនាទីជាស្ថាប័នបច្ចេកទេសជួយដល់ស្ថាប័នICA ។ ស្ថាប័ន ICA-AP គឺជាស្ថាប័នចំណាស់បំផុតក្នុងចំណោមស្ថាប័នទាំងបួន។ [ii]ស្ថាប័នវិស័យផ្សេងៗ៖ ICA មានស្ថាប័នវិស័យចំនួន ០៨ ដែលចងក្រងក្រុមថ្មី ស្ថាប័នជាសមាជិកICAមានផលប្រយោជន៍។ [iii] http://www.ica.coop/ica/structure.htmlICA មានគណៈកម្មាធិការធំៗចំនួនបួនដែលអនុញ្ញាតឱ្យសមាជិក ICA ផ្តោតទៅលើបញ្ហានៃការស្រាវជ្រាវសហគមន៍ ទំនាក់ទំនង ការអភិវឌ្ឍធនធានមនុស្ស និងសមធម៌យេនឌ័រ។ គណៈកម្មាធិការត្រូវបានដឹកនាំតាមបែបប្រជាធិបតេយ្យដោយសមាជិករបស់សហគមន៍ និងផ្តល់ហិរញ្ញប្បទាន និងគាំទ្រដោយ ICA។

**សកម្មភាព ICA៖** អទិភាព និងសកម្មភាពចម្បងរបស់ ICA គឺផ្តោតទៅលើការលើកកម្ពស់ និងការការពារអត្តសញ្ញាណសហគមន៍ ដោយធានាថាសហគ្រាសសហគមន៍ គឺជាសហគ្រាសដែលត្រូវបានទទួលស្គាល់ថាអាចប្រកួតប្រជែងនៅក្នុងទីផ្សារបាន។ **[i] ICA លើកកម្ពស់ការយល់ដឹងអំពីសហគមន៍។ [ii] ICA គឺជាសំឡេងចលនាសហគមន៍។ [iii] ICA ផ្តល់ឱ្យសមាជិករបស់ខ្លួននូវព័ត៌មានបុគ្គលសំខាន់ៗសម្រាប់ទាក់ទង និងព័ត៌មានអំពីការអនុវត្តដែលប្រសើរបំផុត។ [iv] ICA ផ្តល់នូវជំនួយបច្ចេកទេសដល់សហគមន៍** តាមរយៈកម្មវិធីអភិវឌ្ឍន៍របស់ខ្លួននៅថ្នាក់តំបន់ និងសាកល។

**ការបោះពុម្ពផ្សាយអំពីសហគមន៍៖** ឯកសារទាំងនេះផ្តល់នូវឯកសារផ្សេងៗជាច្រើនពីការិយាល័យកណ្តាល និងការិយាល័យតំបន់ និងពីស្ថាប័នតាមវិស័យរបស់ខ្លួនដល់សមាជិករបស់ខ្លួន និងសម្រាប់សាធារណជនទូទៅ។

**សមាជិកភាព វិធាន និងបទបញ្ញត្តិ ICA៖** សមាជិកភាព ICA បើកចំហសម្រាប់ស្ថាប័នដែលអនុវត្តតាមវិធានអត្តសញ្ញាណសហគមន៍ICA [ICIS] និងគោរពតាមគោលបំណងរបស់សម្ព័ន្ធសហគមន៍។ សមាជិកភាពរបស់ ICA ចែកចេញជាពីរផ្នែក៖ [ក] សមាជិកពេញសិទ្ធិជាមួយនឹងសិទ្ធិក្នុងការបោះឆ្នោត និង [ខ] សមាជិកសហគមន៍ដែលមិនមានសិទ្ធិបោះឆ្នោត។

ស្ថាប័នដែលមានសមាជិកនៅច្រើនប្រទេសនៅកម្រិតសាកល ឬកម្រិតតំបន់ (ស្ថាប័នអន្តរជាតិ) មានសិទ្ធិក្នុងការក្លាយជាសមាជិកសហគមន៍របស់ ICA។ ការចុះឈ្មោះធ្វើជាសមាជិក ICA របស់ស្ថាប័នត្រូវបានធ្វើឡើងតាមរយៈការិយាល័យតំបន់នីមួយៗ។

## [ខ] គោលការណ៍នៃកិច្ចសហប្រតិបត្តិការ

ចាប់តាំងពីគោលការណ៍សហគមន៍ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៨៩៥ សម្ព័ន្ធសហគមន៍អន្តរជាតិ [ICA] គឺជាអាជ្ញាធរចុងក្រោយក្នុងការកំណត់សហគមន៍ និងការបកស្រាយគោលការណ៍ដែលសហគមន៍គួរតែយកជាមូលដ្ឋាន។ ក្នុងពេលកន្លងទៅ សម្ព័ន្ធសហគមន៍អន្តរជាតិបានចេញសេចក្ដីថ្លែងការណ៍ផ្លូវការចំនួន ០២ ស្ដីពីគោលការណ៍សហគមន៍លើកទី១នៅឆ្នាំ១៩៣៧ និងលើកទី២នៅឆ្នាំ១៩៦៦។ ដូចគ្នានេះដែរ ទាក់ទងនឹងការកែសម្រួលឡើងវិញនៅឆ្នាំ ១៩៩៥ គោលការណ៍ទាំងពីរនេះគឺត្រូវបានបង្កើតឡើង ដើម្បីពន្យល់អំពីវិធីក្នុងការបកស្រាយគោលការណ៍សហគមន៍នៅពេលបច្ចុប្បន្ននេះ។ តាមប្រវត្តិសាស្ត្រ ចលនាសហគមន៍បានប្រែប្រួលឥតឈប់ឈរ។ នេះគឺដោយសារតែការប្រែប្រួលដែលកើតមានឡើងនៅក្នុងរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួន និងនៅតែបន្តប្រែប្រួលទៀតនៅពេលអនាគតខាងមុខ។

*និយមន័យនៃពាក្យសហគមន៍៖* សេចក្ដីថ្លែងការណ៍ពីអត្តសញ្ញាណសហគមន៍ដែលបានអនុម័តដោយសន្និបាតសហគមន៍អន្តរជាតិនៅឆ្នាំ ១៩៩៥ មានសមាសភាគចំនួន ០៣៖ និយមន័យ គុណតម្លៃ និងគោលការណ៍។ សេចក្ដីថ្លែងការណ៍បានកំណត់អត្តសញ្ញាណសហគមន៍ដូចខាងក្រោម៖ "សហគមន៍ គឺជាសមាគមស្វយ័តរបស់បុគ្គលដែលបានរួបរួមគ្នាដោយស្ម័គ្រចិត្ត ក្នុងការបំពេញតម្រូវការរួមផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងបំណងប្រាថ្នាតាមរយៈសហគ្រាសដែលមានកម្មសិទ្ធិរួមគ្នា និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។"

និយមន័យនេះបានសង្កត់ធ្ងន់បន្ថែមទៅលើលក្ខណៈរបស់សហគមន៍ដូចតទៅ៖ [i] សហគមន៍គឺ*ស្វយ័ត* - សហគមន៍គឺមានភាពឯករាជ្យដូចរដ្ឋាភិបាល និងសហគ្រាសឯកជនខ្ពស់បំផុតតាមដែលអាចធ្វើទៅបាន។ [ii] នេះគឺជាសហគមន៍របស់*មនុស្សច្រើននាក់*។ [iii] បុគ្គលរួបរួមគ្នាបង្កើតជាសហគមន៍ដោយ "*ស្ម័គ្រចិត្ត*"។ សមាជិកភាពមិនគួរត្រូវបានតម្រូវដោយច្បាប់ឡើយ។ សមាជិកគួរមានសេរីភាពក្នុងការចូលរួម ឬចាកចេញពីសហគមន៍។ [iv] សមាជិកសហគមន៍ "*បំពេញតម្រូវការរួមផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌*"។ [v] សហគមន៍គឺជាសហគ្រាសដែលមាន "កម្មសិទ្ធិរួមគ្នា និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ"។ ភាពជាម្ចាស់ និងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យគឺ សំខាន់ណាស់ក្នុងការញែកសហគមន៍ចេញពីប្រភេទស្ថាប័នដទៃទៀត។

គុណតម្លៃមូលដ្ឋានរបស់សហគមន៍៖ គុណតម្លៃមូលដ្ឋានរបស់សហគមន៍ គឺមានចែងដូចតទៅ៖

"សហគមន៍ផ្អែកទៅលើគុណតម្លៃនៃការជួយខ្លួនឯង មានការទទួលខុសត្រូវខ្លួនឯង មានប្រជាធិបតេយ្យ ស្មើភាពគ្នា សមធម៌ និងសាមគ្គីភាព។ តាមប្រវត្តិនៃការបង្កើតសហគមន៍ សមាជិកសហគមន៍ជឿជាក់លើគុណតម្លៃសីលធម៌នៃភាពស្មោះត្រង់ ការបើកទូលាយ ការទទួលខុសត្រូវសង្គម និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃ។"

**សេចក្តីថ្លែងការណ៍របស់ ICA ស្តីពីអត្តសញ្ញាណសហគមន៍ [ISCI]៖**

សេចក្តីថ្លែងការណ៍ស្តីពីអត្តសញ្ញាណសហគមន៍ត្រូវបានអនុម័តដោយសន្និបាតឆ្នាំ ១៩៩៥ និងសមាជរបស់សម្ព័ន្ធសហគមន៍អន្តរជាតិ[ICA] ដែលធ្វើឡើងទៅទីក្រុង Manchester ដើម្បីប្រារព្ធខួបមួយសតវត្សរ៍នៃសម្ព័ន្ធសហគមន៍អន្តរជាតិ។

**គោលការណ៍** Rochdale [1844] (ត្រូវបានបង្កើតឡើងដោយស្ថាបនិកសមធម៌សង្គម Rochdale ចក្រភពអង់គ្លេស (Rochdale Soceity of Equitable Pioneers))៖ ចលនាសហគមន៍មានដើមកំណើតនៅក្នុងចក្រភពអង់គ្លេសនៅដើមសតវត្សរ៍ទី១៩។ ចលនានេះត្រូវបានជំរុញដោយអ្នកកំណែទម្រង់សេដ្ឋកិច្ចសង្គមកិច្ចដែលមានដូចជាលោក Robert Owen។ ចលនាសហគមន៍ដំបូង និងត្រូវបានគេស្គាល់ច្រើនបំផុតនោះគឺ **ស្ថាបនិកសមធម៌សង្គម Rochdale របស់ចក្រភពអង់គ្លេស**។ ចលនានេះត្រូវបានបង្កើតឡើង និងបានកំណត់គោលការណ៍ដែលញែកសហគមន៍ដាច់ចេញពីមុខរបរទូទៅ។ នៅឆ្នាំ១៨៤៤ចលនាសហគមន៍បានបើកហាងទំនិញរបស់ខ្លួន Toad Lane ដែលមានទំនិញដូចជាប៊ឺរ ស្ករស ម្សៅមី ម្សៅធញ្ញជាតិ និងទៀន។ គោលការណ៍របស់ហាងទំនិញនេះ គឺជាគោលការណ៍ណែនាំសម្រាប់សហគមន៍ចាប់តាំងពីពេលនោះមក។ គោលការណ៍ Rochdale សំខាន់ៗរួមមាន៖

[០១] សមាជិកម្នាក់មានមួយសំឡេង ដោយមិនគិតថាតើគាត់មានភាគហ៊ុនប៉ុណ្ណាឡើយ។

[០២] បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមនៅក្នុងសហគមន៍ដោយមិនប្រកាន់ពូជសាសន៍ ឬជំនឿរបស់គាត់ឡើយ។

[០៣] ទំនិញ និងសេវាកម្មដែលត្រូវបានលក់ក្នុងតម្លៃទីផ្សារ។ បន្ទាប់ពីអាជីវកម្មបានទូទាត់ចំណាយរួចហើយ ប្រាក់ចំណេញត្រូវបានបង្វិលទៅសមាជិកតាមចំណែកនៃការទិញរបស់ពួកគាត់ មិនមែនទៅតាមភាគហ៊ុនរបស់ពួកគាត់ឡើយ។

[០៤] អត្ថប្រយោជន៍អំពីមូលធនដែលត្រូវបានវិនិយោគជាភាគហ៊ុនមានកំណត់។

[០៥] ការលក់ត្រូវបានធ្វើឡើងជាសាច់ប្រាក់តែប៉ុណ្ណោះ ដើម្បីចៀសវាងហានិភ័យឥណទាន។

ជាការពិត គោលការណ៍ទាំងនេះ គឺជាមូលនិធិសម្រាប់ការបង្កើតគោលការណ៍សហគមន៍ដែលត្រូវបានលើកកម្ពស់ និងការពារដោយសម្ព័ន្ធសហគមន៍អន្តរជាតិ។

**គោលការណ៍សហគមន៍ដែលត្រូវបានកែសម្រួលឡើងវិញ (១៩៣៧)៖**

[០១] សមាជិកភាពទូទៅ

[០២] គ្រប់គ្រងតាមបែបប្រជាធិបតេយ្យ

[០៣] ភាគលាភនៃការទិញ

[០៤] អត្ថប្រយោជន៍មានកំណត់លើមូលធន

[០៥] អព្យាក្រឹតនយោបាយ និងសាសនា

[០៦] ការធ្វើពាណិជ្ជកម្មសាច់ប្រាក់

[០៧] ការលើកកម្ពស់ការអប់រំ។

**គោលការណ៍សហគមន៍ដែលកែសម្រួលឡើងវិញ (១៩៦៦)៖**

ដោយសម្លឹងមើលការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោក សហគមន៍ត្រូវបានផ្តល់ទិសដៅថ្មីនៅឆ្នាំ ១៩៦៦។ ICA បានកែសម្រួលគោលការណ៍របស់ខ្លួនដូចខាងក្រោម៖

[**០១**] **សមាជិកភាព៖** សមាជិកភាពនៃសហគមន៍គួរតែធ្វើឡើងដោយស្ម័គ្រចិត្ត និងអាចធ្វើជាសមាជិកភាពបានដោយមិនមានការកំហិតតាមរូបភាពផ្សេងៗ ឬការរើសអើងសង្គម នយោបាយ និងសាសនាដល់មនុស្សគ្រប់រូបទាំងអស់ដែលប្រើប្រាស់សេវាកម្មរបស់ខ្លួន និងសុខចិត្តទទួលយកការទទួលខុសត្រូវរបស់សមាជិក។

[**០២**] **រដ្ឋបាលសេដ្ឋកិច្ច៖** សហគមន៍ គឺជាស្ថាប័នប្រជាធិបតេយ្យ។ កិច្ចការរបស់ពួកគេគួរត្រូវបានគ្រប់គ្រងដោយមនុស្សដែលត្រូវបានជ្រើសរើស ឬតែងតាំងដោយមានការព្រមព្រៀងគ្នាដោយសមាជិក និងមានគណនេយ្យភាពដល់សមាជិក។ សមាជិករបស់សង្គមសហគមន៍គួរមានសិទ្ធិស្មើគ្នាក្នុងការ

បោះឆ្នោត (មនុស្សម្នាក់សំឡេងឆ្នោត១)។ ក្រៅពីការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនេះរដ្ឋបាលគួរត្រូវបានធ្វើឡើងតាមបែបប្រជាធិបតេយ្យនៅក្នុងទម្រង់មួយដែលសមរម្យ។

[០៣] **ការប្រាក់ពីមូលធនភាគហ៊ុនៈ** មូលធនភាគហ៊ុនគួរត្រូវបានផ្តល់ជូននូវអត្រាការប្រាក់ដែលបានកំណត់យ៉ាងតឹងរ៉ឹងមួយនៅពេលដែលមានការផ្តល់ការប្រាក់ទាំងនេះ។

[០៤] **ការរំលោយប្រាក់សន្សំៈ** នៅពេលមានភាគហ៊ុនលើស ឬប្រាក់សន្សំដែលទទួលបានពីប្រតិបត្តិការរបស់សហគមន៍ដែលជារបស់សមាជិក និងគួរត្រូវបានបែងចែកដោយមិនឱ្យមានសមាជិកណាម្នាក់ទទួលបានប្រាក់ ដោយសារការចំណាយប្រាក់របស់សមាជិកម្នាក់ទៀតនោះឡើយ។

[០៥] **ការអប់រំៈ** សហគមន៍ទាំងអស់គួរផ្តល់ការអប់រំដល់សមាជិក បុគ្គលិក និយោជិត និងសាធារណជនអំពីគោលការណ៍ និងបច្ចេកទេសសហគមន៍ទាំងផ្នែកសេដ្ឋកិច្ច និងប្រជាធិបតេយ្យ។

[០៦] **សហគមន៍អន្តរសហគមន៍ៈ** ដើម្បីឱ្យសហគមន៍អាចបម្រើផលប្រយោជន៍ខ្ពស់បំផុតដល់សមាជិករបស់ខ្លួន សហគមន៍ទាំងអស់គួរសហការយ៉ាងសកម្មនៅគ្រប់ដំណាក់កាលអនុវត្តទាំងអស់ជាមួយនឹងសហគមន៍ផ្សេងៗទៀតនៅកម្រិតមូលដ្ឋាន ជាតិ និងអន្តរជាតិ។

### ICA សន្និបាតឆ្នាំ ១៩៩៥ កែសម្រួលគោលការណ៍មួយចំនួន

អត្តសញ្ញាណសហគមន៍ពេញលេញត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៥។ ការពិពណ៌នា និងការពន្យល់សង្ខេបអំពីគោលការណ៍ទាំងនេះមានដូចខាងក្រោមៈ

### ផ្នែកទី១ៈ និយមន័យ

សហគមន៍ គឺជាស្ថាប័នស្វយ័តរបស់សមាជិកដែលចូលរួមដោយស្ម័គ្រចិត្តក្នុងការបំពេញតម្រូវការរួមផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងបំណងប្រាថ្នាតាមរយៈសហគ្រាសមួយដែលគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងមានម្ចាស់រួមគ្នា។

### ផ្នែកទី២ៈ គុណតម្លៃ

សហគមន៍ គឺផ្អែកទៅលើគុណតម្លៃនៃការជួយខ្លួនឯង មានការទទួលខុសត្រូវខ្លួនឯង ប្រជាធិបតេយ្យ ភាពស្មើគ្នា សមធម៌ និងសាមគ្គីភាព។ តាមប្រពៃណីរបស់អ្នកបង្កើត សមាជិកសហគមន៍ជឿជាក់ក្នុងគុណតម្លៃសីលធម៌នៃភាពស្មោះត្រង់ ការបើកចិត្តទូលាយ ការទទួលខុសត្រូវសង្គម និងការថៃទាំអ្នកដទៃ។

## ផ្នែកទី៣៖ គោលការណ៍សហគមន៍

គោលការណ៍សហគមន៍ គឺជាគោលការណ៍ណែនាំដែលសហគមន៍បញ្ចូលគុណតម្លៃរបស់ពួកគេទៅក្នុងការអនុវត្ត។

### គោលការណ៍០១: ភាពជាសមាជិកដោយស្ម័គ្រចិត្ត និងបើកទូលាយ

សហគមន៍ គឺជាអង្គការស្ម័គ្រចិត្ត ដែលបើកចំហដល់មនុស្សគ្រប់រូបក្នុងការប្រើប្រាស់សេវាកម្មរបស់ពួកគេ និងសុខចិត្តទទួលយកការទទួលខុសត្រូវភាពជាសមាជិកដោយគ្មានការរើសអើងទៅលើយេនឌ័រ សង្គម ពូជសាសន៍ នយោបាយ និងសាសនា។

*(សហគមន៍បើកទូលាយដល់មនុស្សគ្រប់រូបដែលមានតម្រូវការ និងចំណាប់អារម្មណ៍ដូចគ្នា និងមនុស្សដែលចូលរួមជាមួយសហគមន៍ដោយស្ម័គ្រចិត្ត តាមរយៈការទិញយ៉ាងហោចណាស់ហ៊ុនមួយរួមគ្នានិងបង់ប្រាក់សម្រាប់សមាជិក។ ពួកគេមានសេរីភាពក្នុងការចាកចេញ និងនៅពេលដែលពួកគាត់មានបំណងចាកចេញពីសហគមន៍។ សហគមន៍ស្វាគមន៍សមាជិកទាំងអស់ដោយមិនគិតអំពីសញ្ជាតិ និងជំនឿរបស់ពួកគេ។)*

### គោលការណ៍ ០២៖ ការគ្រប់គ្រងរបស់សមាជិកតាមបែបប្រជាធិបតេយ្យ

សហគមន៍ គឺជាស្ថាប័នប្រជាធិបតេយ្យដែលគ្រប់គ្រងដោយសមាជិករបស់ពួកគេ ដែលចូលរួមយ៉ាងសកម្មក្នុងការកំណត់គោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ពួកគេ។ បុរស និងស្ត្រីដែលជាអ្នកតំណាងដែលជាប់ឆ្នោតទទួលខុសត្រូវចំពោះសមាជិកសហគមន៍។ សមាជិកសហគមន៍មានសិទ្ធិបោះឆ្នោតដូចគ្នា [សមាជិកម្នាក់សន្លឹកឆ្នោតមួយសន្លឹក] និងសហគមន៍នៅកម្រិតផ្សេងៗក៏ត្រូវបានរៀបចំតាមបែបប្រជាធិបតេយ្យផងដែរ។

*[សហគមន៍ឱ្យតម្លៃទៅលើតម្លាភាព និងបង្កើតដំណើរការដល់សមាជិក ដើម្បីឱ្យមានការចូលរួមបង្កើតឥទ្ធិពល និងគ្រប់គ្រងសហគ្រាសសហគមន៍ ដោយមិនធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពការគ្រប់គ្រងដែលត្រូវការដើម្បីឱ្យសហគ្រាសមានភាពជោគជ័យឡើយ។ សមាជិកដែលជាម្ចាស់សហគមន៍ចូលរួមនៅក្នុងដំណើរការប្រជាធិបតេយ្យដោយឈរលើមូលដ្ឋាន "សមាជិកម្នាក់សន្លឹកឆ្នោតមួយសន្លឹក" ដោយមិនគិតអំពីចំនួនភាគហ៊ុនដែលពួកគេមាន។ ពួកគេមានសិទ្ធិក្នុងការចូលរួមកិច្ចប្រជុំ និងបោះឆ្នោតជ្រើសរើសតំណាងរបស់ពួកគេនៅក្នុងក្រុមប្រឹក្សាភិបាល/គណៈកម្មាធិការត្រួតពិនិត្យ និងកិច្ចការសំខាន់ផ្សេងៗទៀតរបស់សហគមន៍។]*

### គោលការណ៍ ០៣: ការចូលរួមផ្នែកសេដ្ឋកិច្ចរបស់សមាជិក

សមាជិករួមចំណែកដោយស្មើភាព និង គ្រប់គ្រងតាមបែបប្រជាធិបតេយ្យទៅលើមូលធន

សហគមន៍របស់ពួកគេ។ យ៉ាងហោចណាស់ ជាធម្មតាផ្នែកមួយនៃមូលធន គឺជាទ្រព្យសម្បត្តិរួមរបស់សហគមន៍។ ជាធម្មតា សមាជិកទទួលបានការសងការខូចខាតមានកំណត់ទៅលើមូលធនដែលត្រូវបានកំណត់ថាជាលក្ខខណ្ឌសម្រាប់ចូលជាសមាជិក។ សមាជិកបែងចែកធនធានដែលលើសសម្រាប់វត្ថុបំណងមួយ ឬទាំងអស់នៃវត្ថុបំណងដែលមានដូចខាងក្រោម៖ អភិវឌ្ឍសហគមន៍របស់ពួកគេ បង្កើតមូលនិធិបម្រុងដែលយ៉ាងហោចណាស់ជាផ្នែកមួយ នៃមូលនិធិបម្រុងមិនអាចបែងចែកបានឡើយផ្តល់អត្ថប្រយោជន៍ដល់សមាជិកទៅតាមចំណែកដែលគាត់បានចំណាយជាមួយសហគមន៍ និងការគាំទ្រសកម្មភាពផ្សេងៗទៀតដែលអនុម័តដោយសមាជិក។

*[ការគ្រប់គ្រងរបស់សមាជិកនៃមូលធនសហគមន៍ គឺជាការឆ្លុះបញ្ចាំងនៃភាពជាម្ចាស់រួមគ្នានៃសហគមន៍ដោយសមាជិក។ ចាប់តាំងពីសហគមន៍ក្លាយជាសហគ្រាសសេដ្ឋកិច្ច សេវាកម្មទាំងអស់ត្រូវបានភ្ជាប់ទៅនឹងហិរញ្ញវត្ថុ មិនមានសេវាកម្មដែលមិនគិតថ្លៃឡើយ។ សមាជិកត្រូវបង់សេវាកម្មទាំងអស់ និងមានបំណងចូលរួមក្នុងដំណើរការបង្កើតមូលធនដោយការវិនិយោគ និងប្រាក់តម្កល់។ សហគមន៍មិនមែនជាស្ថាប័នផ្តល់ប្រាក់កម្ចី និងរកប្រាក់ចំណេញពីប្រាក់កម្ចីនោះសុទ្ធសាធទេ។ សហគមន៍ត្រូវបានបង្កើតឡើងដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចលើអ្នកក្រីក្រ។]*

## គោលការណ៍ ០៤: ស្វ័យភាព និងឯករាជ្យភាព

សហគមន៍ គឺស្វយ័ត។ សហគមន៍គឺជាស្ថាប័នដែលជួយខ្លួនឯងដែលគ្រប់គ្រងដោយសមាជិកសហគមន៍។ ប្រសិនបើសហគមន៍ចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នផ្សេងៗទៀត ដែលរួមមានរដ្ឋាភិបាល ឬកៀងគរមូលធនពីប្រភពខាងក្រៅ សហគមន៍នឹងចុះហត្ថលេខានៅក្នុងលក្ខខណ្ឌដែលធានាពីការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យដោយសមាជិករបស់សហគមន៍ និង រក្សាស្វ័យភាពសហគមន៍របស់ពួកគេ។

*(សហគមន៍នឹងមិនបង្កើតសម្ព័ន្ធភាពជាមួយស្ថាប័នផ្សេង ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ/សមាជិកសហគមន៍ឡើយ។ ការវិនិយោគដែលគេលើកទឹកចិត្តដើម្បីបង្កើតធនធាននៅក្នុងសហគ្រាសសហគមន៍នឹងមិនត្រូវបានអនុវត្តឡើយ ក្នុងរូបភាពដែលអ្នកវិនិយោគភាគហ៊ុនគ្រប់គ្រងទៅលើប្រតិបត្តិការសហគមន៍ ទៅតាមចំណែកភាគហ៊ុនដែលខ្លួនបានវិនិយោគឡើយ។ នេះគឺជាការបញ្ជាក់បន្ថែមទៀតនៃធម្មជាតិនៃការប្រើប្រាស់មូលធនរបស់សហគ្រាសសហគមន៍។ សមាជិកសហគមន៍គឺជាអ្នកសម្រេចចិត្តចុងក្រោយ និងមានអាចធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច និងសង្គមបាន។ សមាជិកមានសិទ្ធិក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និងផ្ទេរអំណាចប្រតិបត្តិរបស់ខ្លួនដល់ក្រុមប្រឹក្សាភិបាល។)*

## គោលការណ៍ ០៥៖ ការអប់រំ ការបណ្តុះបណ្តាល និងព័ត៌មាន

សហគមន៍ផ្តល់ការអប់រំ និងការបណ្តុះបណ្តាលសម្រាប់សមាជិករបស់ខ្លួន អ្នកតំណាងជាប់ឆ្នោត អ្នកគ្រប់គ្រង និងនិយោជិត ដូច្នេះពួកគេអាចចូលរួមដោយមានប្រសិទ្ធភាពដល់ការអភិវឌ្ឍសហគមន៍របស់ពួកគេ។ និយោជិតជូនដំណឹងដល់សាធារណៈជន ជាពិសេសយុវជន និងអ្នកផ្សាយព័ត៌មានអំពីធម្មជាតិ និងអត្ថប្រយោជន៍របស់សហគមន៍។

*[សហគមន៍គួរផ្តល់ការអប់រំដល់សមាជិក សហគមន៍ និងមន្ត្រីរដ្ឋាភិបាលមូលដ្ឋាន។ ដោយមិនមានការអប់រំនេះ សហគមន៍នឹងមិនត្រូវបានប្រើប្រាស់ស្មើៗគ្នា និងមិនទទួលបានការគាំទ្រល្អឡើយ ហើយប្រជាធិបតេយ្យនៅក្នុងសហគមន៍នឹងមិនមានដំណើរការល្អឡើយ។ នេះជាការងាររបស់សហគមន៍ក្នុងការបែងចែកថវិកាសម្រាប់ការអប់រំ និងបណ្តុះបណ្តាល និងអនុវត្តកម្មវិធីអប់រំសម្រាប់សមាជិក ព្រមទាំងការបណ្តុះបណ្តាលសម្រាប់និយោជិត ក្នុងការពង្រឹងទំនាក់ទំនងសមាជិកសហគមន៍ និងវិជ្ជាជីវៈអាជីវកម្មរបស់ខ្លួននៃការគ្រប់គ្រងដែលនេះជាកូនសោគន្លឹះនៃភាពជោគជ័យរបស់សហគ្រាសសហគមន៍។]*

## គោលការណ៍ ០៦៖ កិច្ចសហប្រតិបត្តិការក្នុងចំណោមសហគមន៍

សហគមន៍បម្រើសមាជិករបស់ខ្លួនឲ្យមានប្រសិទ្ធភាពបំផុត និងពង្រឹងចលនាសហគមន៍ដោយការធ្វើការរួមគ្នាតាមរយៈហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ជាតិ ក្នុងតំបន់ និងអន្តរជាតិ។

*[សហគមន៍គាំទ្រគ្នាទៅវិញទៅមក ធ្វើជាអតិថិជន និងអ្នកផ្គត់ផ្គង់ឱ្យគ្នាទៅវិញទៅមក និងជួយធានាពីការផ្តល់ហិរញ្ញប្បទានដល់គ្នាទៅវិញទៅមក និងនៅពេលដែលអាចធ្វើទៅបានបង្កើតធនធានជំនាញ និងធនធានមនុស្សរួមគ្នាសម្រាប់ការអភិវឌ្ឍសហគមន៍បន្ថែមទៀត។ សម្ព័ន្ធ/សហព័ន្ធដែលខ្ពស់ជាងនេះគួរគាំទ្រសហគមន៍សម្ព័ន្ធរបស់ពួកគេ និងមិនត្រូវប្រកួតប្រជែងជាមួយពួកគេឡើយ។]*

## គោលការណ៍ ០៧៖ ការគិតគូរដល់សហគមន៍

សហគមន៍ធ្វើការដើម្បីការអភិវឌ្ឍដែលមាននិរន្តរភាព តាមរយៈគោលនយោបាយដែលអនុម័តដោយសមាជិករបស់ពួកគេ។

*(សហគមន៍ចាត់ទុកតម្រូវការបរិស្ថាន និងសង្គមរបស់សហគមន៍គឺជាការសំខាន់។ សហគមន៍មានកង្វល់ទៅលើភាពយុត្តិធម៌ និងប្រឆាំងទៅនឹងការគាបសង្កត់គ្រប់ទីកន្លែង និងគ្រប់ពេលវេលា សូម្បីតែការធ្វើបែបនេះអាចធ្វើឱ្យបាត់បង់ផលប្រយោជន៍សេដ្ឋកិច្ចរយៈពេលខ្លីក៏ដោយ។ សហគមន៍ធ្វើការដើម្បីថែទាំសុខុមាលភាពមនុស្សចាស់ ស្ត្រី និងកុមារ និងកែសម្រួលលក្ខខណ្ឌរស់នៅដោយការប្រើប្រាស់វិធីសាស្ត្រ និងមធ្យោបាយសមរម្យ។)*

គោលការណ៍សហគមន៍ខុសគ្នាពីគោលការណ៍ដែលប្រើប្រាស់ដោយមុខរបរឯកជនដូចជាសាជីវកម្ម/ក្រុមហ៊ុន ដូចដែលមានបង្ហាញនៅក្នុងតារាងដូចខាងក្រោម៖

| លក្ខណៈ | សហគ្រាសសហគមន៍ | សហគ្រាសឯកជន |
|---|---|---|
| វត្ថុបំណងសាជីវកម្ម | ផ្តល់សេវាកម្មដល់សមាជិក ការលើកកម្ពស់សកម្មភាពរួមគ្នា ការចូលរួមរបស់សមាជិក តាមរយៈដំណើរការប្រជាធិបតេយ្យ ការផ្តល់អំណាច | ប្រាក់ចំណេញ អំណាចប្រកួតប្រជែង និងការបន្តប្រតិបត្តិការរបស់សហគ្រាស |
| ភាពជាម្ចាស់ | សមាជិកដែលចូលរួមចម្បងក្នុងការប្រើប្រាស់សេវាកម្មសហគមន៍ | អ្នកវិនិយោគអាចនឹង ឬមិនអាចនឹងចូលរួមនៅក្នុងប្រតិបត្តិការសហគ្រាស |
| ការគ្រប់គ្រង | "សមាជិកម្នាក់មានសំឡេងមួយ" ដោយមិនគិតថាគាត់មានភាគហ៊ុនប៉ុណ្ណាឡើយ។ មន្ត្រី ឬក្រុមប្រឹក្សាភិបាលដែលជាប់ឆ្នោត។ អន្តរាគមន៍ដោយអាជ្ញាធររដ្ឋាភិបាលនៅក្នុងប្រទេសជាច្រើន។ | "ភាគហ៊ុនមួយមានសំឡេងមួយ" មន្ត្រី ឬក្រុមប្រឹក្សាភិបាលដែលជាប់ឆ្នោត។ ក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រង |
| ធម្មជាតិនៃមូលនិធិសមាជិក | ភាគហ៊ុនត្រូវបានទិញ និងទូទាត់វិញនូវថ្លៃដើម។ ការទូទាត់វិញអាចនឹងប្រើប្រាស់ពេលវេលាច្រើន។ មូលធនបង្វិលនៅពេលដែលសមាជិកថ្មីចូលរួម និងសមាជិកចាស់ចាកចេញពីសហគមន៍។ ភាគហ៊ុនអាចត្រូវបានគេបោះផ្សាយជំនួសឱ្យការទូទាត់ជាសាច់ប្រាក់ដល់សមាជិក ឬពីការកាត់ទុកការទូទាត់ចំណាយពីសមាជិក ឬពីការដកចេញនូវការទូទាត់ជាសាច់ប្រាក់ដោយសមាជិកសម្រាប់សេវាកម្មដែលត្រូវខ្លួនបានប្រើប្រាស់។ ត្រូវបានចាត់ទុកថាជាប្រភេទ | ភាគហ៊ុនគឺអាចចរចាបាន [ឧ. ភាគហ៊ុនអាចត្រូវបានទិញ និងលក់បានដោយសេរី លើកលែងករណីដែលមានការព្រមព្រៀងគ្នាដោយម្ចាស់ភាគហ៊ុន] ប៉ុន្តែភាគហ៊ុនមិនអាចប្តូរជាសាច់ប្រាក់បានទេ។ តម្លៃភាគហ៊ុនត្រូវបានកំណត់ដោយការចរចារគ្នារវាងអ្នកទិញ និងអ្នកលក់ ឬតាមរយៈប្រតិបត្តិការដាក់ដេញថ្លៃ/ស្នើឡើង។ នេះត្រូវបានចាត់ទុកថាជាមូលធន |

| | | |
|---|---|---|
| | ដែលមានតម្លៃទាបបំផុតនៃមូលធន ឬធនធានហិរញ្ញវត្ថុ។ | ឬប្រភពធនធានហិរញ្ញវត្ថុដែលមានថ្លៃខ្ពស់បំផុត។ |
| រចនាសម្ព័ន្ធហិរញ្ញវត្ថុ | ជារឿយៗ គ្រប់គ្រងដោយភាគហ៊ុនរបស់សមាជិកដែលឥណទានពិបាកក្នុងការទទួលបាន។ គ្រប់គ្រងដោយបំណុលនៅពេលដែលមានជំនួយអន្តរជាតិ ឬរដ្ឋាភិបាល។ ខុសគ្នាទៅតាមប្រភេទឧស្សាហកម្ម ឬសកម្មភាព។ | ខុសគ្នាទៅតាមប្រភេទឧស្សាហកម្ម និងសហគ្រាស។ |
| តម្លៃការវិនិយោគដោយម្ចាស់ | តម្លៃភាគហ៊ុនដែលអាចបង្វិលវិញបានបូកផ្សំនឹងប្រាក់សន្សំដែលមានតម្លៃសមរម្យដែលផ្តល់ដោយសហគមន៍លើសេវាកម្មដែលប្រើប្រាស់ដោយសមាជិក។ | តម្លៃភាគហ៊ុននៅលើទីផ្សារ |
| ការបែងចែកប្រាក់ចំណេញសុទ្ធ | ចំណែកនៃប្រាក់វិភាគទាន ឧ. កម្រិតនៃការប្រើប្រាស់សេវាកម្មដែលផ្តល់ដោយសហគមន៍ដែលវាស់វែងដោយលក្ខខណ្ឌហិរញ្ញវត្ថុ។ | ចំណែកនៃការកាន់កាប់ភាគហ៊ុន |
| ភាគរយនៃចំណូលទទួលបានពីការវិនិយោគ | ចំណូលទទួលបានពីភាគហ៊ុនមានកំណត់ ដែលកំណត់ដោយច្បាប់ ការគិតពន្ធ ឬគយ។ អត្ថប្រយោជន៍ដែលទទួលបានពីការប្រើប្រាស់សេវា | ភាគលាភដែលបែងចែកដោយក្រុមប្រឹក្សាភិបាល បូកផ្សំនឹងការកើនឡើង ឬការធ្លាក់ចុះតម្លៃភាគហ៊ុន អាស្រ័យទៅតាមការបំពេញការងារ និងលក្ខខណ្ឌទីផ្សារហិរញ្ញវត្ថុ។ |

ប្រភព៖ ការប្រមូលមូលធននៅក្នុងសហគមន៍សេវាកម្មកសិកម្ម FAO នៅទីក្រុងរ៉ូម។ នៅឆ្នាំ ១៩៩៧ ពីព្រោះតែភាពខុសគ្នាទាំងនេះរវាងសហគមន៍ និងអាជីវកម្មផ្សេងៗទៀត មានប្រទេសជាច្រើនបានទទួលស្គាល់ស្ថាប័នមុខរបរសហគមន៍ថាជាប្រភេទមុខរបរមួយដែលពិសេស និងចាត់ចំណាត់ថ្នាក់ស្ថាប័នទាំងនោះទៅតាមលក្ខខណ្ឌច្បាប់ និងសេដ្ឋកិច្ចដូចគ្នាដែរ។

**សារៈសំខាន់នៃគោលការណ៍សហគមន៍៖** គោលការណ៍សហគមន៍គឺជាគោលការណ៍មូលដ្ឋាន ឬចំណុចគ្រឹះរបស់សហគមន៍។ គោលការណ៍សហគមន៍អាចអនុវត្តបានទៅលើគ្រប់ប្រភេទទាំងអស់នៃ

សហគមន៍នៅគ្រប់លក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយនៅទូទាំងពិភពលោក។

## សន្និដ្ឋាន

សង្គមសហគមន៍ គឺជានីតិបុគ្គលដោយសារតែមានសមាជិកចូលរួមក្នុងការបង្កើតសហគមន៍ និងដោយរដ្ឋាភិបាលទទួលស្គាល់សហគមន៍ស្របច្បាប់ តាមរយៈការចុះបញ្ជីលក្ខន្តិកៈនៃសហគមន៍។ លក្ខន្តិកៈសហគមន៍ត្រូវបានអនុម័តដោយមហាសន្និបាត។ លក្ខន្តិកៈសហគមន៍នេះអាចត្រូវបានធ្វើវិសោធន៍កម្មដោយមហាសន្និបាតនៅពេលដែលមានតម្រូវការក្នុងការធ្វើវិសោធន៍កម្មលក្ខន្តិកៈ។ លក្ខន្តិកៈសហគមន៍ជាថ្មីម្តងទៀតនឹងត្រូវបានចុះបញ្ជីដោយរដ្ឋាភិបាល។ ហេតុនេះលក្ខន្តិកៈនេះអាចអនុវត្តបាននៅកម្រិតខុសគ្នានៃសេចក្តីពិស្តារនៃប្រភេទខុសគ្នា នៃសហគមន៍នៅក្នុងស្ថានភាពផ្សេងៗគ្នា។ លើសពីនេះទៅទៀត សហគមន៍តម្រូវឱ្យសមាជិកធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ ដូចជាធម្មជាតិប្រជាធិបតេយ្យរបស់ស្ថាប័នពួកគេ តួនាទីស្ថាប័នពាក់ព័ន្ធផ្សេងៗ និងការបែងចែកធនធានដែលនៅសល់ដែលសហគមន៍រកបាន។ ទាំងនេះគឺជាលក្ខណៈសំខាន់ដែលធ្វើឱ្យសហគមន៍មានប្រសិទ្ធភាព មានអត្តសញ្ញាណសហគមន៍ និងគុណតម្លៃនៃចលនាសហគមន៍។

# ជំពូកទី៥
# ទម្រង់សហគមន៍កសិកម្ម

សហគមន៍ គឺជាអង្គភាពសង្គមសេដ្ឋកិច្ចប្រជាធិបតេយ្យពលរដ្ឋស្ម័គ្រចិត្ត។ ពួកគេដឹកនាំមុខងារអាជីវកម្ម និងសង្គម ហើយជាសហគ្រាសអាជីវកម្ម។ ពួកគាត់គ្មានការកេងប្រវ័ញ្ច ហើយធ្វើអាជីវកម្មលើមូលដ្ឋាននៃការចូលរួមពីសមាជិកតាមរបៀបប្រជាធិបតេយ្យ និងស្ថិតក្នុងក្របខណ្ឌច្បាប់ប្រទេស។ វត្ថុបំណងចម្បងរបស់ពួកគេ គឺផ្តល់សេវាកម្មសមរម្យប្រកបដោយភាពស័ក្តិសិទ្ធិដល់សមាជិករបស់ពួកគេ។

សហគមន៍ត្រូវបានគេឃើញមានគ្រប់ស្រទាប់វណ្ណៈក្នុងគ្រប់ប្រទេសទាំងអស់។ បុគ្គលម្នាក់ៗអាចចូលរួមក្នុងសហគមន៍ដោយការស្ម័គ្រចិត្តហើយអាចចាកចេញតាមការសម្រេចរបស់ខ្លួន។ សហគមន៍មានទម្រង់ជាច្រើនដូចក្នុងឧទាហរណ៍មួយចំនួនខាងក្រោមនេះ៖

សហគមន៍កសិកម្ម៖ ជាកន្លែងដែលកសិករជាសមាជិក។ សហគមន៍ទាំងនេះផ្តល់ឥណទាន (សម្រាប់ផលិតកម្ម និងការប្រើប្រាស់) ការធ្វើទីផ្សារផលិតផលរបស់សមាជិក ការផ្តល់វត្ថុធាតុដើម

កសិកម្មដូចជាជី និងគីមីកសិកម្ម និងគ្រាប់ពូជ និងសេចក្តីណែនាំជាទម្រង់ពង្រីកកសិកម្ម និងធ្វើឱ្យជីវភាពរស់នៅមានភាពប្រសើរឡើង។ ចំនួនសហគមន៍កសិកម្មក្នុងពិភពលោកមានខ្ពស់ជាងគេបំផុតដែលមាន៦៥%នៃប្រភេទទាំងអស់នៃសហគមន៍ក្នុងចំណោមគម្រោងសរុបនៃរចនាសម្ព័ន្ធសហគមន៍។ សហគមន៍កសិកម្មទាំងនេះបង្កើតសម្ព័ន្ធអាជីវកម្មផ្ទាល់ខ្លួនដែល កែច្នៃ និងធ្វើទីផ្សារផលិតផលកសិកម្ម រួមបញ្ចូលទាំង ការផ្តល់ការគាំទ្រការផ្សាយអាជីវកម្ម។

សហគមន៍ជាប្រភេទសហគមន៍មានគោលបំណងតែមួយ និងគោលបំណងច្រើនផងដែរ។ សហគមន៍ដែលមានគោលបំណងតែមួយមានដូចជាសហគមន៍ផលិតទឹកដោះគោ សហគមន៍ផលិតជី សហគមន៍គាបទឹកអំពៅលក់ សហគមន៍នេសាទ ឧទាហរណ៍៖រោងចក្រផលិតស្ករស សហគមន៍អ្នកបណ្តុះគ្រាប់ពូជ សហគមន៍ដឹកជញ្ជូន។ សហគមន៍ដែលមានគោលបំណងច្រើន គឺសហគមន៍ដែលដំណើរការមុខងារទាំងអស់ដើម្បីបម្រើសមាជិករបស់ពួកគេ ឧទាហរណ៍៖ ការធ្វើទីផ្សារផលិតផលរបស់សមាជិក ឃ្លាំងទំនិញ ការកែច្នៃផលិតផលកសិកម្ម ការកែលម្អដី សហគមន៍ប្រព័ន្ធធារាសាស្ត្រ សហគមន៍ផ្គត់ផ្គង់អគ្គិសនីជនបទ ផ្សារទំនើប ការទិញផលិតផលកសិកម្មសម្រាប់ស្តុកស្បៀងជាតិរបស់រដ្ឋាភិបាល។ល។និង។ល។

សហគមន៍អ្នកប្រើប្រាស់ដែលបង្កើតឡើង ដោយពលរដ្ឋដើម្បីបម្រើពួកគេផ្ទាល់នូវសេវាកម្មនិងទំនិញសម្រាប់អ្នកប្រើប្រាស់។ សហគមន៍បែបនេះដំណើរការជាមជ្ឈមណ្ឌលលទ្ធកម្ម ផ្សារទំនើប ហាងតូចៗ សេវាវេចខ្ចប់ និងសកម្មភាពសុខុមាលភាពសមាជិកពួកគេផ្ទាល់ រួមបញ្ចូលទាំងសេវាកម្មសុខភាពមួយចំនួន។

សហគមន៍ផលិតស្ករស គឺជាសហគមន៍ដែលមានសមាជិកដាំដើមអំពៅ។ សហគមន៍ទាំងនេះធ្វើការទាក់ទងនឹងផលិតកម្មអំពៅ ប្រមូលផលិតផលពីចម្ការហើយយកទៅច្នៃក្នុងរោងចក្រស្ករស។ រោងចក្រស្ករសផលិតស្ករសថ្លា និងអនុផលផ្សេងទៀត។

សហគមន៍ផលិតជី៖ កសិករគឺជាសមាជិកនៃសហគមន៍ទាំងនេះ ព្រោះពួកគេជាអ្នកប្រើប្រាស់ជីផ្ទាល់។ សហគមន៍ផលិតជីទទួលបានវត្ថុធាតុដើមពីប្រភពផ្សេងៗ បង្កើតរោងចក្រផលិតកម្ម និងផលិតគីមីកសិកម្មដើម្បីចែកចាយក្នុងចំណោមកសិករតាមរយៈបណ្តាញសហភាព និងសម្ព័ន្ធទីផ្សារ។ សហគមន៍បែបនេះផ្តល់សេវាផ្សព្វផ្សាយកសិកម្មបន្ថែម។

សហគមន៍នេសាទចូលរួមក្នុងការប្រើប្រាស់ទូក និងធនធាននេសាទក្នុងស្រុក ហើយរៀបចំទីផ្សារ និងការកែច្នៃរបស់ពួកគេ។

ទម្រង់ផ្សេងៗទៀតនៃសហគមន៍គឺ៖ ធនាគារសហគមន៍ (ជនបទ និងទីក្រុង) សហគមន៍សាងសង់ផ្ទះ សហគមន៍ផ្តល់សេវាវេជ្ជសាស្ត្រ សហគមន៍សិស្ស សហគមន៍ទីផ្សារ និងអ្នកដាំបន្លែផ្លែឈើ សហគមន៍ទុកវត្ថុត្រជាក់ សហគមន៍កែលម្អដី សហគមន៍ដឹកជញ្ជូន សហគមន៍ទេសចរណ៍ សហគមន៍

ឧស្សាហកម្មស្ត្រី សហាគមន៍បញ្ចុះសព សហាគមន៍វិចិត្រករ សហាគមន៍គ្រូបង្រៀន សហាគមន៍ជំនួយផ្នែកច្បាប់។ល។និង។ល។

សហាគមន៍ទាំងអស់នេះប្រតិបត្តិលើមូលដ្ឋាននៃគោលការណ៍កិច្ចសហប្រតិបត្តិការ និងស្រប តាមច្បាប់សហប្រតិបត្តិការជាតិ និងក្នុងក្របខណ្ឌច្បាប់ប្រទេស។ សហាគមន៍ទាំងនេះមានសម្ព័ន្ធអាជីវកម្មផ្ទាល់ខ្លួន។ នៅប្រទេសផ្សេងៗ មានច្បាប់ពិសេសសម្រាប់ផ្នែកផ្សេងៗនៃសកម្មភាពសហាគមន៍ដូចជាច្បាប់ស្តីពីសហាគមន៍កសិកម្មកម្ពុជា។

សហាគមន៍ទាំងអស់បង្កើតសម្ព័ន្ធអាជីវកម្មថ្នាក់ខេត្ត និងថ្នាក់ជាតិរបស់ពួកគេ។ សហាគមន៍ទាំងអស់ក៏បង្កើតអ្នកដឹកនាំថ្នាក់ជាតិដែលមើលការខុសត្រូវលើការអភិវឌ្ឍស្ថាប័នសហាគមន៍និងធានាសុវត្ថិភាពនៃគោលការណ៍កិច្ចសហប្រតិបត្តិការ។

-----------------------------------------------------------

# ជំពូកទី៦
## រចនាសម្ព័ន្ធចាត់តាំងនៃសហគមន៍កសិកម្ម

ច្បាប់ស្តីពីសហគមន៍កសិកម្មដែលមានស្រាប់ ឬតាមរយៈការឯកភាពថ្នាក់ជាតិសហគមន៍កសិកម្មបានធ្វើតាមរចនាសម្ព័ន្ធដែលសមហេតុផលជាក់លាក់មួយ ដែលយកចិត្តទុកដាក់លើតម្រូវការមុខរបរ និងប្រជាធិបតេយ្យ។ នៅក្នុងជំពូកនេះ និងជំពូកបន្ទាប់ៗទៀត មានការថែងពីការអនុវត្តដែលធ្វើឡើងក្នុងប្រទេសជាច្រើនលើសាកលលោក។ ក្នុងករណីភាគច្រើន ស្ថាប័នសហគមន៍បានយកតាមរចនា សម្ព័ន្ធចាត់តាំងដូចខាងក្រោមៈ

រចនាសម្ព័ន្ធចាត់តាំងសហគមន៍កសិកម្មដែលល្អមានរូបរាងដូចខាងក្រោមនេះៈ

មនុស្សទាំងនោះដែលបានបង់ថ្លៃសមាជិក ហើយដាក់ហ៊ុន និងអ្នកដែលទទួលជាសមាជិកផ្លូវការនៃសហគមន៍កសិកម្ម បង្កើតមហាសន្និបាត។ ប្រតិបត្តិការ និងមុខងារទាំងអស់នៃសហគមន៍គ្រប់គ្រងដោយមហាសន្និបាត ស្របតាមគោលនយោបាយដែលបង្កើតដោយសហគមន៍កសិកម្ម។ ជាទូទៅមានកិច្ចប្រជុំរៀងរាល់មួយឆ្នាំម្តងដើម្បីកត់ត្រាពីវឌ្ឍនភាព និងពិចារណានិងអនុម័តរបាយការណ៍សវនកម្ម និងរបាយការណ៍ប្រចាំឆ្នាំ និងដើម្បីបោះឆ្នោតជ្រើសតាំងមន្ត្រីការិយាល័យ។

សហគមន៍កសិកម្មបោះឆ្នោត ជ្រើសតាំងក្រុមប្រឹក្សាភិបាល/គណៈកម្មាធិការត្រួតពិនិត្យស្របតាមលក្ខន្តិកៈ។ សមាជិក (ជាទូទៅចាប់ពី៥-៧នាក់) ត្រូវបានតែងតាំងឱ្យធ្វើកិច្ចការផ្សេងគ្នាដែលពួកគេត្រូវធ្វើឱ្យស្របតាមគោលនយោបាយដែលបានកំណត់ដោយមហាសន្និបាត និងលក្ខន្តិកៈសហគមន៍។ គណៈកម្មាធិការត្រួតពិនិត្យបោះឆ្នោតជ្រើសតាំងប្រធានមួយរូប។ មានមន្ត្រីការិយាល័យផ្សេងទៀតដូចជា ៖ អនុប្រធាន ហេរញ្ញិក និងសមាជិកផ្សេងទៀត។ មហាសន្និបាតក៏បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការត្រួតពិនិត្យផងដែរ។

គណៈកម្មាធិការត្រួតពិនិត្យ ប្តូរគោលនយោបាយដែលគាត់តែងដោយស្ថាប័នដឹកនាំទៅជាគម្រោងផែនការដែលអាចអនុវត្តបានសម្រាប់ប្រតិបត្តិការតែងតាំងអ្នកគ្រប់គ្រង និងនិយោជិត។ និយោជិតដែលទទួលប្រាក់ខែ ធ្វើការក្រោមការត្រួតត្រា និងការណែនាំពីគណៈកម្មាធិការត្រួតពិនិត្យ។ គណៈកម្មាធិការត្រួតពិនិត្យក៏អាចតែងតាំងគណៈកម្មាធិការប្រតិបត្តិ និង/ឬ អនុគណៈកម្មាធិការផ្សេងៗទៀតដែលអាចឆ្លើយតបទៅនឹងគណៈកម្មាធិការត្រួតពិនិត្យ។ ក្នុងករណីខ្លះ មហាសន្និបាតជ្រើសតាំង/តែងតាំងអនុគណៈកម្មាធិការបែបនេះដែលអាចឆ្លើយតបទៅនឹងមហាសន្និបាត។

ការអាស្រ័យលើប្រភេទ និងទំហំនៃស្ថាប័នសហគមន៍ និងស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់ស្តីពីសហគមន៍កសិកម្ម និងស្របតាមធម្មនុញ្ញសហគមន៍ រចនាសម្ព័ន្ធចាត់តាំងអាចនឹងមានការកែសម្រួលជាច្រើនលើកច្រើនសា។ មហាសន្និបាត ឬក្រុមប្រឹក្សាភិបាលអាចតែងតាំងគណៈកម្មាធិការបន្ថែមទៀត

ដូចជា គណៈកម្មាធិការអាជីវកម្ម  គណៈកម្មាធិការអចលនទ្រព្យ គណៈកម្មាធិការរដ្ឋបាល គណៈកម្មាធិការលទ្ធកម្មទំនិញ  ។ល។និង។ល។  ចំនួននាយកដ្ឋានអាជីវកម្មក៏អាចកើនឡើងបានដោយអាស្រ័យលើទំហំនៃអាជីវកម្មនិងតំបន់ប្រតិបត្តិការនៃសង្គមសហគមន៍។

រដ្ឋធម្មនុញ្ញនៃសហគមន៍កសិកម្មកំណត់សិទ្ធិ និងភារកិច្ចរបស់មហាសន្និបាត ក្រុមប្រឹក្សាភិបាល គណៈកម្មាធិការត្រួតពិនិត្យ  សវនករ  និងគណៈកម្មាធិការផ្សេងៗទៀតក្រៅពីភាពញឹកញាប់នៃកិច្ចប្រជុំរបស់ពួកគេ និងវិធីសាស្ត្រនៃការកោះប្រជុំ និងនីតិវិធីនៃការរៀបចំការបោះឆ្នោត។

នៅទូទាំងពិភពលោក  គេរកឃើញថាសហគមន៍មានកិច្ចប្រតិបត្តិការល្អប្រសើរនៅពេលសេវាកម្មរបស់ពួកគេត្រូវបានប្រើប្រាស់យ៉ាងច្រើន និងទូលំទូលាយ ហើយនៅពេលលុយនៅតែចរាចរ។ ពួកគេអំពាវនាវឱ្យសមាជិកចូលរួមយ៉ាងមោះមុតក្នុងប្រតិបត្តិការអាជីវកម្ម និងការរៀបចំ។

**រចនាសម្ព័ន្ធចាត់តាំងនៃ**
**សហគមន៍កសិកម្ម**
**"សហគមន៍ គឺដូចជារាងកាយមនុស្សអ៊ីចឹង"**

សមាជសមាជិក

ក្រុមប្រឹក្សាភិបាល/គណៈកម្មាធិការត្រួតពិនិត្យ

សវនករ

អ្នកមើលការខុសត្រូវ/ទីប្រឹក្សា

អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ

នាយកដ្ឋានអាជីវកម្ម

---

# ជំពូកទី៧
# ការរៀបចំសហគមន៍កសិកម្ម

វិធីសាស្ត្រនៃការរៀបចំសហគមន៍កសិកម្មត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពី សហគមន៍កសិកម្ម។ នាយកដ្ឋានសហគមន៍កសិកម្មផ្តល់ជំនួយក្នុងការបង្កើតសហគមន៍កសិកម្ម។ ជំហានមួយចំនួនដែលយកមកប្រើនៅក្នុងការរៀបចំសហគមន៍កសិកម្មរួមមាន៖

- ប្រជាពលរដ្ឋនៃប្រទេសដែលសម្រេចចិត្តច្បាស់លាស់ហើយមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ អាចចូលជាសមាជិកបាន។
- ជនគ្រប់រូបដែលប្រាថ្នាចង់ចូលជាសមាជិកត្រូវបំពេញទម្រង់ ស្នើសុំជាសមាជិក បង់ប្រាក់ភាគហ៊ុន និងថ្លៃចូលជាសមាជិកតាមការកំណត់
- គ្រប់សមាជិកបែបនេះទាំងអស់ ដែលមិនតិចជាង១៥នាក់ បង្កើតបានជាកិច្ចប្រជុំមហាសន្និបាតកំណើតដំបូង
- សង្គមមានតំបន់ប្រតិបត្តិការដែលជាភូមិឬកម្រងភូមិ ស្រុក ឬរដ្ឋទាំងមូល
- កិច្ចប្រជុំមហាសន្និបាតកំណើតដំបូងអនុវត្តតាមបទបញ្ជាផ្ទៃក្នុង [រដ្ឋធម្មនុញ្ញ] និងយល់ព្រមកំណត់ឱ្យខ្លួនធ្វើតាមច្បាប់ទាំងនេះ ហើយចេញសេចក្តីសម្រេចដើម្បីបង្កើតសហគមន៍កសិកម្មមួយឡើង
- កិច្ចប្រជុំមហាសន្និបាតកំណើតដំបូងក៏បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល (ប្រធាន អនុប្រធាន ហេរញ្ញិក និងសមាជិកពីរនាក់ទៀត) ដែលត្រូវបានរំពឹងថាគ្រប់គ្រងសហគមន៍កសិកម្មក្រោយពេលចុះបញ្ជីរួច។
- រៀបចំឯកសារ និងលិខិតស្នាមផ្សេងៗដើម្បីដាក់ជូនអ្នកកាន់បញ្ជី
- បើកគណនីដោយប្រើឈ្មោះសង្គមនិងបង្ហាញឈ្មោះហត្ថលេខី
- ពាក្យសុំផ្លូវការត្រូវធ្វើជូនអ្នកកាន់បញ្ជីសហគមន៍តាមរយៈអ្នកអធិការកិច្ចសហគមន៍នៃតំបន់នោះ ដែលភ្ជាប់ជាមួយនិងលិខិតចម្លងនៃការអនុវត្តតាមបទបញ្ជាផ្ទៃក្នុង បញ្ជីសមាជិកស្ថាបនិក សមាជិកភាព និងភាគហ៊ុនដែលបានបង់រួច និងដំណោះស្រាយ រៀបចំជាបីច្បាប់។
- ពាក្យសុំនេះនឹងត្រូវពិនិត្យ ហើយវាយតម្លៃ
- ក្រោយការបំពេញលិខិតបទដ្ឋានទាំងនេះចប់សព្វគ្រប់ បើឃើញថាមានលំដាប់លំដោយល្អ ហើយ នឹងត្រូវចេញ "វិញ្ញាបនបត្រចុះបញ្ជី" ទៅឱ្យសហគមន៍កសិកម្ម

- បន្ទាប់មកគណៈកម្មាធិការត្រួតពិនិត្យតែងតាំងអ្នកគ្រប់គ្រង និងនិយោជិតផ្សេងទៀតនៃសហគមន៍កសិកម្ម
- បន្ទាប់មកសហគមន៍កសិកម្មអាចចាប់ផ្តើមធ្វើអាជីវកម្មរបស់ខ្លួនធម្មតា
- គេអាចបង្កើតប្រភេទផ្សេងៗនៃសហគមន៍ដូចជាសហគមន៍កសិកម្មមូលដ្ឋាន សហគមន៍ទីផ្សារ សហគមន៍សេវាកម្ម សហគមន៍អ្នកប្រើប្រាស់ សហគមន៍ប្រព័ន្ធធារាសាស្ត្រ សហគមន៍ដាំផ្កា សហគមន៍ផលិតទឹកដោះគោ សហគមន៍តម្បាញ សហគមន៍ព្រៃឈើ សហគមន៍ច្បារដំណាំ សហគមន៍និយោជិត សហគមន៍សាងសង់ផ្ទះ សហគមន៍ការងារ សហគមន៍រោងចក្រផលិតស្បែកជើង សហគមន៍នេសាទ សហគមន៍ផលិត និងចែកចាយអគ្គិសនី ។ល។និង។ល។
- ចំពោះការបង្កើតសហគមន៍ យើងអាចទទួលជំនួយពីអ្នកកាន់បញ្ជីសហគមន៍ សហភាពសហគមន៍ស្រុក ធនាគារសហគមន៍ ។ល។ ហើយសេវានេះមិនគិតថ្លៃទេ។

*ចំណុចសម្រាប់ការពិភាក្សា*

តើអ្វីខ្លះជាគុណសម្បត្តិនៃការរៀបចំសហគមន៍កសិកម្ម?

តើនរណាខ្លះដែលអាចចូលជាសមាជិកសហគមន៍កសិកម្មបាន?

តើវាជាទីភ្នាក់ងាររដ្ឋាភិបាល ឬទីភ្នាក់ងារដែលគ្រប់គ្រងដោយសមាជិក?

-----------------------------------------------------------

# ជំពូកទី៨
# ច្បាប់ វិធាន បទបញ្ជាផ្ទៃក្នុង/ និងលក្ខន្តិកៈ សម្រាប់សហគមន៍កសិកម្ម

## [ក] ច្បាប់ស្តីពីសហគមន៍កសិកម្ម

ច្បាប់ស្តីពី សហគមន៍កសិកម្មគឺជាច្បាប់ដែលអនុម័តដោយរដ្ឋសភា។ វាផ្តល់នីតិបុគ្គលទៅឱ្យផ្នែកសហគមន៍កសិកម្មទាំងមូល និងជាពិសេសសហគមន៍កសិកម្មដែលបង្កើតឡើងក្រោមច្បាប់នេះ។ ច្បាប់នេះជំនួយដល់ដំណើរការ នៃការចុះបញ្ជីដែលមើលការខុសត្រូវដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងមានអ្នកកាន់បញ្ជីសហគមន៍កសិកម្មជាប្រធាន។ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មឆ្លើយតបទៅនឹងរដ្ឋមន្ត្រីក្រសួងកសិកម្ម។ អ្នកកាន់បញ្ជីមាននាយកដ្ឋានពាក់ព័ន្ធដែលធ្វើការងារពីថ្នាក់ជាតិកំពូលទៅរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ទាបបំផុតនៅក្នុងភូមិ ឬអនុសាខា។ ច្បាប់ផ្តល់ជំនួយដល់កត្តាស្របច្បាប់ទាំងអស់ដូចជា ការធ្វើសវនកម្ម ការត្រួតពិនិត្យ ការគ្រប់គ្រងរចនាសម្ព័ន្ធសហគមន៍កសិកម្ម និងមានបណ្តាញសម្របសម្រួលជាមួយនឹងនាយកដ្ឋានរដ្ឋាភិបាល។ វាគឺជាច្បាប់ដែលចុះបញ្ជីសហគមន៍កសិកម្ម ហើយក៏សម្រាប់រំលាយសហគមន៍កសិកម្មដែរ។ គ្រប់សហគមន៍កសិកម្មទាំងអស់គឺតម្រូវឱ្យគោរពច្បាប់ និងធ្វើរបាយការណ៍ឱ្យបានទៀងទាត់ជាក់ជូននាយកដ្ឋានដូចដែលតម្រូវឱ្យធ្វើនៅក្នុង
ច្បាប់។

## [ខ] វិធានសហគមន៍កសិកម្ម

ដើម្បីអនុវត្តច្បាប់និងគ្រប់គ្រងសហគមន៍កសិកម្ម និងដើម្បីធានាកិច្ចប្រតិបត្តិការដែលប្រកបដោយប្រសិទ្ធភាព និងនាំមកនូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដោយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មរៀបចំវិធាន បទបញ្ជា និងគោលការណ៍ណែនាំ។ វិធាន និងបទបញ្ជាទាំងនេះដាក់ឱ្យអនុវត្តពីពេលមួយទៅពេលមួយ និងពេលដែលចាំបាច់និងតម្រូវដោយរដ្ឋាភិបាល។ វិធានទាំងនេះអាចអនុវត្តបានចំពោះសហគមន៍កសិកម្មទាំងអស់ ហើយពួកគេត្រូវគោរពតាមវិធានទាំងនេះ។ វិធាន និងបទបញ្ជាមិនមែនជាឧបករណ៍ត្រួតពិនិត្យចាំបាច់នោះទេ តែត្រូវចាត់ទុកជាឧបករណ៍សម្រាប់សម្របសម្រួលកិច្ចប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសហគមន៍កសិកម្ម។

## [គ] លក្ខន្តិកៈរបស់សហគមន៍កសិកម្ម

វាជាលក្ខន្តិកៈរបស់សហគមន៍កសិកម្មដែលសមាជិកអនុម័តសម្រាប់អភិបាលកិច្ចនៃការចូលរួមនៅក្នុងសហគមន៍កសិកម្ម។ ជាទូទៅរដ្ឋាភិបាលរៀបចំ និងត្រៀមសេចក្តីព្រាងច្បាប់ជាស្រេច

(ឬលក្ខន្តិកៈ) ដែលមហាសន្និបាតកំណើតដំបូងនៃសហគមន៍កសិកម្មចាត់ទុក និងអនុម័តសម្រាប់កិច្ចប្រតិបត្តិការផ្លូវការរបស់ខ្លួន។ សមាជិកមានសិទ្ធិធ្វើការផ្លាស់ប្តូរសេចក្តីព្រាងលក្ខន្តិកៈណាដែលចាំបាច់ដើម្បីត្រូវនឹងលក្ខខណ្ឌតម្រូវ តំបន់កិច្ចប្រតិបត្តិការ និងដែនអាជីវកម្មនៃសហគមន៍កសិកម្មដែលបានស្នើ។ ក្នុងករណីលក្ខន្តិកៈទាំងនេះបានឯកភាព និងអនុម័តហើយ ពួកវាក្លាយជាវិធានផ្លូវការ ឬលក្ខន្តិកៈនៃសហគមន៍កសិកម្ម។ សមាជិកទាំងអស់ត្រូវរំពឹងថាត្រូវគោរពតាមមាត្រាទាំងអស់នៃលក្ខន្តិកៈ។ ដោយអាស្រ័យលើប្រភេទនៃទំហំអាជីវកម្ម ការបង្កើនសមាជិកភាពនៃសហគមន៍ វិធាន និងបទបញ្ជារដ្ឋាភិបាលដែលត្រូវអនុវត្ត សមាជិកសហគមន៍កសិកម្មអាចធ្វើវិសោធនកម្មលក្ខន្តិកៈបាន។ ការធ្វើវិសោធនកម្មត្រូវចុះបញ្ជីជាមួយនឹងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មដើម្បីដាក់ជាធរមាន។

ឧទាហរណ៍ខាងក្រោមជាបទប្បញ្ញត្តិដែលទាក់ទងនឹង ច្បាប់ស្តីពីសហគមន៍កសិកម្ម វិធានបទបញ្ជា និងលក្ខន្តិកៈនៃសហគមន៍កសិកម្មៈ

- សហគមន៍កសិកម្មត្រូវបានរៀបចំស្របទៅតាមបទបញ្ញត្តិនៃច្បាប់ស្តីពីសហគមន៍កសិកម្មដែលត្រូវអនុវត្ត
- ដើម្បីចេញច្បាប់ស្តីពីសហគមន៍កសិកម្ម រដ្ឋាភិបាលតែងតាំងអាជ្ញាធរនិយតកម្ម នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម អ្នកកាន់បញ្ជីសហគមន៍កសិកម្ម(RCS)ជាប្រធានដែលបណ្តាញរបស់គេត្រូវបានពង្រីកដល់កម្រិតស្រុក ឬស្រុករង
- RCSជាអ្នកកាន់បញ្ជីសហគមន៍កសិកម្មទាំងអស់ដើម្បីផ្តល់ឱ្យពួកគេនូវឋានៈនីតិបុគ្គល
- ច្បាប់ស្តីពីសហគមន៍កសិកម្មមានវិធីសាស្ត្រ បច្ចេកទេស និងនីតិវិធីដែលត្រូវធ្វើតាមក្នុងការរៀបចំ និងចាត់ចែងសហគមន៍កសិកម្ម
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មរៀបចំ និងចេញផ្សាយសេចក្តីព្រាងលក្ខន្តិកៈគំរូសម្រាប់សហគមន៍ប្រភេទផ្សេងៗក្នុងការណែនាំនៃអនាគតសមាជិក។ សេចក្តីព្រាងលក្ខន្តិកៈគំរូត្រូវបានពិភាក្សាដោយអនាគតសមាជិកក្នុងមហាសន្និបាត និងក្រោយពីធ្វើវិសោធនកម្មសមស្រប ត្រូវបានអនុម័ត
- លក្ខន្តិកៈដែលបានអនុម័ត គឺត្រូវដាក់ជូនអ្នកកាន់បញ្ជីសហគមន៍ក្រោយពេលពិនិត្យរួចនឹងចុះបញ្ជីហើយចេញវិញ្ញាបនបត្រចុះបញ្ជីដើម្បីធ្វើឱ្យសហគមន៍កសិកម្មក្លាយជាផ្លូវការ
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មអនុវត្តអធិការកិច្ចសហគមន៍ និងចេញសេចក្តីណែនាំនិងគោលការណ៍ណែនាំពីមួយពេលទៅមួយពេល
- ការធ្វើសវនកម្មគណនេយ្យ នៃសហគមន៍កសិកម្មត្រូវធ្វើដោយសវនករនៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។ នាយកដ្ឋានរៀបចំរបាយការណ៍សវនកម្ម និងត្រៀមជាស្រេចសម្រាប់សហគមន៍កសិកម្មធ្វើជាព័ត៌មាន និងប្រព្រឹត្តតាម

- របាយការណ៍សវនកម្មត្រូវដាក់ជូនមហាសន្និបាតសម្រាប់ការគាំទ្រ និងការអនុម័ត។ វាជាភារកិច្ចរបស់សហគមន៍កសិកម្មក្នុងការអនុវត្តតាមសេចក្តីជំទាស់ និងសំណើដែលតាក់តែងនៅក្នុងរបាយការណ៍សវនកម្ម និងផ្ញើជូនអ្នកកាន់បញ្ជីវិញដើម្បីជ្រាបជាព័ត៌មាន
- សវនករផ្ទៃក្នុងត្រូវបានបោះឆ្នោតជ្រើសរើស ក្នុងចំណោមសមាជិកនៃមហាសន្និបាតដើម្បីរក្សាទុកមូលប្បទានបត្រស្តីអំពីកិច្ចការអាជីវកម្មនៃសហគមន៍កសិកម្ម និងដើម្បីជួយសវនករផ្លូវការ។ ក្នុងករណីខ្លះ មហាសន្និបាតអាចបោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ ឬសវនកម្ម/អធិការកិច្ច។ សវនករ ឬគណៈកម្មាធិការសវនកម្ម និងអធិការកិច្ចផ្ទៃក្នុងឆ្លើយតបទៅនឹងមហាសន្និបាតតែមួយប៉ុណ្ណោះ
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម**មិនមែនជា**និយតករ អ្នកត្រួតពិនិត្យ ឬម្ចាស់នៃសហគមន៍កសិកម្មទេ។ ការងារចម្បងរបស់ខ្លួនគឺផ្តល់សំណើ និងសេចក្តីណែនាំដល់សហគមន៍កសិកម្មក្នុងនាមជាមិត្ត ទស្សនវិទូ និងមគ្គុទ្ទេសក៍
- សហគមន៍កសិកម្មធ្វើវិសោធនកម្មលើបទបញ្ញាផ្ទៃក្នុងរបស់ខ្លួនពីមួយពេលទៅមួយពេលដាក់ជូននូវលក្ខន្តិកៈក្នុងដែលធ្វើវិសោធនកម្មរួចដើម្បីចុះបញ្ជីនៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សមាសធាតុសំខាន់ៗមួយចំនួននៃលក្ខន្តិកៈសហគមន៍កសិកម្មរួមមានៈ

  ឈ្មោះ អាសយដ្ឋាន និងតំបន់នៃកិច្ចប្រតិបត្តិការ កម្មវត្ថុនៃសហគមន៍ សមាជិកភាពនៃសហគមន៍កសិកម្ម ចែងអំពីការទទួលខុសត្រូវនៃសង្គម មូលនិធិសង្គម ដែនកំណត់ឥណទានអតិបរមានៃសង្គម ស្ថាប័នសង្គម-ស្ថាប័នដឹកនាំសង្គម គណៈកម្មាធិការត្រួតពិនិត្យ មន្ត្រីការិយាល័យសហគមន៍កសិកម្ម លេខាសហគមន៍កសិកម្ម ហេរញ្ញិកសហគមន៍កសិកម្ម ការចុះឈ្មោះដើម្បីថែរក្សា ប្រភេទ និងជំនួយប្រាក់កម្ចី ការបែងចែកប្រាក់ចំណេញ វិសោធនកម្មលក្ខន្តិកៈនិងផ្សេងៗ
- សមាជិកទាំងអស់នៃសហគមន៍កសិកម្មបង្កើតមហាសន្និបាតដែលជាស្ថាប័នកំពូល។ វាជាស្ថាប័នដែលមានអំណាចបំផុត និងខ្ពស់បំផុតនៃសហគមន៍កសិកម្ម
- សមាជិកគឺអ្នកណាដែលបានអនុញ្ញាតឱ្យចូលជាសមាជិកតាមផ្លូវច្បាប់ ហើយជាអ្នកដែលបានបង់ភាគហ៊ុនរួមទាំងថ្លៃសមាជិកភាពផងដែរ
- សមាជិកដែលបានចុះក្នុងបញ្ជីទាំងអស់ត្រូវបានទទួលសិទ្ធិបោះឆ្នោតផ្អែកលើគោលការណ៍ "សមាជិកម្នាក់-សំឡេងមួយ" ដោយមិនគិតពីចំនួនភាគហ៊ុនដែលពួកគេកាន់កាប់
- នីតិវិធីនៃការអនុញ្ញាតឱ្យចូល និងការបណ្តេញចេញ/ការដកចេញនៃសមាជិក និងសមាជិកគណៈកម្មាធិការត្រួតពិនិត្យត្រូវបានតាក់តែងចូលក្នុងលក្ខន្តិកៈ

- សមាជិកភាពនៃសហគមន៍គឺបើកចំហដោយគ្មានការដាក់កំហិតលើវណ្ណៈ សាសនានិងភេទឡើយ។ សមាជិកមានសិទ្ធិសេរីភាពក្នុងការចូលរួមបន្ត និងបញ្ចប់សមាជិកភាពដោយខ្លួនឯងលុះត្រាតែម្នាក់នោះត្រូវបានប្រកាសថាមិនសម/គ្មានគុណសម្បត្តិបន្តជាសមាជិកភាពតទៅទៀតបាន
- សមាជិកមានសិទ្ធិបោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាលតាមការជ្រើសរើសរបស់ពួកគេដោយប្រើសិទ្ធិក្នុងការបោះឆ្នោត
- អាណត្តិកាន់អំណាចជាគណៈកម្មាធិការត្រួតពិនិត្យបានតាក់តែងនៅក្នុងលក្ខន្តិកៈ (ជាទូទៅមានរយៈពេល២ឆ្នាំ)
- ជាទូទៅក្នុងសហគមន៍កសិកម្មតូចមួយមានគណៈកម្មាធិការត្រួតពិនិត្យចំនួន៥រូប។ ផ្អែកលើការពង្រីកអាជីវកម្មរបស់ខ្លួន សហគមន៍កសិកម្មអាចបង្កើនចំនួនសមាជិកគណៈកម្មាធិការត្រួតពិនិត្យបាន
- ភាពញឹកញាប់និងប្រភេទនៃមហាសន្និបាតរួមបញ្ចូលទាំងកូរ៉ុមត្រូវបានតាក់តែងក្នុងលក្ខន្តិកៈ
- ភាពញឹកញាប់ និងប្រភេទនៃកិច្ចប្រជុំគណៈកម្មធិការត្រួតពិនិត្យរួមបញ្ចូលទាំងកូរ៉ុមត្រូវបានចែងក្នុងលក្ខន្តិកៈ
- លក្ខន្តិកៈតាក់តែងវិធីសាស្ត្រនិងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការផ្សេងៗនៃសហគមន៍កសិកម្ម
- បទបញ្ជាផ្ទៃក្នុងមានចែងវិធីសាស្ត្រនៃការទទួល និងរម្លាយភាគហ៊ុន
- សិទ្ធិ និងភារកិច្ចសមាជិក ស្ថាប័នដឹកនាំ សមាជិកគណៈកម្មាធិការត្រួតពិនិត្យ ប្រធាន អនុប្រធាន ហិរញ្ញិក និងអ្នកគ្រប់គ្រង/លេខា មានចែងក្នុងលក្ខន្តិកៈ
- វិធីសាស្ត្រទទួលប្រាក់កម្ចី និងការទូទាត់ប្រាក់មានចែងនៅក្នុងលក្ខន្តិកៈ
- លក្ខន្តិកៈក៏ផ្តល់វិធីសាស្ត្រ បច្ចេកទេសនៃការគ្រប់គ្រងមូលនិធិសហគមន៍កសិកម្ម បញ្ជីការគណនេយ្យ បញ្ជីឈ្មោះសមាជិក ការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល ការរៀបចំប្រភេទផ្សេងៗនៃរបាយការណ៍។ល។
- លក្ខន្តិកៈក៏មានសេចក្តីពិស្តារនៃការបែងចែក/ការទុកបម្រុងនៃប្រាក់ចំណេញរបស់សហគមន៍ និងវិធីសាស្ត្រនៃការគ្រប់គ្រងការខាតបង់
- លក្ខន្តិកៈក៏តាក់តែងគោលការណ៍ណែនាំពីរបៀបរម្លាយសហគមន៍កសិកម្មដែរ។

ជាទូទៅបំណុលរបស់សមាជិក សម្រាប់ឱនភាពទ្រព្យសកម្មរបស់សហគមន៍កសិកម្មក្នុងពេលដែលបញ្ចប់ កំណត់ត្រឹមប្រាំដងនៃតម្លៃភាគហ៊ុនដែលបានចូលដោយសមាជិក។ ខចែងអំពីប្រាក់បំណុលអាចប្រែប្រួលជាលក្ខណៈឆន្ទានុសិទ្ធិនៃមហាសន្និបាត។

សហគមន៍កសិកម្ម គឺជាស្ថាប័នប្រជាធិបតេយ្យ។ សមាជិកមហាសន្និបាតបោះឆ្នោតជ្រើសតាំង (មិនមែនតែងតាំង) គណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការផ្សេងៗទៀត។ ដោយវាជាស្ថាប័នប្រជាធិបតេយ្យ ការសម្រេចចិត្តធ្វើឡើងដោយ "ការបោះឆ្នោតសំឡេងភាគច្រើន"។ ទោះយ៉ាងណាក៏ដោយសមាជិកដែលមានចំណេះដឹងជ្រៅជ្រះពេញចិត្តនឹងការសម្រេចចិត្តដោយ "មតិឯកច្ឆន្ទ" ដែលបង្កើតភាពស្អិតរមួត និងកេរ្តិ៍ឈ្មោះល្អក្នុងចំណោមសមាជិក។ ទោះយ៉ាងនេះក្តីនិយោជិតទាំងអស់ត្រូវបានតែងតាំងដោយគណៈកម្មាធិការត្រួតពិនិត្យ ហើយពួកគេឆ្លើយតបចំពោះវាតែមួយមុខប៉ុណ្ណោះ។

*ចំណុចសម្រាប់ការពិភាក្សា*

- តើអ្នកធ្លាប់ឃើញ អាន ឬមានលក្ខន្តិកៈសហគមន៍កសិកម្មរបស់អ្នកដែរឬទេ?
- តើអ្នកចូលរួមមហាសន្និបាតសហគមន៍កសិកម្មរបស់អ្នកដែរឬទេ?
- តើអ្នកធ្លាប់ឃើញ អាន ឬមានរបាយការណ៍សវនកម្ម និងរបាយការណ៍ប្រចាំរបស់សហគមន៍កសិកម្មអ្នកដែរឬទេ?
- តើអ្នកធ្លាប់ប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសរើសជាគណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិកម្មរបស់អ្នកដែរឬទេ?
- តើមួយណាល្អជាង "សំឡេងភាគច្រើន" ឬ "ការសម្រេចចិត្តដោយឯកច្ឆន្ទ"?
- តើអ្នកមានយោបល់អ្វីខ្លះដើម្បីកែលម្អសហគមន៍កសិកម្មរបស់អ្នក?

------------------------------------------------------------

# ជំពូកទី៩
# ហេតុអ្វីត្រូវចូលជាសមាជិកសហគមន៍កសិកម្ម?

សមាជិក គឺជាម្ចាស់ពិតប្រាកដនៃសហគមន៍កសិកម្ម។ យោងតាមគោលការណ៍ដែលគេទទួលស្គាល់ទូទាំងសាកលលោក ការចូលជាសមាជិកភាពក្នុងសហគមន៍កសិកម្ម គឺបើកចំហ និងដោយស្ម័គ្រចិត្ត។ សមាជិកមានសិទ្ធិសេរីភាពក្នុងការចូល និងចេញពីសហគមន៍កសិកម្ម។ អ្នកដែលស្ម័គ្រចិត្តហើយមានគុណសម្បត្តិប្រើសេវាកម្មសហគមន៍អាចចូលជាសមាជិកសហគមន៍កសិកម្មបាន។ សមាជិកភាពផ្តល់អំណាចសមាជិកឱ្យមានស្ថានភាពសេដ្ឋកិច្ច និងសង្គមប្រសើរជាងមុន។

ដូចនេះហើយ ខ្ញុំប្រាថ្នាចូលជាសមាជិកសហគមន៍កសិកម្មដោយសារមូលហេតុខាងក្រោមនេះ៖

- សមាជិកភាពសហគមន៍កសិកម្មបង្កើតឱ្យមានអារម្មណ៍ជាម្ចាស់កម្មសិទ្ធិ និងសន្តិសុខសម្រាប់គ្រួសារខ្ញុំ និងខ្ញុំ
- ការចូលជាសមាជិក ខ្ញុំអាចទទួលបានការផ្គត់ផ្គង់ជី គ្រាប់ពូជ វត្ថុធាតុដើមកសិកម្មផ្សេងទៀត និងសម្ភារកសិកម្មរួមបញ្ចូលទាំងការធ្វើទីផ្សារផលិតផល និងឧបករណ៍ឥណទានទាន់ពេលវេលា និងមានគុណភាពល្អប្រសើរ
- ការចូលជាសមាជិក ខ្ញុំអាចទទួលបានព័ត៌មានពិត និងចុងក្រោយអំពីស្ថានភាពទូទៅនៃកសិកម្មដែលជួយខ្ញុំឱ្យទទួលបានផលិតភាព និងផលិតកម្មខ្ពស់។
- ធ្វើទីផ្សារផលិតផលកសិកម្មរបស់ខ្ញុំយ៉ាងឆាប់រហ័ស និងក្នុងអត្រាសមរម្យ
- ទទួលស្តុកផលិតផលលើសរបស់ខ្ញុំទុកនៅក្នុងឃ្លាំងសហគមន៍

ខ្ញុំជាសមាជិកសហគមន៍កសិកម្ម ហើយទទួលបានកិច្ចប្រតិបត្តិការ និងការរួមសហការពីសមាជិកផ្សេងទៀតនៃសហគមន៍។

សមាជិកភាពសហគមន៍កសិកម្មផ្តល់អំណាចនៃការតថ្លៃជាក់ស្តែង និងធំជាងក្នុងការទទួលការផ្គត់ផ្គង់ ការទុកចិត្ត និងការធ្វើទីផ្សារផលិតផល។ សមាជិកភាពជួយការពារសមាជិកពីឈ្មួញកណ្តាលអ្នកផ្តល់ប្រាក់កម្ចី និងអ្នកកេងប្រវ័ញ្ច។ សហគមន៍កសិកម្ម គឺជាបណ្តាញដែលផ្តល់ការការពារ និងសុវត្ថិភាពគ្រប់គ្រាន់ដល់សមាជិក និងគ្រួសាររបស់ពួកគេ។

សហគមន៍កសិកម្ម គឺផ្អែកលើតម្លៃសីលធម៌ និងក្រមសីលធម៌ដែលជាមូលដ្ឋាននៃគោលការណ៍សហគមន៍កសិកម្ម។ សមាជិក គឺជាស្ថាបនិក អ្នកគ្រប់គ្រង និងម្ចាស់នៃសហគ្រាសអាជីវកម្មសហគមន៍កសិកម្ម ហើយពួកគេមានសិទ្ធិសេរីភាពធ្វើការសម្រេចចិត្តលើមុខរបររបស់ពួកគេផ្ទាល់។ សហគមន៍កសិកម្មគឺជាសសរដ៏រឹងមាំនៃកម្លាំងរបស់សមាជិកនៅតំបន់ដាច់ស្រយាល។

*ចំណុចសម្រាប់ការពិភាក្សា*

- ពិភាក្សាពីរបៀបក្លាយជាសមាជិកពេញសិទ្ធិទទួលបានផលប្រយោជន៍នៃសហគមន៍កសិកម្ម។
- តើផលប្រយោជន៍នៃការចូលជាសមាជិកមានអ្វីខ្លះ?

-----------------------------------------------------------

## ជំពូកទី១០
## សិទ្ធិ និងកាតព្វកិច្ចរបស់សហគមន៍កសិកម្ម

សហគមន៍កសិកម្មត្រូវមានសិទ្ធិ និងកាតព្វកិច្ចដូចខាងក្រោម៖

[១] អនុវត្តកិច្ចការអាជីវកម្មក្នុងក្របខណ្ឌនៃផលិតកម្មកសិកម្ម កសិឧស្សាហកម្ម កសិពាណិជ្ជកម្ម និងសេវាពាក់ព័ន្ធផ្សេងៗទៀតដើម្បីផ្តល់អត្ថប្រយោជន៍ដល់សមាជិក

[២] ជានីតិបុគ្គលដែលតំណាងឱ្យសមាជិកក្នុងការចូលដល់ការចុះកិច្ចសន្យា និងអនុវត្តកិច្ចសន្យាជាមួយវិស័យឯកជនឬជាមួយដៃគូអភិវឌ្ឍន៍ផ្សេងៗ

[៣] ធានាសិទ្ធិសមាជិកក្នុងការចូលរួមសម្រេចបាននូវគោលដៅវប្បធម៌ និងសង្គមសេដ្ឋកិច្ចនៃសហគមន៍កសិកម្ម

[៤] ផ្តល់ជំនួយបច្ចេកទេស និងហ្វឹកហ្វឺនដើម្បីបង្កើនសមត្ថភាពសមាជិករបស់ខ្លួន និងផ្តល់ព័ត៌មានដល់សមាជិកដើម្បីជំរុញការចូលរួមរបស់ពួកគេក្នុងកិច្ចប្រតិបត្តិការសហគមន៍កសិកម្ម

[៥] ដាក់ពាក្យសុំ ឬទទួលជំនួយហិរញ្ញវត្ថុ ឬបច្ចេកទេសពីរដ្ឋាភិបាល និងពីប្រភពច្បាប់ផ្សេងៗ

[៦] ទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម ការរក្សាទុក និងការបន្ថែមដើមទុន ព្រមទាំងធនធានសហគមន៍កសិកម្មផ្សេងទៀតស្របនឹងច្បាប់ និងបទបញ្ញាមានសមត្ថកិច្ច

[៧] បង់ពន្ធ និងបំពេញកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងៗស្របនឹងច្បាប់ និងបទបញ្ញាមានសមត្ថកិច្ច

[៨] អនុវត្តកិច្ចការពាក់ព័ន្ធនឹងវត្ថុបំណងសហគមន៍កសិកម្ម

[៩] សហគមន៍កសិកម្មត្រូវរក្សាឯកសារ ឬកំណត់ត្រាទុកនៅការិយាល័យកណ្តាលរបស់ខ្លួន និងកន្លែងណាមួយដែលកំណត់ដោយច្បាប់។ ឯកសារ ឬកំណត់ត្រាដែលត្រូវរក្សាទុកមានដូចខាងក្រោម៖

[១០] លក្ខន្តិកៈសហគមន៍កសិកម្ម បទបញ្ជាផ្ទៃក្នុង និងវិញ្ញាបនបត្រចុះបញ្ជី បញ្ជីសមាជិកសហគមន៍កសិកម្ម ដែលក្នុងនោះរួមមាន៖

[ក] ឈ្មោះ និងអាសយដ្ឋានការិយាល័យសហគមន៍កសិកម្ម

[ខ] ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់សមាជិកសហគមន៍កសិកម្ម

[គ] កាលបរិច្ឆេទនៃការចូលជាសមាជិក

[១១] បញ្ជីភាគហ៊ុនសមាជិក ដែលក្នុងនោះមាន៖ [ក] ឈ្មោះ និងអាសយដ្ឋានការិយាល័យសហគមន៍កសិកម្ម [ខ] ឈ្មោះសមាជិកដែលមានភាគហ៊ុន តម្លៃភាគហ៊ុន ចំនួនភាគហ៊ុន និងហ៊ុនដែលបានបង់រួច។

[១២] តារាងតុល្យការប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម

[១៣] របាយការណ៍ប្រចាំឆ្នាំសហគមន៍កសិកម្មដែលគូសបញ្ជាក់លទ្ធផលនៃកិច្ចប្រតិបត្តិការសហគមន៍កសិកម្ម

[១៤] របាយការណ៍សវនកម្មសហគមន៍កសិកម្ម

[១៥] ប្រភេទទាំងអស់នៃកំណត់ហេតុ និងរបាយការណ៍

[១៦] ឯកសារសហគមន៍កសិកម្មផ្សេងៗដែលតម្រូវដោយរដ្ឋាភិបាល ឬស្នើដោយសមាជិក

*ចំណុចសម្រាប់ការពិភាក្សា*

- តើសហគមន៍កសិកម្មគាំទ្រសមាជិករបស់ខ្លួនបន្ថែមយ៉ាងដូចម្ដេច?
- តើសង្គមអាចជួយអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធភូមិ/ជនបទបានដែរឬទេ?
- តើសហគមន៍កសិកម្មត្រូវផ្ដល់លិខិតចម្លងឯកសារច្បាប់របស់ខ្លួនឱ្យទៅសមាជិករបស់ខ្លួនទាំងអស់ដែរឬទេ?

----------------------------------------------------------

# ជំពូកទី១១
# សិទ្ធិ និងភារកិច្ចរបស់សមាជិកសហគមន៍កសិកម្ម

លក្ខន្តិកៈ មានបញ្ជីពិស្តារនៃសិទ្ធិ និងភារកិច្ចសមាជិក និងស្ថាប័ន និងមុខងារសហគមន៍កសិកម្មផ្សេងទៀត។ ខណៈដែលលក្ខន្តិកៈដាក់បញ្ញត្តិអំពីសិទ្ធិ សមាជិកត្រូវបានរំពឹងថាត្រូវអនុវត្តភារកិច្ចរបស់ពួកគេ។ សិទ្ធិនឹងមិនមានន័យអ្វីឡើយបើគ្មានការអនុវត្តភារកិច្ច។

សិទ្ធិ និងភារកិច្ចរបស់សមាជិកមួយចំនួនដែលបានចែងក្នុងលក្ខន្តិកៈមានដូចខាងក្រោម៖

***ភារកិច្ចសមាជិក***

- ចូលរួមគ្រប់មហាសន្និបាតទាំងអស់
- ប្រតិបត្តិការគ្រប់ការផ្គត់ផ្គង់ និងការធ្វើទីផ្សារអាជីវកម្មជាមួយ/តាមរយៈសហគមន៍កសិកម្ម
- ការពារអត្ថប្រយោជន៍សហគមន៍កសិកម្មពីគូប្រជែង/អ្នករិះគន់
- មិនត្រូវទុកសៀវភៅប្រាក់បញ្ញើ ឬសៀវភៅមូលប្បទានបត្រ ដែលបានចុះហត្ថលេខារួច និងមានមុខងារសហគមន៍កសិកម្មចោលនោះទេ
- រក្សាប័ណ្ណ និងបង្កាន់ដៃទទួលប្រាក់ទាំងអស់ដែលចេញដោយសហគមន៍កសិកម្មនៅកន្លែងមានសុវត្ថិភាព
- ទទួលបង្កាន់ដៃទទួលប្រាក់ពីសហគមន៍កសិកម្មភ្លាមៗរាល់ការទូទាត់ប្រាក់
- បោះឆ្នោតជ្រើសរើសសមាជិកដែលស្មោះត្រង់ លះបង់ និងឧស្សាហ៍ព្យាយាមឱ្យធ្វើជាគណៈកម្មាធិការត្រួតពិនិត្យ

***សិទ្ធិសមាជិក***

- ជួយគ្រប់សេវាកម្មដែលផ្តល់ដោយសហគមន៍កសិកម្ម
- សិក្សា និងសង្កេតមើលវិធាន បទបញ្ជា និងបទប្បញ្ញត្តិទាំងអស់នៃលក្ខន្តិកៈ
- សិក្សារបាយការណ៍សវនកម្ម និងរបាយការណ៍ប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម
- សួរសំណួរ និងសុំឱ្យមន្ត្រីការិយាល័យបញ្ជាក់ឱ្យច្បាស់
- ប្រើសិទ្ធិបោះឆ្នោតដោយសេរី និងគ្មានការបង្ខិតបង្ខំ ឬទំនោរលើនរណាម្នាក់
- ទទួលបានការបោះឆ្នោតជ្រើសតាំងជាគណៈកម្មធិការត្រួតពិនិត្យបើមិនមានការខកខាន
- យកបង្កាន់ដៃបង់ប្រាក់សម្រាប់ការទូទាត់ប្រាក់ឱ្យសហគមន៍កសិកម្ម
- ទទួលបានឯកសារចម្លងដែលបញ្ជាក់ពីសហគមន៍កសិកម្មដោយមិនគិតថ្លៃ
- បញ្ចេញយោបល់ និងទស្សនៈដោយសេរី និងស្មោះត្រង់

*មិនត្រូវភ័យខ្លាចនរណាម្នាក់ ឬស្ទាក់ស្ទើរក្នុងការសួរសំណួរ និងស្វែងរកការបញ្ជាក់ពីមន្ត្រី*

*ការិយាល័យសហគមន៍កសិកម្មរបស់អ្នក។ សូមចាំថា អ្នកជាម្ចាស់សហគមន៍កសិកម្មព្រោះអ្នកបានដាក់ឥណទានទៅក្នុងសហគមន៍កសិកម្មនេះ។ អ្នកជានិយោជកនៅក្នុងសហគមន៍កសិកម្ម។ វាជាសិទ្ធិរបស់អ្នកក្នុងការផ្តល់យោបល់។ សហគមន៍កសិកម្មមិនមែនជាក្លឹបសង្គម ឬស្ថាប័នសប្បុរសធម៌ទេ។ អ្នកត្រូវបង់ថ្លៃគ្រប់សេវាទាំងអស់។ វាជាសហគ្រាសអាជីវកម្ម។*

***ចំណុចសម្រាប់ការពិចារណា***

- តើវាមានសារៈសំខាន់ដូចម្តេចក្នុងការមានតុល្យភាពរវាងសិទ្ធិ និងភារកិច្ច?
- តើអ្នកធ្លាប់អាន ឬមានគេធ្លាប់អានលក្ខន្តិកៈទាក់ទងនឹងសិទ្ធិសមាជិកដែរឬទេ?
- តើអ្នកធ្លាប់អាន ឬមានគេធ្លាប់អានលក្ខន្តិកៈទាក់ទងនឹងភារកិច្ចសមាជិកដែរឬទេ?
- តើអ្នកធ្លាប់ទទួលបានបង្កាន់ដៃបង់ប្រាក់សម្រាប់ការទូទាត់ប្រាក់ឱ្យទៅសហគមន៍កសិកម្មដែរឬទេ?
- តើអ្នកធ្លាប់បោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការត្រួតពីនិត្យដោយជម្រើស និងការពេញចិត្តរបស់អ្នកដែរឬទេ?

---------------------------------------------------------

## ជំពូក ១២
## មហាសន្និបាតសហគមន៍កសិកម្ម

នៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម មហាសន្និបាតរបស់សមាជិក គឺជាអង្គភាពមួយដ៏សំខាន់។ មហាសន្និបាតនេះរួមមាន បុគ្គលទាំងអស់ដែលត្រូវបានទទួលស្គាល់ជាផ្លូវការ បន្ទាប់ពីធ្វើការបង់ថ្លៃសេវាសមាជិកភាពរបស់ខ្លួនរួច និងបានចូលភាគហ៊ុន។ បុគ្គលទាំងនេះ ត្រូវបានហៅថាសមាជិក និង មានសិទ្ធិ "បោះឆ្នោត" ដោយផ្អែកលើគោលការណ៍ "សមាជិក១ សន្លឹកឆ្នោត១" យោងតាមគោលការណ៍សហគមន៍កសិកម្ម។ សហគមន៍មានស្វ័យភាព និងឯករាជភាពមិនពាក់ព័ន្ធជួររដ្ឋាភិបាល។

មហាសន្និបាត គឺជាស្ថាប័នជាន់ខ្ពស់ ដែលដាក់ចេញនូវគោលការណ៍ និងកម្មវិធីសម្រាប់ស្ថាប័នសហគមន៍កសិកម្ម។ ដើម្បីអនុវត្តគោលការណ៍នេះ ស្ថាប័នដឹកនាំបោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការផ្សេងទៀត។ ពួកគេត្រូវឆ្លើយសំណួរទៅកាន់មហាសន្និបាត។ បន្ទាប់មក គណៈកម្មាធិការត្រួតពិនិត្យត្រូវបានប្រគល់សិទ្ធិ ឱ្យជ្រើសរើសបុគ្គលិក។ កិច្ចប្រជុំមហាសន្និបាត

កិច្ចប្រជុំមហាសន្និបាតមានច្រើនទម្រង់ដូចខាងក្រោម៖

- កិច្ចប្រជុំមហាសន្និបាតសាមញ្ញប្រចាំឆ្នាំ កត់សម្គាល់អំពីវិវឌ្ឍនភាពការងារ ដែលសម្រេចបាន និងដាក់ចេញនូវគោលការណ៍សម្រាប់អនុវត្ត
- កិច្ចប្រជុំមហាសន្និបាតពិសេស បន្ថែមពីលើការងាររបស់កិច្ចប្រជុំស្ថាប័នដឹកនាំសាមញ្ញ បោះឆ្នោតជ្រើសរើសមន្ត្រីទទួលបន្ទុក
- កិច្ចប្រជុំមហាសន្និបាតវិសាមញ្ញ ធ្វើវិសោធនកម្មលក្ខន្តិកៈ និង
- កិច្ចប្រជុំមហាសន្និបាតតាមការស្នើសុំ ត្រូវបានស្នើដោយសមាជិក ឬ អ្នកចុះបញ្ជីសហគមន៍កសិកម្ម ដើម្បីធ្វើការប្តេជ្ញាចិត្តលើបញ្ហាជាក់លាក់។

មុខងារសំខាន់របស់មហាសន្និបាត

- ក្នុងនាមជាស្ថាប័នជាន់ខ្ពស់នៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិកម្ម មហាសន្និបាតទូទៅដាក់ចេញនូវគោលនយោបាយ អនុម័តលើកម្មវិធី និងជ្រើសរើសគណៈកម្មាធិការ
- ការប្រជុំនេះ ត្រូវបានដឹកនាំដោយប្រធានមហាសន្និបាត ហើយប្រសិនបើប្រធានមហាសន្និបាតអវត្តមាន ត្រូវដឹកនាំដោយអនុប្រធានមហាសន្និបាត
- ប្រធានមហាសន្និបាត ឬ បុគ្គលដែលដឹកនាំកិច្ចប្រជុំ មានសំឡេងឆ្នោតមួយ ក្នុងករណី ដែលមានទំនាក់ទំនង។

*សិទ្ធិអំណាចរបស់មហាសន្និបាត*

- បោះឆ្នោតជ្រើសរើស ព្យួរការងារ និងដកសមាជិកជាប់ឆ្នោតចេញពីគណៈកម្មាធិការត្រួតពិនិត្យ
- ពិចារណាលើរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍សវនកម្ម គណនេយ្យចំណេញនិងខាត និងកំណត់សម្គាល់អធិការកិច្ច
- កំណត់កម្រិតឥណទានជាអតិបរមា [MCL] របស់សមាជិកម្នាក់ៗ
- ធ្វើវិសោធនកម្មលក្ខន្តិកៈ

  រាល់អាជីវកម្មទាំងអស់ ដែលបានពិភាក្សា ឬ ត្រូវបានសម្រេច នៅក្នុងកិច្ចមហាសន្និបាត ត្រូវកត់ត្រានៅក្នុងបញ្ជីនីតិវិធី ដែលនឹងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ។ រាល់សេចក្តីសម្រេចទាំងអស់របស់មហាសន្និបាត ត្រូវភ្ជាប់កាតព្វកិច្ចទៅឱ្យសមាជិកសហគមន៍កសិកម្មទាំងអស់ មិនថាឡើយពួកគេបានបានបោះឆ្នោតគាំទ្រ ឬ មិនគាំទ្រនោះទេ។

*ចំណុចសម្រាប់ការពិភាក្សា*

- តើយើងចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតឬទេ?
- ហេតុអ្វីប្រធានអង្គប្រជុំគួរតែមានសំឡេងឆ្នោតមួយ?
- តើមហាសន្និបាតអាចបញ្ឈប់ ឬ ព្យួរការងាររបស់គណៈកម្មាធិការត្រួតពិនិត្យដែលជាប់ឆ្នោតដោយរបៀបណា?

---

## ជំពូកទី ១៣
## សិទ្ធិ និងភារកិច្ចក្រុមប្រឹក្សាភិបាល

រាល់កិច្ចការទាំងអស់របស់សហគមន៍កសិកម្ម ត្រូវអនុវត្តដោយគណៈកម្មធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល តាងនាមឱ្យសមាជិក និងអនុលោមតាមគោលការណ៍ទូទៅ ដែលបានដាក់ចេញដោយមហាសន្និបាត។ គណៈកម្មាធិការត្រួតពិនិត្យ ត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកក្នុងចំណោមសមាជិករបស់មហាសន្និបាត។ ភារកិច្ចដ៏សំខាន់របស់គណៈកម្មាធិការត្រួតពិនិត្យ គឺដើម្បីការពារផលប្រយោជន៍របស់សមាជិក និងសហគមន៍កសិកម្មផ្ទាល់។ គណៈកម្មាធិការនេះ មានសិទ្ធិ និងសមត្ថភាពក្នុងការសម្រេចចិត្តទាំងអស់ ជំនួសមុខឱ្យសមាជិក។ ចំនួនសមាជិកគណៈកម្មាធិការត្រូវបានរៀបរាប់នៅក្នុងលក្ខន្តិកៈរបស់សហគមន៍កសិកម្ម។

គណៈកម្មាធិការ ធ្វើការសម្រេចចិត្តទាំងអស់ទៅលើគោលការណ៍ទូទៅដែលបានដាក់ចេញដោយមហាសន្និបាត និងរៀបចំកិច្ចប្រជុំមហាសន្និបាត និងបង្កើតរបៀបវារៈសម្រាប់កិច្ចពិភាក្សា។ គណៈកម្មាធិការនេះ ជ្រើសរើសអ្នកគ្រប់គ្រងទូទៅនិងបុគ្គលិកផ្សេងទៀតដើម្បីអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ធ្វើការទិញលក់តាងនាមឱ្យសហគមន៍កសិកម្ម រៀបចំរបាយការណ៍សវនកម្ម របាយការណ៍អធិការកិច្ចនិងរបាយការណ៍ប្រចាំឆ្នាំសម្រាប់ជាព័ត៌មាន និងដាក់ជូនមហាសន្និបាតដើម្បីអនុម័តនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ខ្លួន។ គណៈកម្មាធិការនេះ ក៏ជ្រើសតាំងគណៈកម្មាធិការផ្សេងៗ ឬ ក្រុមប្រឹក្សាយោបល់ដើម្បីគាំទ្រដល់ដំណើរការអនុវត្តសេចក្តីសម្រេច និងទទួលរបាយការណ៍ពីពួកគេវិញ។

លក្ខន្តិកៈរបស់សហគមន៍កសិកម្មនេះ ពន្យល់អំពីសិទ្ធិនិងភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ។ សិទ្ធនិងភារកិច្ចមួយចំនួនរបស់គណៈកម្មាធិការត្រួតពិនិត្យ មានដូចខាងក្រោម៖

**ភារកិច្ចរបស់គណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល**

- អនុវត្តគោលការណ៍ ដែលបានដាក់ចេញដោយមហាសន្និបាត

- ធានាថា សហគមន៍កសិកម្មនេះ មិនខកខានក្នុងការសងបំណុល ឬ មិនក្លាយជាបុគ្គលជាប់បំណុល
- ធានាថា សមាជិកគណៈកម្មាធិការ មិនប្រកបអាជីវកម្មដូចគ្នាទៅនឹងសហគមន៍កសិកម្ម
- ធានាថា សមាជិកចូលរួមក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការត្រួតពិនិត្យ
- ទទួល សិក្សា និងវិភាគរបាយការណ៍សវនកម្ម និងរបាយការណ៍អធិការកិច្ចឱ្យបានគ្រប់ជ្រុងជ្រោយ
- ចាត់វិធានការលើការជំទាស់ណាមួយដែលបានលើកឡើង និងការផ្តល់មតិយោបល់/ការស្នើសុំរបស់សមាជិក
- យល់ដឹងអំពីរាល់ការផ្លាស់ប្តូរ និងការអភិវឌ្ឍន៍ថ្មីៗ នៅក្នុងច្បាប់ វិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីសហគមន៍កសិកម្ម
- យល់ដឹងអំពីសៀវភៅ ផែនការបង្កើតអាជីវកម្ម គម្រោង និង ថវិការបស់សហគមន៍
- ទទួល វិភាគ និងអនុម័ត/បដិសេធការអនុវត្តឥណទានរបស់សមាជិក
- បើកកិច្ចប្រជុំទាំងអស់ឱ្យបានទាន់ពេលវេលា និងរៀបចំការបោះឆ្នោត
- ព្រមាន ឬ ចាត់វិធានការលើសមាជិកដែលបានខ្ចីឥណទាន ប៉ុន្តែសងវិញមិនបានទាន់ពេលវេលា
- ធានាថា រាល់ការសម្រេចចិត្តផ្នែកធុរកិច្ចទាំងអស់ ដែលត្រូវរក្សាការសម្ងាត់ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ
- ទទួលការស្នើសុំពីសមាជិក និងដោះស្រាយបញ្ហារបស់ពួកគេ
- រក្សាទំនាក់ទំនងជិតស្និទ្ធជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងធនាគារសហគមន៍ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់
- ទប់ស្កាត់ការទាញយកប្រយោជន៍ផ្ទាល់ខ្លួន និងធានាថា បន្ទុកចំណាយផ្ទាល់ខ្លួន មិនត្រូវឱ្យលាយឡំជាមួយសហគមន៍កសិកម្មឡើយ។

សិទ្ធិរបស់គណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល

- ទទួលព័ត៌មានធុរកិច្ចរបស់សហគមន៍កសិកម្មទាំងអស់ពីអ្នកគ្រប់គ្រង/លេខាធិការ
- ស្វែងរកការស្នើសុំ និងដំបូន្មានពីអ្នកគ្រប់គ្រង/លេខាធិការ មុនពេលធ្វើការសម្រេចចិត្ត

- ទទួលនិងសិក្សាអំពីរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ យ៉ាងហោចណាស់មួយថ្ងៃនៅមុនពេលចាប់ផ្តើម
- បង្ហាញទស្សនៈ និងការស្នើសុំផ្ទាល់ខ្លួនឱ្យបានច្បាស់លាស់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការ
- ត្រួតពិនិត្យរបាយការណ៍ប្រចាំខែ ឬ ប្រចាំត្រីមាស របស់អ្នកគ្រប់គ្រង ដែលពាក់ព័ន្ធនឹងរាល់គ្រប់ទិដ្ឋភាពទាំងអស់
- ធានាថា ចំណាយរបស់សហគមន៍កសិកម្មមិនលើសពីគម្រោងថវិកា និងត្រូវមានការបញ្ជាក់ និងការស្នើសុំ ព្រមទាំងត្រូវផ្តល់អនុសាសន៍អំពីវិធានការសមរម្យ
- ត្រួតពិនិត្យសៀវភៅគណនេយ្យ សាច់ប្រាក់ និងសន្និធិ ឱ្យបានទៀងទាត់ តាមរយៈការត្រួតពិនិត្យដែលជូនដំណឹងជាមុន ឬ មិនជូនដំណឹងជាមុន
- គោរពតាមការជំទាស់នៅក្នុងរបាយការណ៍សវនកម្ម និងរៀបចំរបាយការណ៍អនុលោមភាព
- រៀបចំវិធាននិងបទបញ្ញត្តិនៃការគ្រប់គ្រង លក្ខខណ្ឌការងាររបស់បុគ្គលិកផ្សេងៗ ការគ្រប់គ្រងអចនទ្រព្យ និងផ្តល់ការស្នើសុំសម្រាប់កែលម្អ
- ចាត់វិធានការលើសមាជិកទាំងឡាយដែលខ្ចីឥណទានពីសហគមន៍កសិកម្ម ប៉ុន្តែមិនសងវិញទាន់ពេលវេលា និងមិនប្រកបអាជីវកម្មជាមួយសហគមន៍កសិកម្ម និងអ្នកដែលរិះគន់ការប្រព្រឹត្តទៅរបស់សហគមន៍កសិកម្ម និងមន្ត្រីទទួលបន្ទុក។

*ចំណុចសម្រាប់ការពិភាក្សា*

- តើអ្នកណាទទួលពាក្យស្នើសុំឥណទាន ពិចារណា សម្រេច ឬ បដិសេធឥណទាន?
- តើអ្នកណាត្រូវរងការខូចខាត ប្រសិនបើឥណទានមិនត្រូវបានសងទាន់ពេលវេលា?
- តើយើងចាំបាច់ត្រូវផ្តល់ហេតុផលទៅឱ្យអ្នកស្នើសុំ សម្រាប់ការបដិសេធពាក្យស្នើសុំឥណទានដែរឬទេ?
- តើអ្នកណាជ្រើសតាំងប្រធានសហគមន៍កសិកម្ម?
- តើបុគ្គលិកសហគមន៍កសិកម្ម ឬ ក៏នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ដែលជាលេខាធិការ?
- តើអ្នកធ្លាប់បានទទួល និងសិក្សាអំពីរបាយការណ៍ប្រចាំឆ្នាំ/របាយការណ៍សវនកម្ម របស់សហគមន៍កសិកម្មអ្នកដែរឬទេ?

# ជំពូកទី ១៤
# គណៈកម្មាធិការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម

គណៈកម្មាធិការត្រួតពិនិត្យ ត្រូវបានជ្រើសរើសដោយផ្ទាល់តាមរយៈកិច្ចប្រជុំមហាសន្និបាត។ គណៈកម្មាធិការត្រួតពិនិត្យត្រូវបើកកិច្ចប្រជុំ ដែលដឹកនាំដោយប្រធានគណៈកម្មាធិការ ឬ ការស្នើសុំសំឡេង២/៣ របស់សមាជិក ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានគណៈកម្មាធិការត្រូវយកទៅអនុត្ត។ សមាជិកគណៈកម្មាធិការត្រួតពិនិត្យអាចចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងសមត្ថកិច្ចជាអ្នកផ្តល់ប្រឹក្សាយោបល់។

គណៈកម្មាធិការត្រួតពិនិត្យ ត្រូវមានសិទ្ធិ និងបំពេញភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យ ឬ បញ្ជាឱ្យត្រួតពិនិត្យសៀវភៅធំគណនេយ្យ និងសៀវភៅគណនេយ្យផ្សេងទៀតរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យ ឬ បញ្ជាឱ្យត្រួតពិនិត្យរាល់ទ្រព្យសកម្ម និងបំណុលរបស់សហគមន៍កសិកម្ម
- ត្រួតពិនិត្យបញ្ជីសារពើភណ្ឌ និងតារាងតុល្យការ តាមការចាំបាច់
- បញ្ជូនលទ្ធផលដែលរកឃើញទៅក្រុមប្រឹក្សាភិបាល និងបញ្ចូលលទ្ធផលទាំងនោះចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ដើម្បីដាក់ជូនអង្គមហាសន្និបាត។

ក្នុងករណីដែលមានបញ្ហាបន្ទាន់ ឬ សមាជិកភាគច្រើននៃក្រុមប្រឹក្សាភិបាល យល់ឃើញថា ខ្លួនឯងគ្មានសមត្ថភាពអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនទេនោះ គណៈកម្មាធិការត្រួតពិនិត្យត្រូវស្នើទៅប្រធានក្រុមប្រឹក្សាភិបាល ដើម្បីកោះប្រជុំវិសាមញ្ញដោះស្រាយបញ្ហានេះ។

សមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ មិនត្រូវមានប្រាក់បៀវត្សរ៍ទេ។ ទោះជាយ៉ាងណា មហាសន្និបាតនេះ អាចបែងចែកថវិកាផ្នែកណាមួយ ដើម្បីទូទាត់ចំណាយបេសកកម្ម និង ប្រាក់ឧបត្ថម្ភ/ប្រាក់លើកទឹកចិត្តសម្រាប់សមាជិក។

***ចំណុចសម្រាប់ការពិភាក្សា***

- តើអ្នកណាជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ?
- តើគណៈកម្មាធិការត្រួតពិនិត្យស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលដែរឬទេ?
- តើគណៈកម្មាធិការត្រួតពិនិត្យមានមុខងារដូចក្រុមប្រឹក្សាភិបាលដែរឬទេ?
- តើអ្នកណាអាចដកសមាជិកគណៈកម្មាធិការត្រួតពិនិត្យ?

-------------------------------------

# ជំពូកទី ១៥
# សិទ្ធិ និងភារកិច្ចរបស់អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ និងបុគ្គលិកផ្សេងទៀត

មហាសន្និបាតសហគមន៍កសិកម្ម បោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យដែលអនុវត្ត គោលការណ៍ដូចបានកំណត់នៅក្នុងកិច្ចប្រជុំមហាសន្និបាត។ គោលការណ៍ទូទៅត្រូវបានដាក់បញ្ចូល ទៅក្នុងផែនការសកម្មភាព ដែលអាចអនុវត្តបាន និងត្រូវអនុវត្តតាមរយៈបុគ្គលិកដែលបានជ្រើសតាំង ដោយគណៈកម្មាធិការត្រួតពិនិត្យ។ គណៈកម្មាធិការនេះ ជួលអ្នកគ្រប់គ្រងទូទៅម្នាក់ ដើម្បីធ្វើជា បណ្តាញទំនាក់ទំនងដ៏សំខាន់រវាងសមាជិក និងសហគមន៍កសិកម្ម។ អ្នកគ្រប់គ្រងទូទៅមានភារកិច្ចដូច ខាងក្រោម៖ រៀបចំផែនការសកម្មភាព ថែរក្សាសៀវភៅគណនេយ្យ និងសៀវភៅផ្សេងទៀត ក៏ដូចជា ទ្រព្យសកម្មរបស់សហគមន៍កសិកម្ម រក្សាទំនាក់ទំនងជាមួយសមាជិក ធ្វើការងារជាមួយមន្ត្រីទទួល បន្ទុកដែលបានជ្រើសរើស រក្សាទំនាក់ទំនងជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម និងធនាគារ សហគមន៍ គ្រប់គ្រងដំណើរការកិច្ចប្រជុំ។ល។ អ្នកគ្រប់គ្រងត្រូវបានជ្រើសរើសចេញពីទីផ្សារបើកចំហរ ដោយគណៈកម្មាធិការ។

***ភារកិច្ចរបស់អ្នកគ្រប់គ្រង/នាយកប្រតិបត្តិ***

- បម្រើសហគមន៍កសិកម្ម ក្នុងនាមជាបុគ្គលិកឧស្សាហ៍ព្យាយាម ស្មោះត្រង់ និងមានការតាំង ចិត្តខ្ពស់
- ផ្តល់ការណែនាំ ដំបូន្មាន និងការគាំទ្រទៅដលគណៈកម្មាធិការត្រួតពិនិត្យ
- យល់ដឹង និងអាចផ្តល់ព័ត៌មានអំពីច្បាប់ វិធាន និងបទបញ្ញត្តិស្តីពីសហគមន៍កសិកម្មឱ្យបានគ្រប់ ជ្រុងជ្រោយ និងបទបញ្ញត្តិអំពីលក្ខន្តិកៈទៅឱ្យមន្ត្រីទទួលបន្ទុកសហគមន៍កសិកម្ម
- ថែរក្សា និងទុកដាក់សៀវភៅគណនេយ្យ សាច់ប្រាក់ និងសន្និធិ ព្រមទាំងសេវាកម្មនិងមុខរបរ ផ្សេងៗទាំងអស់របស់សហគមន៍កសិកម្ម
- រៀបចំផែនការបង្កើតអាជីវកម្ម គម្រោងថវិកា និងរបាយការណ៍ចំណូលនិងចំណាយរបស់ សហគមន៍កសិកម្ម និងដាក់ជូនរបាយការណ៍ប្រចាំខែ របាយការណ៍ប្រចាំត្រីមាស និង របាយការណ៍ប្រចាំឆ្នាំ
- រក្សា និងធ្វើបច្ចុប្បន្នភាពសៀវភៅប្រាក់បញ្ញើ និងគណនីផ្ទាល់ខ្លួនទាំងអស់របស់សមាជិក

- កំណត់កម្រិតឥណទានអតិបរមា [MCL] របស់សមាជិក ដូចមានចែងក្នុងបទប្បញ្ញត្តិរបស់ធនាគារសហគមន៍ និងដាក់ឱ្យគណៈកម្មាធិការត្រួតពិនិត្យ និងមហាសន្និបាតធ្វើការអនុម័ត
- រៀបចំបញ្ជីសមាជិកដែលខកខានក្នុងការសងបំណុល និងអនុវត្តតាមបែបបទសម្រាប់ការទារបំណុល
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការទាំងអស់ លើកលែងតែករណីពិចារណាលើតម្លៃ និងសេវាកម្មរបស់បុគ្គលមួយចំនួន
- ធានាថា អ្នកគ្រប់គ្រងមិនទុកសៀវភៅបញ្ជីប្រាក់បញ្ញើ និងចុះហត្ថលេខាលើសៀវភៅមូលប្បទានបត្ររបស់សមាជិក
- ចេញបង្កាន់ដៃបង់ប្រាក់ទៅឱ្យសមាជិកសម្រាប់ចំណាយទាំងអស់របស់សមាជិក
- ធ្វើការត្រួតពិនិត្យលើទ្រព្យសកម្ម និងបំណុលទាំងអស់របស់សហគមន៍កសិកម្ម
- ធ្វើការផ្ទៀងផ្ទាត់ជាក់ស្តែងលើបញ្ជីសារពើភណ្ឌទាំងអស់ ដូចជា អចនទ្រព្យ ឃ្លាំងស្តុកទំនិញ ម៉ាស៊ីន និងឧបករណ៍ការិយាល័យ
- សុំការឯកភាពលើការរក្សា "សាច់ប្រាក់ក្នុងដៃ" និងសាច់ប្រាក់លើស ដើម្បីយកទៅផ្ញើនៅធនាគារ
- គ្រប់គ្រងត្រារបស់សហគមន៍កសិកម្ម និងឧបករណ៍/សម្ភារផ្សេងទៀត សម្រាប់ការទូទាត់
- សរសេរបញ្ជីប្រាក់ចេញចូល និងសៀវភៅធំរៀងរាល់ថ្ងៃច័ន្ទ
- តម្កល់មូលប្បទានបត្រទាំងអស់របស់សហគមន៍កសិកម្ម នៅធនាគារ និងរក្សាគណនីទាំងនោះឱ្យបានត្រឹមត្រូវ
- រៀបចំផ្ទៀងផ្ទាត់គណនីរបស់សហគមន៍ជាមួយធនាគារសហគមន៍កសិកម្ម
- ធានាថា រាល់ការទូទាត់ទៅឱ្យអ្នកលក់ និងសមាជិក ត្រូវបានធ្វើឡើងទាន់ពេលវេលា
- រៀបចំបញ្ជីសមាជិក និងសម្របសម្រួលដំណើរការបោះឆ្នោតនៅក្នុងសហគមន៍កសិកម្ម
- រៀបចំរបៀបវារៈ កំណត់ហេតុរបៀបវារៈ កំណត់ហេតុកិច្ចប្រជុំ និងរៀបចំការចែកចាយរបស់ខ្លួនឱ្យបានត្រឹមត្រូវ
- រៀបចំរបាយការណ៍សវនកម្ម និងដាក់ជូនអ្នកចុះបញ្ជី RCS បន្ទាប់ពីទទួលបានការអនុម័តពីគណៈកម្មាធិការត្រួតពិនិត្យ

- រៀបចំតារាងតុល្យការរបស់សហាគមន៍កសិកម្ម និងដាក់ជូនគណៈកម្មាធិការត្រួតពិនិត្យធ្វើការអនុម័ត
- រៀបចំបញ្ជីសមាជិកដែលខកខានក្នុងការសងប្រាក់ និងចេញសេចក្តីជូនដំណឹងអំពីការទារបំណុល
- រៀបចំលក្ខខណ្ឌការងារ សម្រាប់និយោជិតទាំងអស់
- ជួយបង្កើតទំនាក់ទំនងជិតស្និទ្ធរាក់ទាក់គួរសមរវាងសមាជិក និងគណៈកម្មាធិការត្រួតពិនិត្យ

*សិទ្ធិរបស់អ្នកគ្រប់គ្រង*

- ប្រើប្រាស់សម្ភារទាំងអស់ ដែលផ្តល់ឱ្យដោយសហាគមន៍ដែលអាចជួយឱ្យអ្នកគ្រប់គ្រងបំពេញមុខងាររបស់ខ្លួនដោយត្រឹមត្រូវ
- ស្នើសុំការកែលម្អប្រតិបត្តិការរបស់សហាគមន៍និងលក្ខខណ្ឌការងាររបស់និយោជិត

*ចំណុចសម្រាប់ការពិចារណា*

- តើអ្នកគ្រប់គ្រងអាចចូលរួមក្នុងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការត្រួតពិនិត្យដែរឬទេ?
- តើអ្នកគ្រប់គ្រងអាចអនុម័ត/បដិសេធពាក្យស្នើសុំខ្ចីប្រាក់របស់សមាជិក ដោយខ្លួនឯងបានដែរឬទេ?
- តើអ្នកគ្រប់គ្រងគួររក្សាទុកសៀវភៅប្រាក់បញ្ញើ ឬសៀវភៅមូលប្បទានបត្ររបស់បុគ្គលិកដោយខ្លួនឯង?

## ជំពូកទី១៦
## សៀវភៅស្តីពីសហាគមន៍កសិកម្ម

តាមការចុះបញ្ជីនៅក្រោមច្បាប់ស្តីពីសហាគមន៍កសិកម្មដើម្បីក្លាយជានីតិបុគ្គលស្របច្បាប់ គឺតម្រូវតម្រូវឱ្យសហាគមន៍កសិកម្មរក្សាទុកសៀវភៅនិងឯកសារចុះបញ្ជីទាំងអស់នោះ។

ដោយសារសហាគមន៍កសិកម្មជាសហគ្រាសពាណិជ្ជកម្ម មានប្រតិបត្តិការអាជីវកម្មយ៉ាងច្រើនមិនត្រឹមតែជាមួយសមាជិក និងនិយោជិតប៉ុណ្ណោះទេ ថែមទាំងជាមួយអ្នកផ្សេងៗទៀតដូចជា ធនាគារ

សហគមន៍ អ្នកផ្គត់ផ្គង់ទិន្នផលកសិកម្ម ឈ្មួញ អ្នកផ្តល់សេវាកម្ម គម្រោងទាក់ទងសហគមន៍កសិកម្ម។ល។ ការទូទាត់ទាំងអស់ មិនថាការទូទាត់តាមរយៈមូលប្បទានបត្រ ឬជាសាច់ប្រាក់ទេ ត្រូវបានធ្វើឡើង។ សហគមន៍កសិកម្មត្រូវរក្សាសៀវភៅចុះឈ្មោះ និងសៀវភៅគណនីឱ្យបានសមរម្យ។
បញ្ជីជ្រើសរើសនៃសៀវភៅនិងមុខទំនិញមួយចំនួនដែលត្រូវរក្សាទុកក្នុងអង្គការសហគមន៍មានដូចខាងក្រោម៖

- បញ្ជីចុះឈ្មោះសមាជិក
- បញ្ជីប្រាក់ចេញចូល សៀវភៅមូលប្បទានបត្រ/សៀវភៅបញ្ជីប្រាក់ និងសៀវភៅបញ្ជីប្រាក់សម្រាប់សមាជិក/អ្នកកក់ប្រាក់នីមួយៗ
- ត្រាសហគមន៍កសិកម្ម
- ទូរក្សាសាច់ប្រាក់
- សៀវភៅធំ និងសៀវកំណត់ហេតុប្រចាំថ្ងៃ
- សៀវភៅធំសម្រាប់សមាជិកនីមួយៗ អ្នកកក់ប្រាក់ អ្នកដាក់ប្រាក់ ចំណូលនិងចំណាយផ្សេងៗ និងមិនបានព្រាង និងការទិញនិងលក់ទំនិញ។ល។
- តារាងតុល្យការ
- របាយការណ៍សវនកម្ម និងរបាយការណ៍សមស្របរបស់ខ្លួន
- សៀវភៅកំណត់សម្គាល់
- សៀវភៅប្រាក់ចំណូល
- រដ្ឋធម្មនុញ្ញដែលថ្មីចុងក្រោយ ដែលមានការដាក់បញ្ចូលនូវអ្វីដែលធ្វើវិសោធនកម្មរួចទាំងអស់
- បញ្ជីការចលនាទំនិញ
- សៀវភៅកត់ត្រាយានយន្តចេញចូល
- បញ្ជីភាគហ៊ុន ឬបញ្ជីការភាគហ៊ុន
- បញ្ជីឈ្មោះអ្នកធានា
- បញ្ជីបង្ហាញMCLរបស់សមាជិក
- កំណត់ហេតុសាច់ប្រាក់ដែលភ្ជាប់ជាមួយឯកសារចម្លង
- សៀវភៅភ្ញៀវ
- បញ្ជីផ្សេងទៀតដែលកំណត់ដោយអ្នកកាន់បញ្ជីឬតម្រូវដោយសហគមន៍កសិកម្ម

គោលការណ៍សំខាន់មួយសម្រាប់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងមានតម្លាភាព គឺថាសមាជិកត្រូវមានទំនុកចិត្តលើគ្គទំនាក់ទំនងហិរញ្ញវត្ថុរបស់ពួកគាត់ជាមួយសហគមន៍កសិកម្ម។

មិនគួរមានដំណើរការ ឬនីតិវិធីតាមបែបការិយាល័យប្រជាធិបតេយ្យ។ សមាជិកគឺជាម្ចាស់ពិតប្រាកដ ដូច្នេះហើយពួកគេស្វែងរកសេវាកម្មដែលមានប្រសិទ្ធភាពពីសហគមន៍កសិកម្ម។

សៀវភៅគណនីនិងប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ត្រូវធ្វើបច្ចុប្បន្នភាព។

នៅពេលទូទាត់ប្រាក់ឱ្យសហគមន៍កសិកម្ម សមាជិកត្រូវទទួលបានបង្កាន់ដៃបង់ប្រាក់។

និយោជិតត្រូវធានាថាលុយផ្ទាល់ខ្លួន និងលុយរបស់មន្ត្រីត្រូវបានទុកដាក់ផ្សេងគ្នា។

ឯកសារ និងបញ្ជីទាំងអស់ចាំបាច់ត្រូវរក្សាទុកឱ្យមានសណ្តាប់ធ្នាប់ អាចរកបាន និងមានបច្ចុប្បន្នភាព។ ឯកសារទាំងនេះជួយឱ្យយើងរៀបចំរបាយការណ៍គ្រប់ជ្រុងជ្រោយសម្រាប់ដាក់ជូន និងអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយគណៈកម្មាធិការត្រួតពិនិត្យក៏ត្រូវការឯកសារទាំងនេះដែរ។ ឯកសារទាំងនេះត្រូវរៀបចំឱ្យហើយមុនពេលអ្នកកាន់បញ្ជីទាមទារយក។

*ចំណុចសម្រាប់ការពិភាក្សា*

- តើអ្នកទទួលបានបង្កាន់ដៃបង់ប្រាក់ភ្លាមៗនៅពេលទូទាត់ប្រាក់ជាមួយសហគមន៍កសិកម្មដែរឬទេ?
- តើការទុកទូរក្សាសាច់ប្រាក់នៅការិយាល័យសហគមន៍កសិកម្ម ឬនៅផ្ទះប្រធាន/លេខាមានសុវត្ថិភាពដែរឬទេ?
- តើអ្នកយល់ពីស្ថានភាពមុខរបររបស់សហគមន៍កសិកម្មរបស់អ្នកតាមរយៈតារាងតុល្យការដែរឬទេ?
- តើអ្នកកាន់កាប់សៀវភៅបញ្ញើប្រាក់/ប័ណ្ណឥណទាន/សៀវភៅមូលប្បទានបត្រដែលចេញដោយសហគមន៍កសិកម្មដែរឬទេ?
- តើអ្នកធ្លាប់ចុះហត្ថលេខាក្នុងបញ្ជីចុះឈ្មោះសមាជិកដែលរក្សាទុកនៅក្នុងសហគមន៍កសិកម្មដែរឬទេ?

## ជំពូកទី ១៧
## ការបង្កើតដើមទុន
## នៅក្នុងសហគមន៍កសិកម្ម

សហគមន៍កសិកម្ម គឺជាសហគ្រាសអាជីវកម្មមួយដែលមានភាពខុសគ្នាពីសហគ្រាស់ឯកជនត្រង់សមាជិកទាំងអស់ជាម្ចាស់កម្មសិទ្ធិ មានការដឹកនាំ និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ សមាជិក គឺជាអ្នកធ្វើការសម្រេចចិត្តដូចនឹងនិយោជកអីចឹងដែរ។ សហគមន៍កសិកម្មទូទាំងពិភពលោកផ្តល់ការងារដល់មនុស្សបានច្រើនជាងក្រុមហ៊ុនពហុជាតិ [MNC] ទាំងអស់ដែលបញ្ចូលគ្នានៅក្នុងពិភពលោក។ ពួកគេគឺជាម្ចាស់អចលនទ្រព្យធំបំផុត និងមានវត្តមាននៅគ្រប់ច្រកល្ហកទាំងអស់នៃពិភព

លោករហូតដល់ថ្នាក់ភូមិ។ សហគមន៍កសិកម្មទាំងនោះមានជាទម្រង់ផ្សេងៗគ្នា។ ពួកគេត្រូវការមូលនិធិសម្រាប់ប្រតិបត្តិការរបស់ខ្លួន។ ដោយគ្រាន់តែប្រមូលថ្លៃចូលជាសមាជិក និងប្រាក់ភាគហ៊ុន និងការទទួលប្រាក់បញ្ញើតូចៗពីសមាជិក គឺមិនគ្រប់គ្រាន់ទេ។

ដូច្នេះសហគមន៍កសិកម្មបានអនុម័តវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ដើម្បីបង្កើតមូលនិធិសម្រាប់ប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនៈ

- តាមរយៈការលក់ភាគហ៊ុនទៅឱ្យសមាជិក ដោយផ្តល់ប្រាក់ និងភាគលាភដល់គាត់
- ការស្នើឱ្យសមាជិកដាក់ប្រាក់បញ្ញើ ឧទាហរណ៍ដូចជា ប្រាក់បញ្ញើសន្សំធម្មតា ប្រាក់បញ្ញើដែលមានកាលកំណត់ និងប្រាក់បញ្ញើសន្សំដែលជាកំហិត
- កម្ចីពីធនាគារសហគមន៍ រដ្ឋាភិបាល និងវិនិយោគិនឯកជន
- រដ្ឋាភិបាល ក៏ផ្តល់មូលនិធិដល់ដល់សហគមន៍កសិកម្មសម្រាប់គោលបំណងផ្សេងៗផងដែរ
- ការទទួលបានកម្រៃជើងសាសមស្រប / ស្របច្បាប់លើការលក់ / ទិញ និងសេវាកម្ម
- ជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាល និង / ឬ ស្ថាប័នដែលទទួលបានការអនុម័តទទួលស្គាល់ដោយរដ្ឋាភិបាល។

  ជាអនុសាសន៍មិនគួរមានការរៃអង្គាសមូលនិធិពីទីផ្សារសេរី ដោយគ្មានការអនុម័តពីមហាសន្និបាត និងរដ្ឋាភិបាលឡើយ។

*ចំណុចសម្រាប់ការពិភាក្សា*

- មួយណាជាវិធីសាស្ត្រល្អបំផុតក្នុងការបង្កើតមូលនិធិសម្រាប់សហគមន៍កសិកម្ម?
- តើសហគមន៍កសិកម្មអាចដាក់ចេញគម្រោងដាក់ប្រាក់បញ្ញើសន្សំជាកំហិតដើម្បីទទួលបានថវិកាដែរទេ?
- តើអ្វីខ្លះជាគ្រោះថ្នាក់នៃការទទួលបានមូលនិធិដែលទទួលបានពីទីផ្សារសេរី?

---

## ជំពូក ១៨
## សេវាកម្មផ្តល់ដោយ
## សហគមន៍កសិកម្ម

សមាជិកបង្កើតសហគមន៍កសិកម្មដើម្បីជួយខ្លួនឯង។ ដោយសារតែសមាជិកពិបាកទទួលបានរាល់សេវាកម្មទាក់ទងនិងកសិដ្ឋានរបស់ពួកគេ ដែលបង្កើតជាសហគមន៍កសិកម្មឡើងដើម្បីទាញយកប្រយោជន៍ពីសកម្មភាពសមូហភាព ពីព្រោះពួកគេអាចមានសិទ្ធិអំណាចក្នុងការចរចា។ សហគមន៍

កសិកម្មអាចផ្តល់សេវាផ្សេងៗដល់សមាជិករបស់ខ្លួន។ តាមពិត គឺសមាជិកជាអ្នកដែលត្រូវស្នើសុំឱ្យសហគមន៍កសិកម្មផ្តល់សេវា។

សេវាកម្មមួយចំនួនដែលផ្តល់ដោយសហគមន៍មានដូចខាងក្រោម៖

- សេវាកម្មហិរញ្ញវត្ថុ៖ សេវាប្រាក់បញ្ញើ ប្រាក់កម្ចី និងធានារ៉ាប់រង
- សេវាកម្មផលិតកម្មកសិកម្ម និងតម្លៃបន្ថែម៖ ផ្គត់ផ្គង់ជី ពូជដែលមានគុណភាពល្អ ថ្នាំគីមីកសិកម្ម ឧបករណ៍កសិកម្ម បច្ចេកវិទ្យាកសិកម្ម ។ល។
- សេវាកម្មទីផ្សារ និងការកែច្នៃ៖ សមាជិកលក់ផលិតផលកសិកម្ម និងសាកវប្បកម្មដែលលើសរបស់ខ្លួនតាមរយៈសហគមន៍កសិកម្ម។ សហគមន៍កសិកម្មក៏ត្រូវធ្វើសកម្មភាពកែច្នៃជូនសមុខឱ្យសមាជិករបស់ខ្លួនផងដែរ។
- សេវាប្រើប្រាស់៖ ការផ្គត់ផ្គង់សំភារៈកសិកម្ម ទំនិញប្រើប្រាស់ក្នុងគ្រួសារ ។ល។
- សេវាកម្មសុខុមាលភាពសហគមន៍កសិកម្ម៖ ជាសេវាកម្មពាក់ព័ន្ធនឹងសហគមន៍កសិកម្ម ឧទាហរណ៍ការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ទទួលទាន អំពូលភ្លើងបំភ្លឺផ្លូវ ផ្លូវនៅជនបទ ការថែទាំសត្វ ទារកដ្ឋាន ប្រព័ន្ធលូ និងសន្តិសុខក្នុងមូលដ្ឋាន។ល។

សហគមន៍កសិកម្ម គឺជាស្ថាប័នផ្តល់សេវាកម្មសម្រាប់កសិករ។ មុខងារសំខាន់របស់ពួកគេក្នុងនាមជាសហគ្រាសអាជីវកម្មសហគមន៍កសិកម្មពហុគោលបំណងមានដូចជា៖ ការផ្តល់ឥណទានសហគមន៍កសិកម្ម / មិនមែនកសិកម្មដល់កសិករ ការផ្សព្វផ្សាយលក់ផលិតផលរបស់សមាជិករួមទាំងតម្លៃបន្ថែមផង ការផ្គត់ផ្គង់ធនធានកសិកម្មដូចជាជី គ្រាប់ពូជល្អ គ្រឿងចក្រ និងឧបករណ៍កសិកម្ម និងគោលការណ៍ណែនាំរួមទាំងសេវាកម្មផ្សព្វផ្សាយ សេវាកម្មផ្តល់ប្រឹក្សាអំពីការរស់នៅល្អប្រសើរ ការធ្វើផែនការផលិតកម្ម និងការធានារ៉ាប់រងផងដែរ។ ផ្អែកលើទំហំសមាជិកភាព និងតំបន់ធ្វើប្រតិបត្តិការសហគមន៍កសិកម្មអាចពង្រីកសេវារបស់ខ្លួនតាមរយៈការបើកសាខា និងការផ្តល់សេវាកម្មបន្ថែមទៀតដែលសមាជិកត្រូវការ។

ផ្អែកលើតម្រូវការទូទៅ និងជាក់លាក់របស់សមាជិក និងសហគមន៍ សហគមន៍កសិកម្មក៏អាចផ្តល់សេវានៅតាមមូលដ្ឋាន និងសេវាសុខុមាលភាពផ្សេងៗទៀតដែរ។ សហគមន៍កសិកម្ម គឺជាសហគ្រាសអាជីវកម្ម ហេតុដូច្នេះហើយសេវាទាំងអស់ដែលផ្តល់ ត្រូវគិតថ្លៃ ប៉ុន្តែជាតម្លៃសមរម្យ។ វាត្រូវបានចងចាំថា សហគមន៍កសិកម្មមិនមែនជាស្ថាប័នសប្បុរសធម៌នោះទេ។

*ចំណុចសម្រាប់ការពិភាក្សា*

- តើអ្នកដឹងអំពីសេវាកម្មដែលផ្តល់ដោយសហគមន៍កសិកម្មអ្នកដែរទេ?

- តើសេវាកម្មប្រភេទណាដែលអ្នកអាចទទួលបានពីសហាគមន៍កសិកម្មរបស់អ្នក?
- តើសេវាកម្មប្រភេទណាដែលចង់អោយសហាគមន៍កសិកម្មរបស់អ្នកផ្តល់ជូន?
- តើអ្នកសុខចិត្តបង់ថ្លៃសេវាកម្មដែរទេ?

---------------------------------------------------------------------------

# ជំពូកទី ១៩
# សេវាកម្មឥណទានផ្តល់ដោយ
# សហគមន៍កសិកម្ម

មនុស្សជាច្រើននៅមិនទាន់ដឹងអំពីសេវាកម្ម និង អត្ថប្រយោជន៍ដែលខ្លួនអាចទទួលពីសហាគមន៍កសិកម្ម។ ជាលទ្ធផល សមាជិកសហាគមន៍កសិកម្មជាច្រើន ឬអ្នកដែលប្រាថ្នាចង់ក្លាយជាសមាជិក មិនអាចទទួលបានអត្ថប្រយោជន៍ពីសហាគមន៍កសិកម្មឡើយ។ ហេតុដូច្នេះហើយ វាជាកត្តាពាក់ព័ន្ធសំខាន់ និងពាក់ព័ន្ធដែលត្រូវប្រាប់ពួកគេអំពីអត្ថប្រយោជន៍ នៃការធ្វើអាជីវកម្មជាមួយសហាគមន៍កសិកម្ម និងសេវាកម្មដែលពួកគេអាចផ្តល់ជូន។ សមាជិកដែលមានការយល់ដឹង និងទទួលបានព័ត៌មានគ្រប់គ្រាន់ អាចប្រើប្រាស់សេវាកម្មរបស់សហាគមន៍បានល្អ។ បន្ទាប់មក វាគឺជារឿងសំខាន់ដែលសមាជិកទទួលបានព័ត៌មាន និងការអប់រំអំពីទស្សនវិជ្ជាស្តីពីកិច្ចសហប្រតិបត្តិការ ព្រមទាំងសេវាកម្មដែលអាចផ្តល់ជូនបាន ដើម្បីឱ្យពួកគេមានជីវភាពរស់នៅកាន់តែ
ប្រសើរ។

សហាគមន៍កសិកម្មមានសមត្ថភាពផ្តល់ឥណទានដែលជួយធ្វើឱ្យប្រសើរឡើងផ្នែកផលិតភាព និងផលិតកម្ម ការផ្គត់ផ្គង់ធនធានកសិកម្មល្អៗដូចជា ជី ពូជ និងគីមីកសិកម្ម ការគាំទ្រផ្នែកទីផ្សារនៅក្នុងការលក់ផលិតផលរបស់ពួកគេក្នុងតម្លៃល្អសមរម្យ និងការផ្សព្វផ្សាយអំពីបច្ចេកវិទ្យាកសិកម្ម។ ឥណទានគឺជាសេវាកម្មដ៏សំខាន់ដែលសហាគមន៍កសិកម្មផ្តល់ជូនសមាជិករបស់ខ្លួន។ នៅក្នុងពិភពលោក គ្មានកសិករណាដែលថាមិនទទួលយកឥណទានសម្រាប់គោលបំណងកសិកម្មឡើយ។ ឥណានទានក្នុងទីផ្សារសេរី គឺមានអត្រាការប្រាក់ខ្ពស់ និងមានការយឺតយ៉ាវ ប៉ុន្តែការប្រើប្រាស់សហាគមន៍កសិកម្មជាឧបករណ៍ដើម្បីទទួលបានឥណទាន មានអត្ថប្រយោជន៍ត្រង់គេគិតអត្រាការប្រាក់ទាប និងការប្រាក់សងបណ្តាក់ក្នុងករណីមានគ្រោះធម្មជាតិកើតឡើង។

### *សេវាឥណទានផ្តល់ដោយសហគមន៍កសិកម្ម*

*[ក] ឥណទានរយៈពេលខ្លី៖* ត្រៀមសម្រាប់កសិករដាំដុះដែលត្រូវការប្រាក់ ដើម្បីឱ្យពួកគេមានលទ្ធភាពទិញឧបករណ៍កសិកម្ម ជីគីមីកសិកម្ម និងពូជដែលមានគុណភាពល្អ។ សេវាកម្មទាំងនេះផ្តល់ដោយសហគមន៍កសិកម្ម។ ឥណទានដែលផ្តល់ឱ្យសម្រាប់រយៈពេលដាំដុះមួយរដូវ ឱ្យឈ្មោះថា ឥណទានរយៈពេលខ្លី។ ជាធម្មតា សហគមន៍កសិកម្មបឋម ផ្តល់ឥណទានរយៈពេលខ្លី ឬឥណទានសម្រាប់ការដាំដុះ។ ឥណទានត្រូវប្រមូលយកវិញ បន្ទាប់ពីដំណាំប្រមូលផលរួច។

*[ខ] ឥណទានរយៈពេលមធ្យម៖* ឥណទានប្រភេទនេះផ្តល់ជូនសមាជិកសម្រាប់រយៈពេលពី ៣ ឆ្នាំទៅ ៥ ឆ្នាំដើម្បីឱ្យពួកគេមានលទ្ធភាពទិញគោក្របីសម្រាប់អូសទាញ រទេះ សង់ឡជីវឧស្ម័ន ទិញឧបករណ៍កសិកម្មតូចៗ បង្កើតកន្លែងចិញ្ចឹមត្រី ទិញមាន់ទាជាដើម ។ល។ គេរកឃើញថា ភ្លាមៗបន្ទាប់ពីដាំដុះ និងនៅពេលប្រមូលផល បន្ទុកការងារត្រូវបានកាត់បន្ថយ។ ប្រសិនបើកសិករអាចទទួលបានការងារមួយចំនួនផ្សេងទៀត ពេលនោះវានឹងជាការប្រសើរ ពីព្រោះពួកគេអាចរកប្រាក់ចំណូលបានបន្ថែម។ ឥណទានបែបនេះអាចទទួលបានតាមរយៈការក្លាយជាសមាជិករបស់សហគមន៍កសិកម្ម។ ការសងវិញចំពោះឥណទានបែបនេះ ជាទូទៅសងដោយបង់រម្លស់។ ជាធម្មតា ឥណទានរយៈពេលមធ្យម និងរយៈពេលវែង ផ្តល់ដោយធនាគារកណ្តាលសហគមន៍ ឬធានាគារអភិវឌ្ឍន៍ដីធ្លី ឬស្ទូម្បីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។

*[គ] ឥណទានរយៈពេលវែង៖* ឥណទានប្រភេទនេះផ្តល់ជូនសម្រាប់រយៈពេលពី ៥ ឆ្នាំទៅ ១០ ឆ្នាំ។ ឥណទានទាំងនេះត្រូវបានផ្តល់ជូនតាមរយៈធនាគារអភិវឌ្ឍន៍ដីធ្លី។ គោលបំណងនៃឥណទានបែបនេះ គឺដើម្បីកែលម្អប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍជនបទរួមមានទាំងលំនៅដ្ឋាននៅជនបទផងដែរ។ ឥណទាននេះផ្តល់ជូនផ្អែកលើបរិមាណដីដែលសមាជិកមាន ហើយត្រូវសងវិញដោយការបង់រម្លស់។

*[ឃ] ឥណទានប្រើប្រាស់៖* សហគមន៍កសិកម្មផ្តល់ឥណទានបែបនេះទៅដល់សមាជិកដែលទន់ខ្សោយខាងហិរញ្ញវត្ថុ។ ឥណទានបែបនេះត្រូវបានផ្តល់ជូនសម្រាប់គោលបំណងផ្សេងៗ ឧទាហរណ៍ពិធីក្នុងសង្គមជាលក្ខណៈគ្រួសារដូចជាអាពាហ៍ពិពាហ៍ ការអប់រំ មរណភាពជាដើម។ល។ ឥណទានបែបនេះមានរយៈពេលខុសៗគ្នា ហើយអាចសងវិញដោយការរម្លស់បានតាមការសម្រេចរបស់គណៈកម្មការត្រួតពិនិត្យរបស់សហគមន៍កសិកម្ម។

### *នីតិវិធីក្នុងការទទួលឥណទានទាន*

សមាជិកបំពេញទម្រង់បែបបទឈ្មោះថា ‘pronote’ ដែលចាត់ទុកជាកិច្ចសន្យារវាងសមាជិក និងសហគមន៍កសិកម្ម។ ‘pronote’ មានហត្ថលេខារបស់សមាជិក ចំនួនឥណទានដែលត្រូវស្នើសុំ កាល

បរិច្ឆេទ ហត្ថលេខារបស់អ្នកគ្រប់គ្រង និងហត្ថលេខារបស់សាក្សីពីរនាក់។ ឥណទាននេះត្រូវសងទៅសហគមន៍កសិកម្មវិញ ក្រោយពីលក់ផលិតផលរួច។

*ការសងវិញទាន់ពេលកំណត់*

សមាជិកមានកាតព្វកិច្ចត្រូវសងឥណទានវិញរួម ជាមួយការប្រាក់ឱ្យបានទាន់ពេលវេលាដូចមានចែងនៅក្នុងកិច្ចសន្យា។ ការសងវិញទាន់ពេលវេលា មានអត្ថប្រយោជន៍ដូចខាងក្រោមសម្រាប់សមាជិក៖ អាចចូលរួម / ប្រកួតប្រជែងនៅក្នុងដំណើរការបោះឆ្នោតបាន អាចបោះឆ្នោតបាននៅក្នុងដំណើរការបោះឆ្នោត អាចខ្ចីឥណទានឡើងវិញបានពីសហគមន៍កសិកម្ម អាចចៀសផុតពីការពិន័យដោយសារការសងយឺតយ៉ាវ និងថ្លៃប្រមូល អាចចៀសផុតពីដំណើរការមជ្ឈត្តកម្ម និងបទប្បញ្ញត្តិផ្សេងៗទៀតដែលមានចែងនៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្ម អាចចៀសផុតពីការឈឺចាប់ខាងផ្លូវចិត្ត និងឧបសគ្គផ្នែកហិរញ្ញវត្ថុ មានកេរ្តិ៍ឈ្មោះល្អក្នុងសង្គម និងក្លាយជាគំរូគេសម្រាប់សមាជិកផ្សេងៗទៀតសម្រាប់ការសងទាន់ពេលវេលា។

*ការកំណត់ឥណទានមានកម្រិត*

អ្នកគ្រប់គ្រងត្រូវត្រៀមបញ្ជីឥណទានមានកម្រិតរបស់សមាជិកទាំងអស់ជាបីច្បាប់។ សមាជិកទាំងអស់ចាំបាច់ត្រូវតែធ្វើកិច្ចសន្យា មិនថាពួកគេធ្លាប់សងមិនទាន់ពេលវេលា ឬក៏អត់ឡើយ។ ដូចគ្នាដែរ នៅពេលសហគមន៍កំណត់ឥណទានមានកម្រិតអតិបរមារបស់សមាជិកខ្លួន ឥណទានមានកម្រិតរបស់ខ្លួនក៏ត្រូវកំណត់ដោយធនាគារកណ្តាលសហគមន៍កសិកម្ម។ សម្រាប់ឥណានទានដំណាំ ចំនួនឥណទានត្រូវកំណត់ធនាគារកណ្តាលសហគមន៍ ដោយមានការពិគ្រោះជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។ ឥណទានមានកម្រិតអតិបរមារបស់ធនាគារសហគមន៍ ក៏ត្រូវកំណត់ដោយធនាគារសហគមន៍រដ្ឋផងដែរ។

*ការទទួលបានឥណទានមកវិញ*

ប្រសិទ្ធភាពនៃប្រតិបត្តិការមុខរបរសហគមន៍កសិកម្ម ពឹងផ្អែកលើការទទួលបានឥណទានមកវិញ។ ប្រសិនបើឥណទានដែលទទួលបានមកវិញល្អគ្មានបញ្ហា ឆន្ទៈរបស់សហគមន៍កសិកម្មក៏ត្រូវបានចាត់ទុកថាល្អ ហើយស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួនក៏រឹងមាំ។ ក្នុងករណីទទួលបានឥណានទានមកវិញទាបសហគមន៍កសិកម្មនឹងក្លាយជាអ្នកខកខានក្នុងការសងរបស់ធនាគារសហគមន៍ ហើយប្រឈមបញ្ហាក្នុងការរៃអង្គាសមូលនិធិបន្ថែមទៀត។ ដូច្នេះហើយវាជាកត្តាសំខាន់ដែលមិនថាឥណានទានប្រភេទណាទេឱ្យតែទទួលបានពីសមាជិកគួរតែបង្វិលសងទៅធនាគារវិញភ្លាមៗ ដើម្បីឱ្យសេវារបស់ធនាគារអាចបន្តដំណើរការសម្រាប់បម្រើសហគមន៍កសិកម្ម។ ក្នុងករណីដែលសហគមន៍កសិកម្មខកខានក្នុងការ

សងសហគមន៍ត្រូវបង់ការប្រាក់ពិន័យ ហើយវាមិនត្រឹមតែក្លាយជាបន្ទុករបស់សហគមន៍កសិកម្មប៉ុណ្ណោះទេ តែវាក៏ជាបន្ទុករបស់សមាជិកខ្លួនផងដែរ។

***សារៈសំខាន់៖*** *ប្រសិនបើអ្នកមានសិទ្ធិទទួលបានឥណទានពីសហគមន៍កសិកម្ម ពេលនោះអ្នកក៏មានកាតព្វកិច្ចត្រូវសងឥណានទានទៅសហគមន៍កសិកម្មវិញជាមួយនឹងការប្រាក់ឱ្យទាន់ពេលវេលាដែរ។ ដំណើរការនេះគឺដើម្បីអត្ថប្រយោជន៍របស់សមាជិកទាំងអស់ ព្រមទាំងសហគមន៍កសិកម្មរបស់ពួកគេផងដែរ។ នេះគឺជាវិធីល្អបំផុតក្នុងការប្រើប្រាស់សេវាកម្មរបស់សហគមន៍កសិកម្ម។*

***ចំណុចសម្រាប់ការពិចារណា***

- រយៈពេលបីឆ្នាំចុងក្រោយនេះ តើកម្ចីចំនួនប៉ុន្មានដែលអ្នកបានខ្ចីពីសហគមន៍កសិកម្មរបស់អ្នក?
- តើអ្នកបានសងប្រាក់កម្ចីរបស់អ្នកជាមួយនឹងការប្រាក់បានទាន់ពេលវេលាដែរទេ?
- តើអ្នកយល់ស្របថា ឥណទានគួរតែសងវិញឱ្យបានទាន់ពេលដែរទេ?
- តើអ្នកធ្លាប់ប្រឈមនឹងដំណើរការនៃការទទួលបានឥណទានមកវិញដែរទេ?
- តើអ្នកមានសំណើលើកឡើងអំពីនីតិវិធី នៃការសងឥណទានដែរទេ?

---

## ជំពូកទី ២០
## ការធ្វើសវនកម្មលើ
## សហគមន៍កសិកម្ម

រាល់សហគមន៍កសិកម្មទាំងអស់ត្រូវធ្វើសវនកម្មម្តងក្នុងមួយឆ្នាំតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។

សវនកម្មត្រូវធ្វើឡើងដោយសវនករមកពីនាយកដ្ឋាន/មន្រ្តីចុះបញ្ជីទទួលបន្ទុកសហគមន៍កសិកម្ម ឬដោយគណនេយ្យករដែលគេជួលពីទីផ្សារ ដោយមានការអនុម័តពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម។

ប្រសិនបើមានចែងនៅក្នុងលក្ខន្តិកៈ មហាសន្និបាតក៏អាចតែងតាំង / ជ្រើសតាំងសវនករ ឬគណៈកម្មការសវនកម្មដែលអាចពន្យល់បកស្រាយប្រាប់មហាសន្និបាតបាន។

របាយការណ៍សវនកម្ម អាចដាក់ជូនបានតាមរយៈក្រុមប្រឹក្សាភិបាលសម្រាប់ការពិភាក្សា និងអនុម័ត។

លទ្ធផលនៃការពិភាក្សា និងការសម្រេចដោយមហាសន្និបាត ត្រូវធ្វើឡើងជាផ្នែកមួយនៃ

របាយការណ៍ប្រចាំឆ្នាំ។

នៅក្នុងករណីជាច្រើន សហគមន៍កសិកម្មដែលធ្វើអាជីវកម្មតូចតាច ជាទូទៅត្រូវបានលើកលែងពីការធ្វើសវនកម្មផ្លូវការ។ នៅក្នុងករណីដែលរបាយការណ៍របស់គណៈកម្មការគណនេយ្យ ឬគណៈកម្មការត្រួតពិនិត្យល្អគ្រប់គ្រាន់សម្រាប់ដាក់ជូនទៅមហាសន្និបាត និងមន្ត្រីចុះបញ្ជី។

អ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវទាំងស្រុងចំពោះការត្រៀមរាល់ឯកសារ និង facilities សម្រាប់សវនករដើម្បីឱ្យដំណើរការធ្វើសវនកម្មប្រព្រឹត្តទៅយ៉ាងរលូន។

***ចំណុចសម្រាប់ការពិភាក្សា***

- ហេតុអ្វីបានជាការធ្វើសវនកម្មមានសារៈសំខាន់សម្រាប់សហគមន៍កសិកម្ម?
- ហេតុអ្វីបានជារបាយការណ៍សវនកម្ម គួរតែដាក់ជូនទៅមហាសន្និបាត?
- ហេតុអ្វីបានសមាជិករបស់គណៈកម្មការគ្រប់គ្រងមិនអាចធ្វើសវនកម្មបាន?

---

# ជំពូកទី ២១
# ការរៀបចំរចនាសម្ព័ន្ធឡើងវិញរបស់សហគមន៍កសិកម្ម

## [ក] ការរំលាយសហគមន៍កសិកម្ម

សហគមន៍កសិកម្ម អាចរំលាយបានដោយសារមូលហេតុដូចខាងក្រោម៖ [i] ការសម្រេចរបស់មហាសន្និបាត [ii] ការដល់ពេលត្រូវរំលាយចោលដូចបានពណ៌នានៅក្នុងលក្ខន្តិកៈរបស់ខ្លួន [iii] នៅពេលសមាជិកលាឈប់ សល់តែសមាជិកតិចជាង ៦ នាក់ [iv] នៅពេលក្ស័យធន ឬជំពាក់បំណុលច្រើន [v] នៅពេលមានដីកាបង្គាប់ពីតុលាការ [vi] នៅពេលដកវិញ្ញាបនប័ត្រចុះបញ្ជីផ្លូវការ។

## [ខ] ការរួមបញ្ចូលសហគមន៍កសិកម្ម

សហគមន៍កសិកម្មពីរ ឬច្រើនជាងនេះនៅក្នុងព្រំប្រទល់ភូមិសាស្ត្រតែមួយ អាចរួមបញ្ចូលគ្នាតាមការសម្រេចចិត្តរបស់មហាសន្និបាត នៃសហគមន៍កសិកម្មនីមួយៗ។ សហគមន៍កសិកម្មដែលត្រូវបានរួមបញ្ចូលគ្នា ត្រូវតែចុះបញ្ជីជាថ្មីម្តងទៀតដូចសហគមន៍កសិកម្មថ្មីដែរដោយអនុលោមតាមបទបញ្ញត្តិ នៃច្បាប់ជាធរមាន។ សហគមន៍កសិកម្មដែលត្រូវរួមបញ្ចូលគ្នា ត្រូវទូទាត់បំណុលរបស់ខ្លួនជាមួយម្ចាស់បំណុលរួចរាល់ មុនពេលការរួមបញ្ចូលគ្នាចូលជាធរមាន។

## [គ] ការបំបែកខ្លួនសហគមន៍កសិកម្ម

សហគមន៍កសិកម្មអាចត្រូវបំបែកខ្លួនក្នុងករណីមានការផ្លាស់ប្តូរដែនសមត្ថកិច្ច ឬព្រំដែនរដ្ឋបាលឬការបែងចែកការគ្រប់គ្រងអាជីវកម្ម។ ការបំបែកសហគមន៍កសិកម្មអាចពិចារណាបានឱ្យតែមានសំណើពីសមាជិកត្រឹមពាក់កណ្តាល [១/២] ។

បន្ទាប់ពីកាលបរិច្ឆេទនៃដំណោះស្រាយបំបែកខ្លួន សហគមន៍កសិកម្មត្រូវទូទាត់បំណុល។ វាត្រូវចុះបញ្ជីជាមួយមន្ត្រីចុះបញ្ជី។

*ចំណុចសម្រាប់ការពិភាក្សា*

- តើមានអត្ថប្រយោជន៍អ្វីខ្លះសម្រាប់សមាជិក នៅពេលរំលាយសហគមន៍កសិកម្ម?
- តើមានអត្ថប្រយោជន៍អ្វីខ្លះ នៅពេលសហគមន៍កសិកម្មត្រូវបានរួមបញ្ចូលគ្នា?
- តើហេតុអ្វីបានជាសហគមន៍កសិកម្មគួរបំបែកខ្លួនជាពីរ ឬបី?

----------------------------------------------------------------------

# ជំពូកទី ២២
# ការលើកកម្ពស់ការគ្រប់គ្រងមុខរបររបស់សហគមន៍កសិកម្ម

នៅក្នុងប្រទេសភាគច្រើន សហព័ន្ធថ្នាក់ជាតិ និងថ្នាក់ខេត្តត្រូវបានរៀបចំឡើងដោយសហគមន៍កសិកម្មបឋមដើម្បីអនុវត្តមុខរបរសេដ្ឋកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព។ បន្ថែមពីលើនេះ សហភាពជាតិនៃសហគន៍កសិកម្ម ឬសហគមន៍កសិកម្ម ត្រូវបានរៀបចំឡើងដើម្បីតំណាងចលនាសហគមន៍របស់ប្រទេស ហើយផ្តល់គោលការណ៍ណែនាំ សេវាកម្មសវនកម្ម និងសេវាកម្មអប់រំ។

*ចំណុចសម្រាប់ការពិភាក្សា៖*

- ហេតុអ្វីសហភាពមានសារៈសំខាន់សម្រាប់វិស័យនេះ?
- អ្វីជាអត្ថប្រយោជន៍ នៃការបង្កើតសម្ព័ន្ធភាពសម្រាប់សហគមន៍កសិកម្ម?

----------------------------------------------------------------------

# ជំពូកទី២៣
# ចំណុចពិសេសសម្រាប់ការពិចារណា

សូមចាំថា.....

- សហគមន៍កសិកម្មគឺជាស្ថាប័នរបស់អ្នកផ្ទាល់។ អ្នកគឺជាម្ចាស់របស់វា។ អ្នកចាត់ចែងគ្រប់គ្រងតាមបែបលទ្ធិប្រជាធិបតេយ្យ។ អ្នកជាអ្នកតាក់តែង និងអនុវត្តកម្មវិធី និងគោលនយោបាយដោយខ្លួនឯង
- ដោយទិញភាគហ៊ុនសហគមន៍កសិកម្ម អ្នកអាចក្លាយជាសមាជិកដោយស្ម័គ្រចិត្ត ហើយអាចលាឈប់នៅពេលណាដែលអ្នកចង់ចេញ
- បើទោះជាសហគមន៍កសិកម្មចុះបញ្ជីដោយអ្នកកាន់បញ្ជីសហគមន៍កសិកម្មក៏ដោយ ក៏រដ្ឋាភិបាលមិនអាចក្លាយជាម្ចាស់សហគមន៍កសិកម្មឡើយ។ សហគមន៍កសិកម្មក៏មិនមែនជាទីភ្នាក់ងារ ឬនាយកដ្ឋានរដ្ឋាភិបាលដែរ
- អ្នកជាអ្នកបង្កើតលក្ខន្តិកៈ ហើយធ្វើវិសោធនកម្មលើលក្ខន្តិកៈហើយប្ដេជ្ញាគោរពលក្ខន្តិកៈនេះ
- អ្នកអាចបោះឆ្នោតជ្រើសរើសគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាល និងអ្នកទទួលបន្ទុកតាមការិយាល័យ ដូចជា ប្រធាន អនុប្រធាន ហិរញ្ញិក និងសមាជិកផ្សេងៗ។
- អ្នកមានសិទ្ធិក្នុងការឈរឈ្មោះក្នុងតំណែងណាមួយក្នុងសហគមន៍កសិកម្មអាចជាគណៈកម្មាធិការត្រួតពិនិត្យ ឬគណៈកម្មាធិការផ្សេងទៀត
- អ្នកត្រូវបានអនុញ្ញាតឱ្យជ្រើសតាំងអ្នកគ្រប់គ្រងរបស់អ្នក និងនិយោជិតផ្សេងទៀត
- នេះជាសិទ្ធិរបស់អ្នកក្នុងការទទួល និងអានរបាយការណ៍សវនកម្មប្រចាំឆ្នាំ ឬរបាយការណ៍ផ្សេងទៀតរបស់សហគមន៍កសិកម្ម និងលើកសំណួរដើម្បីសួរបញ្ជាក់
- ក្នុងករណីមហាសន្និបាតមិនបានធ្វើឡើងទាន់ពេល ឬអ្នកមិនបានទទួលរបាយការណ៍សវនកម្មប្រចាំឆ្នាំទាន់ពេល អ្នកមានសិទ្ធិក្នុងការសួរហេតុផលពីមន្ត្រីការិយាល័យសហគមន៍កសិកម្ម ឬដាក់ពាក្យបណ្ដឹងទៅអ្នកកាន់បញ្ជីសហគមន៍កសិកម្ម។
- វាមានសារៈសំខាន់បំផុតសម្រាប់ការទូទាត់ប្រាក់ទាំងអស់ក្នុងសហគមន៍កសិកម្ម។ អ្នកត្រូវសុំយកបង្កាន់ដៃបង់ប្រាក់ផ្លូវការ ហើយអ្នកត្រូវរក្សាវាទុកនៅកន្លែងដែលមានសុវត្ថិភាពរបស់អ្នក

- អ្នកមានសិទ្ធិយ៉ាងពេញលេញក្នុងការពិនិត្យគណនីសហគមន៍កសិកម្មរបស់លោកអ្នកនៅពេលណាក៏បាន ហើយបើចាំបាច់អ្នកអាចសុំយកលិខិតចម្លងគណនីដែលបានបញ្ជាក់ជាផ្លូវការ ឬឯកសារផ្សេងទៀតដោយមិនមានការបង់ប្រាក់
- មិនត្រូវបង្កឱ្យមានអំពើពុករលួយដោយឱ្យសំណូកដល់មន្ត្រីការិយាល័យ ឬនិយោជិតសហគមន៍កសិកម្មណាមួយឡើយ
- អ្នកអាចផ្តល់ការណែនាំ និងគំនិតយោបល់ដល់សហគមន៍កសិកម្មសម្រាប់ការងារប្រកបដោយភាពស័ក្តិសិទ្ធិរបស់ខ្លួន
- វាជាសិទ្ធិរបស់អ្នកក្នុងការដកនិយោជិតសហគមន៍កសិកម្មណាមួយក្រោយពីការដាក់ស្នើសមស្រប ដោយព្រោះបុគ្គលនោះមិនមានភាពស័ក្តិសិទ្ធិក្នុងការងារ អាកប្បកិរិយាមិនល្អ ឬមិនមានភាពសមរម្យ
- វត្ថុបំណងចម្បងរបស់សហគមន៍កសិកម្ម គឺដើម្បីធានាការពារអត្ថប្រយោជន៍សមាជិករបស់ខ្លួន និងពង្រឹងមុខតំណែងសេដ្ឋកិច្ច និងសង្គមរបស់ពួកគេនៅក្នុងសហគមន៍កសិកម្ម
- គ្មានសហគមន៍កសិកម្មណាអាចទទួលបានជោគជ័យត្រចះត្រចង់ និងផ្តល់ប្រភេទសេវាកម្មដ៏ត្រឹមត្រូវបានដោយគ្មានការចូលរួមយ៉ាងសកម្មរបស់អ្នកក្នុងសកម្មភាពអង្គភាព និងសេដ្ឋកិច្ចរបស់ខ្លួនឡើយ
- សមាជិកត្រូវយល់ដឹងពីលំហូរចូល និងលំហូរចេញនៃមូលនិធិក្នុងសហគមន៍កសិកម្ម
- សមាជិកត្រូវយល់ដឹងពីសារៈសំខាន់នៃទំនាក់ទំនងល្អរវាងសហគមន៍កសិកម្ម និងធនាគារសហគមន៍កសិកម្ម
- ជួយអ្នកក្នុងប្រតិបត្តិការកសិកម្មដូចជាអ្នកខ្ចីលុយពីសហគមន៍កសិកម្ម សហគមន៍កសិកម្មខ្ចីលុយពីធនាគារសហគមន៍។ ដូច្នេះ វាជាភារកិច្ចរបស់អ្នកក្នុងការសងប្រាក់វិញឱ្យទាន់ពេលដើម្បីឱ្យសហគមន៍នៅតែអាចមានសិទ្ធិខ្ចីលុយពីធនាគារសហគមន៍ម្តងទៀត ហើយឱ្យសមាជិកដែលត្រូវការលុយខ្ចីបន្ត
- បើប្រាក់កម្ចីមិនបានសងទាន់ពេលវេលា សមាជិកសហគមន៍កសិកម្មផ្សេងទៀតមិនអាចទទួល

ឥណទានពីសហាគមន៍កសិកម្មបានឡើយ។ វាជាភារកិច្ចរបស់អ្នកក្នុងការជួយមិត្តរបស់អ្នក [នេះជាអត្ថន័យនៃសហាគមន៍កសិកម្ម]

- បើអ្នកមានអារម្មណ៍ថាបទបញ្ញត្តិមួយចំនួននៃច្បាប់ វិធាន និងបទបញ្ជាសហាគមន៍កសិកម្ម ដែលបង្កើតឡើងដោយនាយកដ្ឋានអភិវឌ្ឍន៍សហាគមន៍បង្កឱ្យមានការរាំងស្ទះភាពរលូននៃមុខងារសហាគមន៍កសិកម្មរបស់អ្នក អ្នកមានសិទ្ធិក្នុងការពិភាក្សាបញ្ហានេះជាមួយមន្ត្រីការិយាល័យ ឬក៏យកបញ្ហានេះទៅពិភាក្សាជាមួយថ្នាក់ដឹកនាំនយោបាយមូលដ្ឋានដូចជាប្រធានគណៈកម្មាធិការភូមិ ឬអ្នកតំណាងរាស្ត្រ។ អ្នកបានបោះឆ្នោតជូនពួកគេ ដូចនេះហើយ វាជាភារកិច្ចរបស់ពួកគាត់ក្នុងការដោះស្រាយបញ្ហាជាមួយរដ្ឋាភិបាល
- ច្បាប់ស្តីពីសហាគមន៍កសិកម្មធ្វើឡើងសម្រាប់ណែនាំ និងគ្រប់គ្រងអាជីវកម្មសហាគមន៍កសិកម្មដោយសមស្រប មិនមែនដើម្បីត្រួតត្រា ឬដឹកនាំឡើយ
- អ្នកត្រូវដឹងថាអ្នកបានអនុម័តលក្ខន្តិកៈសហាគមន៍កសិកម្ម។ អ្នកបានយល់ព្រមគោរពតាមនៅពេលស្នើសុំចូលជាសមាជិកភាព។ ក្នុងករណីដែលអ្នកមិនយល់បទបញ្ញត្តិមួយនៃលក្ខន្តិកៈ ឬមានចម្ងល់ពីអត្ថន័យពិតរបស់វា អ្នកមានសិទ្ធិក្នុងការពិភាក្សាបញ្ហាជាមួយប្រធាន ឬមន្ត្រីការិយាល័យសហាគមន៍កសិកម្ម ឬនាយកដ្ឋានអភិវឌ្ឍន៍សហាគមន៍កសិកម្ម
- វាជាសិទ្ធិរបស់អ្នកក្នុងការទទួលបានព័ត៌មានពេញលេញស្តីពីមុខងារសហាគមន៍កសិកម្មរបស់អ្នក។ អ្នកអាចទទួលព័ត៌មានពីអ្នកគ្រប់គ្រងដែលធ្លាប់ជានិយោជិតរបស់អ្នក។ វាជាភារកិច្ចរបស់គាត់ក្នុងការបម្រើសហាគមន៍កសិកម្ម និងសមាជិករបស់ខ្លួន និងផ្តល់ឱ្យសមាជិកនូវចម្លើយពិត និងសមស្របចំពោះសំណួររបស់ពួកគេ។

------------------------------------------------------------

# ជំពូកទី២៤
# សេចក្តីសង្ខេបនៃការពិភាក្សា

នៅប្រទេសជាច្រើនក្នុងវិស័យសហគមន៍កសិកម្ម សមាជិកដែលជាកសិករប្រឈមមុខនឹងបញ្ហាជាច្រើនដែលបណ្តាលមកពីការភាន់ច្រឡំ និងអំពើពុករលួយ។ ចំណុចដែលផ្តល់ខាងក្រោមនេះគឺក្នុងបំណងបញ្ជាក់ពីបញ្ហាចម្បងមួយចំនួន។ សេចក្តីសង្ខេបនៃប្រធានបទដែលពិភាក្សាក្នុងសៀវភៅណែនាំ និងចំណុចសំខាន់ដែលជួយពង្រឹងសហគមន៍កសិកម្មមានដូចខាងក្រោម៖

*"សហគមន៍កសិកម្ម គឺជាសមាគមន៍ស្វយ័តមួយដែលបង្កើតឡើងដោយមនុស្សមួយក្រុមដោយស្ម័គ្រចិត្តដើម្បីសម្រេចគោលបំណងរួម និងបំពេញតម្រូវការវប្បធម៌ សង្គម និងសេដ្ឋកិច្ច តាមរយៈការចាប់ផ្តើមសហគ្រាសសហកម្មសិទ្ធិ និងគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ"។*

សហគមន៍កសិកម្មជួយពង្រឹងតម្លៃក្រមសីលធម៌ និងមូលដ្ឋានក្នុងចំណោមសមាជិក និងសហគមន៍កសិកម្មទាំងមូល។

០១. ជូនកាលសមាជិកនីមួយៗត្រូវចូលរួមក្នុងអាជីវកម្មសហគមន៍កសិកម្មយ៉ាងទៀងទាត់ដូចជា ការទិញពីសហគមន៍កសិកម្ម ការលក់ទៅឱ្យសហគមន៍កសិកម្ម និងសន្សំប្រាក់ជាមួយសហគមន៍កសិកម្ម

០២. មនុស្សស្មោះត្រង់ និងចេះលះបង់ត្រូវកាន់តំណែងក្នុងសហគមន៍។ អ្នកនោះត្រូវពលីដើម្បីបុព្វហេតុ មូលដ្ឋាន និងគោលការណ៍សហគមន៍កសិកម្ម និងត្រូវទទួលខុសត្រូវចំពោះភារកិច្ចរបស់គាត់ដោយស្មោះត្រង់ និងស្មោះស្ម័គ្រ

០៣. មន្ត្រី និងសមាជិកនាយកដ្ឋានសហគមន៍កសិកម្ម រដ្ឋាភិបាលត្រូវលើកទឹកចិត្តមន្ត្រីការិយាល័យ និងបុគ្គលិក និងត្រូវបន្តបង្ហាញការពេញចិត្តចំពោះការងាររបស់ពួកគេ។ បុគ្គលិកល្អត្រូវផ្តល់រង្វាន់តាមការងាររបស់ពួកគេ

០៤. កិច្ចប្រជុំសហគមន៍កសិកម្មត្រូវធ្វើជាប្រចាំ និងទៀងទាត់ស្របតាមនីតិវិធីដែលតាក់តែងនៅក្នុងលក្ខន្តិកៈសហគមន៍កសិកម្មដែលសមាជិកបានដាក់ដើម្បីអនុវត្តខ្លួនឯងដោយស្ម័គ្រចិត្ត។

០៥. ការធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង និងរបាយការណ៍សវនកម្មត្រូវដាក់ជូនអ្នកកាន់បញ្ជីឱ្យបានទៀងទាត់។ ការពន្យារពេលនឹងនាំឱ្យមានអំពើពុករលួយ និងបង្កលក្ខណៈមិនចាំបាច់

០៦. មន្ត្រីមកពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ធនាគារសហគមន៍ នាយកដ្ឋានអភិវឌ្ឍន៍ជនបទ មូលដ្ឋានគ្រប់គ្រងដោយខ្លួនឯង អង្គការក្រុមជួយខ្លួនឯង និងភ្នាក់ងារពាក់ព័ន្ធផ្សេងទៀតដែលមានបណ្តាញសហគមន៍កសិកម្ម ត្រូវអញ្ជើញចូលរួមកិច្ចប្រជុំជាភ្ញៀវ និងជាវាគ្មិន

០៧. សហគមន៍កសិកម្មត្រូវចៀសវាង "ការដឹកនាំដោយមនុស្សម្នាក់" ទោះត្រូវប្រើវិធីណាក៏ដោយ។

សហគមន៍កសិកម្មមិនមែនជាអង្គភាពដែលកាន់កាប់ដោយមនុស្សម្នាក់ឡើយ ។ វាជាស្ថាប័នដែលគ្រប់គ្រង និងកាន់កាប់ដោយសមាជិក។

០៨. នាយក/ប្រធានត្រូវរៀបចំវគ្គហ្វឹកហ្វឺន និងវគ្គផ្តល់ព័ត៌មានសម្រាប់សមាជិកគណៈកម្មាធិការត្រួតពិនិត្យម្តងម្កាលដែលជួយពួកគាត់ទាក់ទងការប្រែប្រួលគោលនយោបាយ នីតិវិធិ និងនិន្នាការទីផ្សារបច្ចុប្បន្ន

០៩. ចំនួនប្រាក់ជាក់លាក់ត្រូវត្រៀមទុកសម្រាប់ការបណ្តុះបណ្តាលសមាជិក និងហ្វឹកហ្វឺននិយោជិតសហគមន៍កសិកម្មដោយប្រើថវិកាសហគមន៍កសិកម្ម។ ចំនួននេះគឺប្រើសម្រាប់តែការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនប៉ុណ្ណោះមិនមែនសម្រាប់កម្សាន្តឡើយ

១០. នាយក/ប្រធានត្រូវស្នើសុំយោបល់ពីអ្នកគ្រប់គ្រងសហគមន៍កសិកម្មឱ្យបានច្រើនតាមតែអាចធ្វើបានក្នុងការសម្រេចចិត្តលើអាជីវកម្ម និងអង្គភាព។ អ្នកគ្រប់គ្រងដែលជាបុគ្គលិកពេញម៉ោងរបស់សហគមន៍កសិកម្មត្រូវអញ្ជើញឱ្យចូលរួមកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ/ក្រុមប្រឹក្សាភិបាលទាំងអស់លើកលែងតែកិច្ចប្រជុំស្តីពីលក្ខខណ្ឌការងាររបស់អ្នកគ្រប់គ្រងនោះ

១១. សហគមន៍កសិកម្មនីមួយៗត្រូវមានលិខិតចម្លងបទបញ្ជាផ្ទៃក្នុងចុងក្រោយបង្អស់មួយច្បាប់។ សមាជិកគ្រប់រូបត្រូវអានលក្ខន្តិកៈ ឬយ៉ាងហោចណាស់ត្រូវបានពន្យល់ពីចំណុចសំខាន់ៗទាក់ទងនឹងសិទ្ធិ និងភារកិច្ច និងវត្ថុបំណងសហគមន៍កសិកម្ម។

១២. ត្រូវរក្សាគណនីឱ្យមានសុវត្ថិភាព និងថ្មីចុងក្រោយបំផុត។ គណនីត្រូវតែមានតម្លាភាពហើយសមាជិកត្រូវមានការពេញចិត្តចំពោះគណនីរបស់ពួកគេ។

១៣. សមាជិកត្រូវទទួចសុំយកបង្កាន់ដៃបង់ប្រាក់នៅពេលមានការទូទាត់ប្រាក់

១៤. ចំពោះសៀវភៅមូលប្បទានបត្រ ប័ណ្ណឥណទានសមាជិក និងសៀវភៅប្រាក់បញ្ញើសមាជិកត្រូវរក្សាទុកដោយខ្លួនឯង។ មិនត្រូវទុកសៀវភៅមូលប្បទានបត្រនឹងនិយោជិតសហគមន៍កសិកម្មណាម្នាក់ឡើយ

១៥. សហគមន៍កសិកម្មទាំងឡាយណាដែលមានប្រាក់កក់ច្រើនត្រូវមានការយកចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងមូលនិធិ

១៦. សហគមន៍កសិកម្មទាំងឡាយ ជាពិសេសសហគមន៍កសិកម្មថ្នាក់ភូមិ ត្រូវធ្វើអាជីវកម្មចម្រុះ។ ពួកគេមិនត្រូវប្រកាន់យកតែជី និងការចែកចាយពូជប៉ុណ្ណឹងទេ។ យើងមានរបៀបធ្វើអាជីវកម្មផ្សេងទៀតដូចជា ការចែកចាយគីមីកសិកម្ម ការផលិត និងចែកចាយជីកំប៉ុស ការដាក់ប្រាក់កក់ ការចែកចាយឥន្ធនៈ ការភ្ជាស់ស៊ុត ការដាក់ជួលម៉ាស៊ីនកសិកម្ម ការផ្គត់ផ្គង់ទឹក និងអគ្គិសនី ការណែនាំ និងផ្សព្វផ្សាយកសិកម្ម ការធ្វើតេស្តដី និងការសាងសង់ បើកមជ្ឈមណ្ឌលសហគមន៍កសិកម្ម ការផលិតគ្រឿងសង្ហារឹម សម្ភារៈសាងសង់ ជួសជុលម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ការជួលឃ្លាំង ការ

ចិញ្ចឹមឃ្មុំ ការអភិវឌ្ឍសត្វពាហនៈ ការចិញ្ចឹមគោយកទឹកដោះ នេសាទ ។ល។

១៧. សហគមន៍កសិកម្មត្រូវមានសេវាកម្មដែលទាក់ទងនឹងសហគមន៍កសិកម្ម ដូចជា សុខាភិបាល អនាម័យ អំពូលភ្លើងនៅតាមផ្លូវ ទូរទូរស័ព្ទសាធារណៈ ការទូទាត់ថ្លៃអគ្គិសនី ទឹក និង ពន្ធផ្ទះ ការអប់រំមនុស្សពេញវ័យ មជ្ឈមណ្ឌលថែទាំកុមារពេលថ្ងៃ ការផ្ដល់អាហារូបករណ៍កូនៗរបស់ សមាជិក។ល។

១៨. ជាមួយទស្សនៈពង្រីកអាជីវកម្ម និងទំនាក់ទំនងសង្គម សហគមន៍កសិកម្មដែលប្រតិបត្តិការ នៅក្នុងតំបន់ជិតខាងត្រូវរួមគ្នាធ្វើការទាក់ទងនឹងពិធីបុណ្យក្នុងមូលដ្ឋាន។ ការចុះទស្សនកិច្ចផ្លាស់ប្ដូរបទ ពិសោធន៍ជួយឱ្យសមាជិករៀនពីគ្នាទៅវិញទៅមក

១៩. ជាក់ស្ដែងសហគមន៍កសិកម្មមិនមែនជាស្ថាប័នសប្បុរសធម៌ទេ។ ពួកគេមិនអាចមាន លទ្ធភាពផ្ដល់សេវាកម្មដោយឥតគិតថ្លៃឡើយ។ សមាជិកត្រូវបង់ថ្លៃសេវាកម្ម ហើយសមាជិកត្រូវបង់ ប្រាក់ពេលទទួលបានសេវាកម្ម។ ការផ្ដល់សេវាកម្មដោយឥតគិតថ្លៃ ឬចោរកម្ម ឬការខូចខាតធនធាន គឺ ជាការខាតបង់។ មន្ត្រីការិយាល័យត្រូវធានាថា ថ្លៃប្រើប្រាស់ផ្ទាល់ខ្លួនរបស់ពួកគេមិនត្រូវគិតថាជាការ ចំណាយរបស់សហគមន៍កសិកម្មឡើយ។

២០. ចលនាសហគមន៍កសិកម្មមិនមែនត្រឹមតែជាចលនាសេដ្ឋកិច្ច និងសង្គមទេថែមទាំងដើរតួ ជាចលនាស្ថាបនាសីលធម៌ផងដែរ។ សហគមន៍កសិកម្មប្រកបដោយភាពស័ក្តិសិទ្ធិដើរតួជាគំរូសម្រាប់ មនុស្ស។

សហគមន៍កសិកម្ម គឺជាអង្គការប្រមូលផ្ដុំ ជាជាងអង្គការប្រមូលផ្ដុំដើមទុន។ សហគមន៍កសិកម្ម គឺជាសម្ព័ន្ធភ្ជាក់ងារសហគមន៍ពិត។ ពួកវានាំឆ្ពោះទៅរកសាមគ្គីភាពសង្គមដ៏រឹងមាំ។ ដូច្នេះការផ្ដល់ការ បណ្ដុះបណ្ដាល និងការផ្សព្វផ្សាយ គឺជាវិធីសាស្ត្រដ៏សមរម្យបំផុតសម្រាប់អភិវឌ្ឍទ្រព្យសកម្មដែលមាន តម្លៃបំផុតរបស់សហគមន៍កសិកម្មដូចជាសមាជិករបស់ខ្លួន។

# ឧបសម្ព័ន្ធ ១
# ចលនាសហគមន៍កសិកម្មនៅកម្ពុជា

## សេចក្តីផ្តើម

ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា គឺបានកើតឡើងចម្បងនៅជនបទ។ ចំនួនភាគច្រើនដ៏លើសលប់នៃអ្នកក្រ ចិញ្ចឹមជីវិតពួកគេដោយផ្អែកលើកសិកម្ម ហើយអាំងតង់ស៊ីតេនៃភាពក្រីក្រក៏មានខ្ពស់ក្នុងចំណោមកសិករជាងក្នុងចំណោមក្រុមប្រកបមុខរបរផ្សេងទៀត។ ប្រហែល៨៥%នៃចំនួនប្រជាជន និង៩០%នៃអ្នកក្រ រស់នៅតំបន់ដាច់ស្រយាល ហើយការប្រកបរបរកសិកម្មគឺជាប្រភពសំខាន់នៃប្រាក់ចំណូលរបស់ពួកគាត់។ ជាមួយគ្នានេះដែរ កសិកម្មផ្តល់ផលជាង២៦%នៃផលិតផលសរុបក្នុងស្រុកក្នុងឆ្នាំ២០១៣។ ដូច្នេះយុទ្ធសាស្ត្ររដ្ឋាភិបាលដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រទាមទារឱ្យមានការផ្តោតលើការអភិវឌ្ឍវិស័យកសិកម្មឱ្យបានខ្លាំងជាងមុន ដែលជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីបង្កើតការងារបន្ថែម។ ប៉ុន្តែផលិតកម្មដំណាំ សត្វពាហនៈ រុក្ខាប្រមាញ់ និងនេសាទ អាចលើកស្ទួយប្រជាជនឱ្យរួចផុតពីភាពក្រីក្របានលុះត្រាតែមានវិធានការច្បាស់លាស់ក្នុងការការពារ និងជួយអ្នកក្រ ហើយលុះត្រាតែធនធានធម្មជាតិរបស់ប្រទេសត្រូវបានគ្រប់គ្រងឱ្យមាននិរន្តភាព។

ការរួមចំណែកផ្នែកកសិកម្ម ផលិតផលក្នុងស្រុកសរុបបានថយចុះពីប្រមាណ ៥២% ក្នុងឆ្នាំ ១៩៩០ ទៅ២៦%ក្នុងឆ្នាំ២០១៣ ខណៈដែលការរីកចម្រើននៃវិស័យកសិកម្មមានលក្ខណៈយឺតជាងវិស័យឧស្សាហកម្ម។ ទោះជាយ៉ាងណាក៏ដោយ កសិកម្មនៅតែជាវិស័យសំខាន់បំផុតក្នុងសេដ្ឋកិច្ចកម្ពុជា ហើយនៅតែបែបនេះរហូតតទៅ។ ក្នុងវិស័យកសិកម្ម ដំណាំ និងសត្វពាហនៈមានចំនួនប្រហែល ៦៨% នៃតម្លៃសរុបបន្ថែម ជលផលមាន២៦% និងរុក្ខាប្រមាញ់ប្រហែល៥%ក្នុងឆ្នាំ២០១៣។

ផ្ទៃដីសរុបនៃប្រទេសកម្ពុជាមានប្រមាណ១៨,១លានហិកតា ដែលក្នុងនោះ១ភាគ៣ ឬ ៦,៤លានហិកតាជាផ្ទៃដីដែលអាចធ្វើកសិកម្មបាន (ការធ្វើជំរឿនផ្នែកកសិកម្ម ហើយនឹងទទួលបានទិន្នន័យពីរដ្ឋាភិបាលនៅពេលឆាប់ៗនេះ ដូច្នេះយើងត្រូវរង់ចាំទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព)។ នាពេលបច្ចុប្បន្ននេះ ដីដែលរៀបចំប្រកបដោយប្រសិទ្ធភាពដើម្បីធ្វើកសិកម្មមានប្រហែល ២,៧លានហិកតា ដែលបង្ហាញថាមានដី៣,៧លានហិកតាទៀតដែលអាចយកមកធ្វើកសិកម្មបាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ករន) ទទួលខុសត្រូវក្នុងការលើកកម្ពស់ ការអភិវឌ្ឍ និងពង្រឹងសហគមន៍កសិកម្ម។ ចំណែកឯគោលនយោបាយវិញ រដ្ឋាភិបាលពង្រឹងអង្គការកសិករដែលមានស្រាប់ ហើយផ្តល់ជម្រើសឱ្យពួកគេថាតើត្រូវបន្តដូចទម្រង់បច្ចុប្បន្នឬប្តូរទៅជាសហគមន៍កសិកម្ម។

## ប្រវត្តិចលនាសហគមន៍កសិកម្ម

មុនសម័យសង្គ្រាមស៊ីវិល រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់សហគមន៍កសិកម្មក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៦ ការិយាល័យរាជសហគមន៍[OROC] ត្រូវបានបង្កើតក្រោមក្រសួងកសិកម្មក្នុងការផ្តួចផ្តើម និងអភិវឌ្ឍសហគមន៍កសិកម្មដើម្បីជំនួសការិយាល័យឥណទានប្រជាជនដែលកើតមានជិតពីរទសវត្សរ៍។ OROC បានផ្គត់ផ្គង់សហគមន៍នូវកសិកម្មមូលនិធិ និងប្រាក់កម្ចីដើម្បីទិញ និងលក់ទិន្នផលកសិកម្មជនបទ បង្កើតស្ថានីយពិសោធន៍សម្រាប់ផលិតគ្រាប់ពូជល្អ ចញ្ចឹមគោ ក្របី ជ្រូក និងបក្សីដែលជ្រើសរើសយ៉ាងសម្រិតសម្រាំង និងរៀបចំហាងលក់ធំៗនៅតំបន់ដាច់ស្រយាលដើម្បីផ្គត់ផ្គង់សេចក្តីត្រូវការនៅជនបទ និងដើម្បីទិញយកទិន្នផលកសិកម្មរបស់ពួកគេ។ ដោយសារគ្មានអាជីវកម្មឯកជននៅតំបន់ជនបទ ប្រជាជនត្រូវផ្អែកលើសហគមន៍កសិកម្មដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន។ OROC ក៏បានជួយសហគមន៍ផលិតដើម្បីកែលម្អការអនុវត្តតាមបែបធម្មជាតិ។

នៅពាក់កណ្តាលឆ្នាំ១៩៦៦ មានសហគមន៍កសិកម្មសរុបចំនួន៥១២បានដំណើរការនៅក្នុងតំបន់ដាច់ស្រយាល។ សហគមន៍កសិកម្មទាំងនេះបែងចែកជាសហគមន៍ឥណទានខេត្តចំនួន១៣ដែលផ្តល់ប្រាក់កម្ចីដល់សមាជិករបស់ខ្លួន។ អ្នកទទួលផលពីឥណទានភាគច្រើនមិនមែនជាអ្នកនៅក្នុងវណ្ណៈអ្នកក្រទេ។ លើសពីនេះទៅទៀត មានសហគមន៍កសិកម្មដែលមានគោលបំណងច្រើន ចំនួន៣៩០ សហគមន៍អ្នកប្រើប្រាស់ចំនួន៥៥ សហគមន៍ឯកទេសផលិតចំនួន១៤ និងសហគមន៍សាលារៀនចំនួន៤០។ អត្រាចំណូលរបស់ពួកគេក្នុងឆ្នាំ១៩៦៥មានចំនួន១៣លានដុល្លារសហរដ្ឋអាមេរិក។ ចលនាសហគមន៍កសិកម្មបានលេចចេញជារូបរាង និងមានភាពរឹងមាំល្អ ហើយមានលទ្ធផលគួរឱ្យស្ញប់ស្ញែង។ OROC ដែលបានបោះពុម្ពសៀវភៅមួយក្បាលស្តីពីសហគមន៍កសិកម្មសម្រាប់សាលាបឋមសិក្សានៅកម្ពុជា។

ព្រឹត្តិការណ៍កាលប្រវត្តិសំខាន់ៗខាងក្រោមនេះជួយបង្ហាញរូបភាពយ៉ាងច្បាស់នៃការប្រែប្រួលតាមពេលវេលាដោយសហគមន៍កសិកម្មៈ

១៩៥៦ សេចក្តីលម្អិតពីលក្ខន្តិកៈរបស់ OROC

១៩៥៨ ការបង្កើតសហគមន៍អ្នកប្រើប្រាស់ក្នុងខេត្តចំនួន១៣

១៩៦០ ការបង្កើតសហគមន៍កសិកម្មដែលមានគោលបំណងច្រើនក្នុងខេត្តចំនួន១៣

១៩៦១ ការប្តូរសហគមន៍កសិកម្មឱ្យស្ថិតនៅក្រោមគណៈរដ្ឋមន្ត្រី

១៩៦៤ ការបង្កើតសហគមន៍កសិកម្មឱ្យឈានដល់លំដាប់ថ្នាក់ខេត្ត

១៩៦៦ ការស្ថាបនាមហាវិទ្យាល័យសហគមន៍កសិកម្ម

១៩៦៧ ការស្ថាបនាសហគមន៍កសិកម្មចំនួន១៤ដែលមានឯកទេសលើស្រូវ កប្បាស ថ្នាំជក់ ។ល។

១៩៧០ ការចាប់ផ្តើមនៃរបប លន់ នល់ ៖ ឈ្មោះOROCបានប្តូរទៅជាការិយាល័យសហគមន៍ជាតិ [NCO]

១៩៧៤ ការប្តូរសហគមន៍កសិកម្មឱ្យស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្ម

១៩៧៥ របប ប៉ុល ពត ៖ សហករណ៍បានប្តូរទៅជា "មនុស្សរួម" តាមគំរូចិន។ ដីសម្ភូហភាព ការងារសម្ភូហភាព រោងបាយរួម កន្លែងហូបអាហាររួម ត្រូវបានស្ថាបនាឡើងផ្ទុយពីឆន្ទៈប្រជាជន។

១៩៧៩ របបវៀតណាមៈ "ក្រុមសាមគ្គី" ដែលមានគ្រួសារនៅជិតគ្នាពី១៥-៣០គ្រួសារ សម្រាប់ការប្រមូលផលរួមប៉ុន្តែភាពជាម្ចាស់ដីនៅមានកម្រិត ការចែករំលែកសម្ភារៈ និងសត្វដែលនៅសល់នៅមានកម្រិត។ ការរៀបចំនេះបានជួយស្ត្រីមេម៉ាយជាច្រើនដែលមានកូនបានត្រឹមតែមួយគ្រប់។

១៩៨៩ កិច្ចពិភាក្សានៅកម្រិតក្រសួងកសិកម្មស្តីពីសេចក្តីត្រូវការក្នុងការបង្កើត "អង្គការកសិករ"។ ប្រធាននាយកដ្ឋានក្សេត្រសាស្ត្របានផ្ទេរការងារជាមួយនឹងការទទួលខុសត្រូវនៃការរៀបចំលក្ខន្តិកៈ។ ប៉ុន្តែឯកសារដែលចាំបាច់នេះមិនដែលបានសរសេរជាលាយលក្ខណ៍អក្សរទេ។

១៩៩៩ សិក្ខាសាលាស្តីពីការស្ថាបនាសហគមន៍កសិកម្មធ្វើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រទេសកម្ពុជា។

២០០១ ព្រះរាជក្រឹត្យស្តីពីការស្ថាបនា និងមុខងារសហគមន៍កសិកម្មបានប្រកាសឱ្យប្រើប្រាស់ដើម្បីគាំទ្រការស្ថាបនាសហគមន៍កសិកម្មដោយស្របច្បាប់។ ការិយាល័យអង្គការកសិករដែលទទួលបន្ទុកស្ថាបនា និងលើកកម្ពស់សហគមន៍កសិកម្មត្រូវបានបង្កើតឡើងក្នុងនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រទេសកម្ពុជា។

២០០៣ ប្រកាសស្តីពីការស្ថាបនា និងការចុះបញ្ជីសហគមន៍កសិកម្មបានប្រកាសដើម្បីបំពេញតាមព្រះរាជក្រឹត្យ។

២០១៣ ច្បាប់ស្តីពីសហគមន៍កសិកម្មត្រូវបានអនុម័តជាសន្តតិកម្មនៃព្រះរាជក្រឹត្យ

២០១៤ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មត្រូវបានស្ថាបនាឡើងក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រទេសកម្ពុជា ជានាយកដ្ឋានឯកទេសទទួលបន្ទុកអភិវឌ្ឍន៍សហគមន៍កសិកម្ម។

ខាងក្រោមនេះជាដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍសហគមន៍កសិកម្មនៅកម្ពុជាៈ

១៩៥៦-១៩៦៩ រាជសហករណ៍

១៩៧៥-១៩៧៩ សហាគមន៍ប្រមូលផ្តុំ

១៩៧៩-១៩៨៩ ក្រុមសាមគ្គីបង្កបង្កើនផល

២០០១-២០១២ សហាគមន៍អភិវឌ្ឍន៍កសិកម្ម

២០១៣- ដល់បច្ចុប្បន្ន សហាគមន៍កសិកម្ម

ក្រោយពីឆ្នាំ១៩៧៩ កសិកម្មកម្ពុជាត្រូវបានរៀបចំជាលក្ខណៈមូលដ្ឋានប្រមូលផ្តុំដែលមាន១២-១៥គ្រួសារបង្កើតបានជាក្រុមសាមគ្គីមួយ ដែលក្នុងពេលនោះវាជាអង្គការកសិករតែមួយប្រភេទប៉ុណ្ណោះនៅកម្ពុជា។ សមាជិកក្រុមសាមគ្គីបង្កបង្កើនផលលើផ្ទៃដីចន្លោះពី១៥ទៅ២០ហិកតាដោយប្រើកម្លាំងពលកម្ម ឧបករណ៍កសិកម្ម និងសត្វដែលជាកម្លាំងអូសទាញរួមគ្នា។ ប្រព័ន្ធក្រុមសាមគ្គីត្រូវរំពឹងថា ធានាការចែកចាយដី សត្វដែលជាកម្លាំងអូសទាញ ឧបករណ៍កសិកម្ម កម្លាំងពលកម្មបុរស [កម្លាំងពលកម្មស្ត្រីមានរហូតដល់៧០%] ឱ្យបានស្មើ និងយុត្តិធម៌។ សមាជិកក្រុមសាមគ្គីនីមួយៗត្រូវបានផ្តល់ដីផ្ទាល់ខ្លួនមួយប្លង់ដែលមានផ្ទៃក្រឡាប្រមាណ ៦០០-២.០០០ម² សម្រាប់សង់លំនៅដ្ឋាន និងធ្វើកសិកម្មផ្ទាល់ខ្លួន។ ក្នុងការផ្តល់ដីផ្ទាល់ខ្លួននេះ សមាជិកអាចអនុញ្ញាតឱ្យដាំដំណាំឬបន្លែ ដើម្បីបង្កើនផលិតកម្ម ដែលអាចយកមកប្រើក្នុងគ្រួសារ ឬលក់ផ្ទាល់ខ្លួនបាន។ នៅក្នុងឆ្នាំ១៩៨៧ ប្រទេសកម្ពុជាមានក្រុមសាមគ្គីចំនួន ១២៤.៣៧៧ក្រុម។

ក្រុមសាមគ្គីត្រូវបានចាត់ទុកជាក្រុមប្រមូលផ្តុំដ៏មានប្រយោជន៍ក្នុងន័យដែលពួកគេបម្រើជាក្រុមផលិតកម្មដែលផ្តល់ការងារ និងសន្តិសុខក្នុងការចិញ្ចឹមជីវិតចំពោះស្ត្រី [ព្រោះបុរសភាគច្រើនត្រូវបានសម្លាប់]។ ក្រុមទាំងនេះ ក៏បានផ្តល់ស្បៀងសម្រាប់ប្រើប្រាស់ក្នុងប្រទេសព្រមទាំងបណ្តាញចែកចាយសម្ភារៈកសិកម្មដូចជា គ្រាប់ពូជ ឧបករណ៍ ជី ។ល។ នៅពេលនោះ ដីកសិកម្មជាកម្មសិទ្ធិរបស់រដ្ឋ។ ផលិតកម្មត្រូវបានចែករំលែកក្នុងចំណោមសមាជិក ហើយផលិតផលដែលនៅសល់ត្រូវទុកនៅភូមិក្រោមការមើលការខុសត្រូវ និងត្រួតពិនិត្យពីមេឃុំ/មេភូមិ។ ពួកគេធ្វើការតាមរបៀបកសិកម្មរួមគ្នា។ ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ[MAFF] បានជួយសម្របសម្រួលការបង្កបង្កើនផលផលិតកម្ម និងការស្តុកទុក។ នៅពេលនោះមិនមានប្រព័ន្ធទីផ្សារកសិកម្មទេ។

ក្រោយពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ១៩៩៣ មានការរៀបចំដី ហើយផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីជូនកសិករ ហើយអនុញ្ញាតឱ្យមានការធ្វើទីផ្សារផ្សព្វផ្សាយទិន្នផលកសិកម្មរបស់ពួកគេ ហើយមិនមានការបង់ពន្ធកសិកម្មឡើយ។

ដោយសារទិន្នផលកសិកម្មមានការថយចុះ ហើយក្រុមសាមគ្គីបានចាប់ផ្តើមរំលាយខ្លួន កសិករត្រូវការការផ្គត់ផ្គង់សម្ភារៈកសិកម្មជាលក្ខណៈប្រព័ន្ធ ហើយរដ្ឋាភិបាលក៏ត្រូវការរក្សាទុកស្បៀងមួយចំនួនដែរ។ បន្ទាប់មករដ្ឋាភិបាលបានស្ថាបនាក្រុមហ៊ុនរដ្ឋដែលមានឈ្មោះថា COCMA។ ក្នុងការធ្វើឱ្យស្របតាមការលើកកម្ពស់ និងកែទម្រង់សេដ្ឋកិច្ចស្ថាប័នអាជីវកម្មរដ្ឋ COCMA ត្រូវបានរៀបចំរចនា

សម្ព័ន្ធឡើងវិញទៅជា សាជីវកម្មធនធានកសិកម្ម [AIC] ជាសាជីវកម្មរដ្ឋក្នុងឆ្នាំ១៩៩៩ ក្រោមការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ វត្ថុបំណងរបស់វាគឺ៖ ទទួលរ៉ាប់រងការងារពាក់ព័ន្ធជំនួញ និងសេវាផ្សេងទៀតក្នុងផ្នែកសម្ភារៈកសិកម្ម និងការផ្គត់ផ្គង់ ដើម្បីនាំចេញ និងលក់សម្ភារៈកសិកម្មដូចជាជី គ្រាប់ពូជ ថ្នាំសម្លាប់សត្វល្អិត និងឧបករណ៍ និងសម្ភារៈដែលបម្រើឱ្យផលិតកម្មកសិកម្មដើម្បីឱ្យស្របនឹងគោលនយោបាយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបើធៀបនឹងជីគីមីសម្ភារៈកសិកម្ម និងការចែកចាយរបស់ពួកគេ ដើម្បីគ្រប់គ្រងព័ត៌មានស្ថិតិ និងទិន្នន័យនាំចេញ និងនាំចូល ដើម្បីចូលរួមក្នុងសន្និសីទបណ្តុះបណ្តាល និងសិក្ខាសាលាទាក់ទងនឹងជីគីមី ដើម្បីចូលរួម និងសម្របសម្រួលក្នុងការសិក្សាដើម្បីការអភិវឌ្ឍ និងលើកកម្ពស់សម្ភារៈកសិកម្ម ជាពិសេសជីគីមី។

*អំពីអ្នកនិពន្ធ....*

**វេជ្ជបណ្ឌិត Daman Prakash** ជនជាតិឥណ្ឌា គឺជាអតីតនាយកការិយាល័យតំបន់សម្ព័ន្ធសហគមន៍ អន្តរជាតិនៃអាស៊ីប៉ាស៊ីហ្វិក ជាអតីតប្រធានផ្នែកទីប្រឹក្សាបច្ចេកទេសស្តីពីការគ្រប់គ្រងសហគមន៍នៅអង្គការពលកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិនៅប្រទេសឥណ្ឌូនេស៊ី ជាអតីតទីប្រឹក្សាគម្រោង FAO នៅប្រទេសមីយ៉ាន់ម៉ា ជាអតីតទីប្រឹក្សាបច្ចេកទេសគម្រោងICA/SCC ស្តីពីវគ្គហ្វឹកហ្វឺនគ្រូសហគមន៍នៅប្រទេសស្រីលង្កា ជាទីប្រឹក្សាជាន់ខ្ពស់នៅបណ្តាញអភិវឌ្ឍន៍សហគមន៍កសិកម្មក្នុងអាស៊ីប៉ាស៊ីហ្វិក [NEDAC] និងជាទីប្រឹក្សាមូលនិធិIFFCO។ ថ្មីៗនេះជានាយកមជ្ឈមណ្ឌលគ្រប់គ្រង និងអភិវឌ្ឍន៍ជនបទនៅទីក្រុងញូវដេលីប្រទេសឥណ្ឌា ដែលមានបទពិសោធន៍៥៥ឆ្នាំក្នុងវិស័យអភិវឌ្ឍន៍សហគមន៍នៅក្នុងប្រទេសឥណ្ឌា និងក្រៅប្រទេស។ លោកមានការបោះពុម្ពសៀវភៅ និងការស្រាវជ្រាវបច្ចេកទេសមួយចំនួនដែលធ្វើឱ្យគាត់ទទួលបានការជឿទុកចិត្ត។ លោកអ្នកអាចទំនាក់ទំនងទៅកាន់លោកតាមរយៈ <damanprakash@yahoo.co.in>។

**Study Guide for Training of Agricultural Cooperative members and officials in Cambodia**
Printed date in July 2015
Published by Department of Agricultural Cooperative Promotion of GDA (MAFF)
The Project for Establishing Business Oriented Agricultural Cooperative Models (BPAC)
Address: #54B/49F.St395-656,Sangkat Toeuk Laak 3 Khan Tuol Kok, Phnom penh ,Cambodia,
Phone: (023) 883 427, Fax : 023) 883 427
© The Project for Establishing Business-Oriented Agricultural Cooperative Models